ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សា ទុតិយភូមិនៅរាជធានីភ្នំពេញ

## THE CHALLENGES OF LEARNING AND TEACHING ENGLISH LISTENING SKILLS AT HIGH SCHOOL (STATE SCHOOL) IN PHNOM PENH


ដោយ/By

**យ៉ា ច័ន្ទសុធា**/ YA CHANSOTHEA


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សា ទុតិយភូមិនៅរាជធានីភ្នំពេញ

THE CHALLENGES OF LEARNING AND TEACHING ENGLISH LISTENING SKILLS AT HIGH SCHOOL (STATE SCHOOL)
IN PHNOM PENH

ដោយ/By

យ៉ា ច័ន្ទសុធា/YA CHANSOTHEA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបង្គោល៖ លោកបណ្ឌិត នី រដ្ឋា

គ្រូដឹកនាំរង៖ លោក លឹម វ៉ាន់

# សេចក្តីអះអាងរបស់បេក្ខជន

នាងខ្ញុំឈ្មោះ **យ៉ា ច័ន្ទសុជា** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**យ៉ា ច័ន្ទសុជា**

# លិខិតបញ្ជាក់

**លោកបណ្ឌិត នី រដ្ឋា** ជាគ្រូដឹកនាំបង្គោល

**លោក លឹម វ៉ាន់** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **យ៉ា ច័ន្ទសុធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ **"បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ"** ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

| | |
|---|---|
| **លោកបណ្ឌិត នី រដ្ឋា** | **លោក លឹម វ៉ាន់** |
| គ្រូឧបទ្ទេស | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** [illegible] **អយក.**[illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ [illegible]៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ ក៏ដូចជាផ្តល់ឱកាសដល់រូបនាងខ្ញុំឱ្យបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។ នាងខ្ញុំក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ព្រមទាំងលោកប្រធានការិយាល័យអប់រំខណ្ឌ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សនៅតាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការណ៍ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាពិសេសនាងខ្ញុំសូមគោរព ថ្លែងអំណរគុណជូនចំពោះ **លោកបណ្ឌិត នី រដ្ឋា** គ្រូដឹកនាំបង្គោលសរសេរនិក្ខេបបទដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយពន្យល់ណែនាំបង្ហាញផ្លូវ និងផ្តល់ចំណេះដឹងល្អៗ និងលោកសាស្ត្រាចារ្យ លឹម វ៉ាន់ គ្រូដឹកនាំរងផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ដល់រូបខ្ញុំ ព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី៧ និងមិត្តរួមការងារ ជាពិសេសស្វាមីព្រមទាំងបុត្រ ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការអភិវឌ្ឍគុណភាពគ្រូបង្រៀន និងគុណភាពវិស័យអប់រំ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់ ការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលគឺជាចំណុចអទិភាពមួយក្នុងចំណោមកំណែទម្រង់ទាំង១៥របស់ក្រសួងអប់រំ។ អ្នកសិក្សាស្រាវជ្រាវជ្រើសរើសប្រធានបទបញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស នៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីសិក្សាស្វែងយល់ពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀននិងរៀន លើសមត្ថភាពស្ដាប់ភាសាអង់គ្លេស និងសិក្សាពីបញ្ហាប្រឈមនានាក្នុងការបង្រៀននិងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូល តាមរយៈការប្រើកម្រងសំណួរទៅលោកគ្រូ-អ្នកគ្រូចំនួន២០ នាក់គណៈគ្រប់គ្រងចំនួន១៣នាក់ និងសិស្សចំនួន១៩០នាក់ ដែលមកពីអនុវិទ្យាល័យចំនួន៧ ក្នុងរាជធានីភ្នំពេញនៃខណ្ឌចំនួន៦។ ដើម្បីសិក្សាទៅលើប្រធានបទមួយនេះឱ្យបានជោគជ័យអ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណ ហើយវិភាគទន្និន័យដោយប្រើប្រាស់កម្មវិធី Excel និងវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ដោយអ្នកស្រាវជ្រាវចងក្រងជាសំណួរបើកដើម្បីទទួលបានព័ត៌មានបន្ថែម សម្រាប់គាំទ្រចម្លើយមួយចំនួនឱ្យបានជាក់លាក់។ តាមរយៈការសិក្សាបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនបានប្រើប្រាស់វិធីសាស្ត្របង្រៀននៅមានលក្ខណៈល្អមិនទាន់គ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ទាមទារឱ្យគ្រូត្រូវយកចិត្តទុកដាក់លើដំណើរបង្រៀននិងរៀន ដើម្បីឱ្យការសិក្សារបស់សិស្សទទួលលទ្ធផលសិក្សាប្រកបដោយគុណភាព។ ដោយឡែកនៅក្នុងការរៀននិងបង្រៀនបំណិនស្ដាប់ភាសាអង់គ្លេស មានកត្តាមួយចំនួនអ្នកស្រាវជ្រាវបានរកឃើញតាមទិន្នន័យសរុបរបស់គ្រូនិងភាគីពាក់ព័ន្ធ ដូចជាកត្តាបណ្ណាល័យខ្វះសៀវភៅអានភាសាអង់គ្លេស បន្ទប់សោតទស្សន៍ភាសាបរទេស និងកង្វះខាតសម្ភារ

ឧបទេស ម៉ាញេចាក់កាសែត កាសែតសម្លេង ថាសសម្លេងCD VCD និងកត្តាគ្រូបង្រៀនដោយមិនបានប្រើសម្ភារឧបទេសជួយក្នុងការបង្រៀនសមត្ថភាពស្តាប់ ដែលចាំបាច់បំផុតលើការអនុវត្តស្តាប់ផ្ទាល់ពីម៉ាញេកាសែត ស៊ីឌី ពីការបញ្ចេញសម្លេងផ្ទាល់ ដែលធ្វើឱ្យការប្រើប្រាស់វិធីសាស្រ្តបង្រៀននៅមិនទាន់មានប្រសិទ្ធភាពល្អប្រសើរ ហើយបើគ្រូខ្លួនឯងពុំមានទំនួលខុសត្រូវលើតួនាទី ភារកិច្ច កាតព្វកិច្ចរបស់ខ្លួនទេនោះ វានឹងបង្កើតឱ្យមានបញ្ហាប្រឈមទៅលើគុណភាពនៃការបង្រៀន។ ដោយសារកង្វះសៀវភៅសិក្សាគោល ចំណេះដឹង និងវិធីសាស្រ្តបង្រៀនរបស់គ្រូបង្រៀនលើមុខវិជ្ជាភាសាអង់គ្លេសខ្វះឯកសារស្រាវជ្រាវផ្សេងៗ និងសម្ភារឧបទេសដែលបម្រើឱ្យការបង្រៀន និងរៀនលើមុខវិជ្ជាភាសាអង់គ្លេស ជាកត្តាជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការសិក្សារបស់សិស្ស។ ដោយឡែកកត្តាសិស្ស៨៣% មានសមត្ថភាពភាសាអង់គ្លេសមធ្យម និងការប្រើប្រាស់វិធីសាស្រ្តរៀននៅមានកម្រិតមធ្យម ព្រមទាំងសិស្ស៥២% មានការលំបាកទៅលើពាក្យស្តាប់មិនសូវបានការបញ្ចេញសម្លេង និងលើកដាក់សម្លេងរបស់ការសន្ទនាក្នុងការសែត រីឯសិស្ស ៣០ %ជួបពាក្យពិបាកខណៈពេលស្តាប់ សិស្ស២៥ % ជួបការលំបាកទៅលើការនិយាយមានល្បឿនលឿន និងសិស្ស២៥% ជួបការលំបាកទៅលើការស្តាប់មិនសូវបាននិងសម្លេងមិនច្បាស់ពីកាសែត។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានរកឃើញខាងលើ សំណូមពរមួយចំនួនត្រូវបានដាក់ចេញស្នើដល់ស្ថាប័ន និងភាគីពាក់ព័ន្ធមួយចំនួន។ សម្រាប់គណៈគ្រប់គ្រងសាលាគួរតែធ្វើផែនការផ្គត់ផ្គង់សម្ភារឧបទេសបង្រៀន និងលើកទឹកចិត្តដល់គ្រូបង្រៀន ឱ្យមានការប្រកួតប្រជែងសមត្ថភាពភាសាអង់គ្លេសរបស់សិស្ស រីឯក្រសួងនិងមន្ទីរអប់រំ យុវជន និងកីឡា រៀបចំឱ្យមានការប្រជុំផ្លាស់ប្តូរបទពិសោធន៍គ្រូភាសាអង់គ្លេសថ្នាក់ខេត្ត រាជធានី។ សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយគួរតែពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀតជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត និងសិក្សាស្រាវជ្រាវនៅខេត្តផ្សេងទៀត។

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** .......... i

**លិខិតបញ្ជាក់** .......... ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** .......... iii

**សេចក្តីថ្លែងអំណរគុណ** .......... iv

**មូលន័យសង្ខេប** .......... v

**មាតិកា** .......... vii

**បញ្ជីតារាង** .......... xii

**អក្សរកាត់** .......... xiii

**ជំពូកទី១** .......... 1

១.សេចក្តីផ្តើម .......... 1

១.១.លំនាំបញ្ហានៃការស្រាវជ្រាវ .......... 1

១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ .......... 2

១.៣.គោលបំណងនៃការស្រាវជ្រាវ .......... 4

១.៤.សំណួរស្រាវជ្រាវ .......... 4

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ .......... 4

១.៦.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ .......... 5

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... 6

**ជំពូកទី២** .......... 8

ការរំឭកទ្រឹស្តី .......... 8

២.១.និយមន័យ .......... 8

២.១.១.សមត្ថភាពស្តាប់ ........ 8
២.១.២.ប្រភេទនៃការស្តាប់ ........ 9
២.១.៣.ជំហានក្នុងការបង្រៀនសមត្ថភាពស្តាប់ ........ 10
២.២.វិធីសាស្ត្របង្រៀនសម្ថតភាពស្តាប់ ........ 11
២.២.១.វិធីសាស្ត្របង្រៀនសមត្ថភាពស្តាប់ដោយចាក់សម្លេង (The Audio Lingual Method) . 12
២.២.២.វិធីសាស្ត្របង្រៀនដោយការចាក់ភ្លេង(Suggestopedia) ........ 13
២.២.៣.វិធីសាស្ត្រស្តាប់ដោយយល់ (Comprehensive Listening) ........ 14
២.២.៤.ការបង្រៀនភាសាបែបទំនាក់ទំនង (Communicative Langauge Teaching) ........ 15
២.២.៥.វិធីសាស្ត្របកប្រែ (The Grammar Translation Method) ........ 15
២.២.៦.ការបង្រៀនដោយផ្ទាល់ (The Direct Method) ........ 17
២.២.៧.ចំនុចត្រូវពង្រឹងក្នុងសមត្ថភាពស្តាប់ ........ 18
២.២.៨.បញ្ហានៃការស្តាប់(Problem of listening Skills) ........ 19
២.២.៩.សម្ភារឧបទ្ទេសសម្រាប់បង្រៀនការស្តាប់ ........ 21
២.៣.សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស ........ 23
២.៣.២ ការប្រឡងស្តង់ដារអន្តរជាតិ ........ 25
២.៤.កម្មវិធីសិក្សាលម្អិតមធ្យមសិក្សាទុតិយភូមិ ........ 25
២.៥ ការលើកទឹកចិត្ត ........ 28
**ជំពូកទី៣** ........ 31
វិធីសាស្ត្រស្រាវជ្រាវ ........ 31
៣.១.ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ ........ 31
៣.២.ទីកន្លែងសិក្សាស្រាវជ្រាវ ........ 33
៣.៣.ភាគសំណាក និងទំហំភាគសំណាក ........ 35

៣.៤.ឧបករណ៍សម្រាប់ធ្វើការស្រាវជ្រាវ ........ 36

៣.៤.១.កម្រិតចង្អុលបង្ហាញ ........ 36

៣.៤.២.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ........ 37

៣.៤.៣.កម្រងសំណួរសម្រាប់គ្រូបង្រៀន ........ 38

៣.៤.៤.កម្រងសំណួរសម្រាប់សិស្ស ........ 38

៣.៥.វិធីសាស្ត្រប្រមូលទិន្នន័យ ........ 39

៣.៦.ដំណើរការក្នុងការប្រមូលទិន្នន័យ ........ 39

៣.៧.ការវិភាគទិន្នន័យ ........ 40

៣.៨.ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ........ 41

៣.៩.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ 41

**ជំពូកទី៤** ........ 43

លទ្ធផល និងការពិភាក្សា ........ 43

៤.១.ទិន្នន័យព័ត៌មានទូទៅ(គ្រូបង្រៀន សិស្សនិងគណៈគ្រប់គ្រង) ........ 43

៤.១.១.ព័ត៌មានទូទៅរបស់អ្នកចូលរួម ........ 43

៤.២.ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនបំណិនស្តាប់ភាសាអង់គ្លេស ........ 48

៤.២.១.ទិន្នន័យការឆ្លើយតបរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រងនិងដឹកនាំលើការបង្រៀនភាសាអង់គ្លេស ........ 48

៤.២.២.ទិន្នន័យការឆ្លើយតបរបស់គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀន ........ 51

៤.២.៤ ទិន្នន័យសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន ........ 57

៤.២.៣.ទិន្នន័យការឆ្លើយតបរបស់សិស្សប្រើប្រាស់វិធីសាស្ត្ររៀន ........ 58

៤.២.៤.ទិន្នន័យសរុបនៃការឆ្លើយតបរបស់សិស្ស ........ 61

៤.២.៥.សរុបទិន្ន័យការប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ........ 61

៤.៣.ការវិភាគទិន្នន័យលើកម្រងទី២ មធ្យមភាគ (គ្រូបង្រៀននិងសិស្ស) ........ 62

៤.៣.១បញ្ហាប្រឈមលើការបង្រៀន ........................................................................ 62
៤.៣.២.សរុបទិន្នន័យលើបញ្ហាប្រឈមលើការបង្រៀននិងរៀនសមត្ថភាពស្តាប់(គ្រូបង្រៀន និងសិស្ស) ........................................................................ 66
៤.៣.៣.ការពិភាក្សាលើការប្រើប្រាស់វិធីសាស្រ្តរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់កម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ ........................................................................ 66
៤.៣.៣.១.ផ្នែកកម្មវិធីសិក្សា និងដំណើរការបង្រៀន ........................................................................ 66
៤.៣.៣.២.គ្រូបង្រៀន និងដំណើរការបង្រៀនក្នុងថ្នាក់ ........................................................................ 67
៤.៣.៣.៣.សម្ភារឧបទ្ទេស បន្ទប់ភាសា និងសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស ........... 69
៤.៣.៣.៤.សិស្ស និងដំណើរការបង្រៀនក្នុងថ្នាក់ ........................................................................ 70
៤.៤.១ ទិន្នន័យបែបគុណវិស័យដែលទទួលបាន ពីគណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស លើបញ្ហាប្រឈមនៃការរៀននិងបង្រៀន ........................................................................ 72
ក. ពិភាក្សាលើបញ្ហាប្រឈមគ្រូ ក្នុងការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ........................................ 73
ខ.ដំណើរការរៀនរបស់សិស្ស ........................................................................ 76
គ.ដំណោះស្រាយលើដំណើរការបង្រៀន៖ ........................................................................ 78
**ជំពូកទី៥** ........................................................................ 81
សេចក្តីសន្និដ្ឋាន និងសំណូមពរ ........................................................................ 81
៥.១.សេចក្តីសន្និដ្ឋាន ........................................................................ 81
៥.២.សំណូមពរ ........................................................................ 82
៥.២.១.ក្រសួងអប់រំ យុវជន និងកីឡា ........................................................................ 82
៥.២.២.មន្ទីរអប់រំ យុវជន និងកីឡា ........................................................................ 83
៥.២.៣.គណៈគ្រប់គ្រងសាលា ........................................................................ 83
៥.៤.៣.គ្រូបង្រៀន ........................................................................ 83
៥.៤.៤.ការសិក្សាស្រាវជ្រាវបន្ត ........................................................................ 83

**ឯកសារយោង** ........................................ 84
**ឧបសម្ព័ន្ធ** ........................................ 87
ឧបសម្ព័ន្ធ "ក" ........................................ 87
កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គណៈគ្រប់គ្រង ........................................ 87
ឧបសម្ព័ន្ធ "ខ" ........................................ 90
កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់លោកគ្រូ-អ្នកគ្រូ........................................ 90
ឧបសម្ព័ន្ធ "គ" ........................................ 95
កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់សិស្ស........................................ 95
ឧបសម្ព័ន្ធ "ឃ" ........................................ 99
លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ ........................................ 99

# បញ្ជីតារាង


តារាង ៣.១. ឈ្មោះខណ្ឌ និងសាលា 34

តារាង ៣.២. ភាគសំណាក និងទំហំភាគសំណាក 35

តារាង ៤.១ ទិន្នន័យព័ត៌មានទូទៅពីគ្រូ 44

តារាង ៤.២ ទិន្នន័យព័ត៌មានទូទៅពីសិស្ស 45

តារាង ៤.៣ ទិន្នន័យព័ត៌មានទូទៅពីគណៈគ្រប់គ្រង 47

តារាង ៤.៤ ការគ្រប់គ្រងនិងតាមដានគ្រូបង្រៀនភាសាអង់គ្លេស 49

តារាង ៤.៥ ការប្រើវិធីសាស្រ្តបង្រៀនបំណិនស្តាប់ 51

តារាង ៤.៦ ការប្រើប្រាស់សម្ភារឧបទេសជំនួយដល់ការបង្រៀន 53

តារាង ៤.៧ ការជំរុញនិងលើកទឹកចិត្ត 54

តារាង៤.៨ ការយល់ឃើញរបស់គ្រូនៃសារប្រយោជន៍ការរៀននិងបង្រៀនសមត្ថភាពស្តាប់ 56

តារាង៤.៩ ទិន្នន័យសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន 57

តារាង៤.១០ វិធីសាស្រ្តរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស 58

តារាង.៤.១១ សម្ភារឧបទេស 60

តារាង ៤.១២ ទិន្នន័យសរុបនៃការឆ្លើយតបរបស់សិស្ស 61

តារាង៤.១៣ ន័យសរុបការប្រើប្រាស់វិធីសាស្រ្តក្នុងការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស 62

តារាង៤.១៤ ក.កត្តាគ្រូបង្រៀន 62

តារាង៤.១៥ ខ.កត្តាសិស្ស 64

តារាង៤.១៦ ទិន្នន័យសរុបកម្រងសំណួរលើបញ្ហាប្រឈមលើការបង្រៀនសមត្ថភាពស្តាប់ 66

# អក្សរកាត់

| | |
|---|---|
| ALM | :(The Direct Method) |
| CBT | :(Computer Based Test) |
| CL | :(Comprehensive Listening) |
| CLM | :(Communicate Language Method) |
| CLT | :(Communicative language Teaching) |
| GTM | :(Grammar Translation Method) |
| IBC | :(Internet Based Test) |
| IELTS | :(International English Language Test System) |
| L1 | :(Language 1) |
| TOEFL | :(Test of English foreign Language) |

# ជំពូកទី១

## ១.សេចក្ដីផ្ដើម

### ១.១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ដែលគេបានបង្ហាញពីតំបន់វប្បធម៌ និងវប្បធម៌ភាសាតាមតំបន់។ ដោយឡែកប្រទេសឥណ្ឌូណេស៊ី ប្រើប្រាស់ភាសាច្រើនជាង៧០០ទូទាំងប្រទេសរបស់ខ្លួន។ ដោយមានស្ថានភាពចម្រុះទាំងនេះ ប្រទេសទាំង១០នៃអាស៊ានបានចុះហត្ថលេខាលើធម្មនុញ្ញអាស៊ាននាពេលថ្មីៗនេះទៅលើគោលនយោបាយអប់រំនៃភាសាតំបន់ និង ពិចារណាពីផលប៉ះពាល់នៃគោលនយោបាយទាំងនេះសម្រាប់ថែរក្សាភាពខុសគ្នារបស់ភាសា វប្បធម៌ និងការលើកកម្ពស់ភាសាអង់គ្លេស និងភាសាជាតិរៀងៗខ្លួន (Kirkpatrick, A.,and Liddicoat, A., 2017)។

ដោយមើលឃើញពីសារៈសំខាន់នៃការប្រើប្រាស់ភាសាអង់គ្លេស គេសង្កេតឃើញថាមានសាលាភាសាអង់គ្លេសឯកជនរីកដុះដាលយ៉ាងច្រើននៅទូទាំងប្រទេសកម្ពុជា ជាពិសេសនៅក្នុងរាជធានីភ្នំពេញ និងនៅខេត្តកណ្ដាលរហូតដល់មានសាលាមួយចំនួនជ្រើសយកភាសាអង់គ្លេសជាយាន សម្រាប់បង្រៀនចំណេះដឹងទូទៅ ទៅលើគ្រប់មុខវិជ្ជាទាំងអស់ថែមទៀតផង។ ក្នុងនោះមានសាលាអន្តរជាតិចំនួន៣នៅរាជធានីភ្នំពេញ បានអនុវត្តតាមកម្មវិធីសិក្សាចំណេះទូទៅនរបស់ក្រសួងអប់រំយុវជន និងកីឡា និងជ្រើសយកការបង្រៀនគ្រប់មុខវិជ្ជាជាភាសាអង់គ្លេស។ ហើយមានសាលាអន្តរជាតិចំនួន ៧ទៀតដែលអនុវត្តកម្មវិធីសិក្សាបរទេស ដោយយកភាសាអង់គ្លេសជាយាន (ក្រសួងអប់រំយុវជននិងកីឡា, ២០១៧) ។ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការរៀន និងបង្រៀនភាសាអង់គ្លេស តាមរយៈការកែប្រែកម្មវិធីសិក្សាភាសាអង់គ្លេសនៅតាមសាលារដ្ឋ ដោយឱ្យសិស្សចាប់ផ្ដើមរៀនភាសានេះតាំងពីថ្នាក់ទី៤ នៅបឋមសិក្សា (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)ហើយក្រសួងក៏បានធ្វើការកែប្រែសៀវភៅសិក្សាគោលភាសាអង់គ្លេសផងដែរ (Tweed, A. D., & Som, M.,NarinHeng, 2018)។

តម្រូវការចាំបាច់មួយដែលត្រូវការប្រើភាសាសកលមួយ ដែលជាមូលដ្ឋានគ្រឹះក្នុងការទំនាក់ទំនង ដើម្បីសម្រួលដល់ការប្រកបរបរនិងការរស់នៅប្រចាំថ្ងៃ។ ភាសាអង់គ្លេស បានបំពេញសេចក្ដីត្រូវការ របស់អ្នកប្រើប្រាស់ មិនតែប៉ុណ្ណោះភាសាអង់គ្លេសមានសារៈសំខាន់សម្រាប់ការទំនាក់ទំនងផ្លូវការ ទំនាក់ទំនងការទូត ជំនួញជួញដូរ ពាណិជ្ជកម្ម ទីផ្សារការងារបានប្រាក់ចំណូលកាន់តែប្រសើរជាងមុន។ ប្រទេសមួយចំនួននៅក្នុងអាស៊ាន ប្រើប្រាស់សាកលវិទ្យាល័យមួយចំនួនផ្ដល់ការអប់រំ ជាភាសាអង់គ្លេស ហើយបោះពុម្ពផ្សាយព័ត៌មានមួយចំនួនធំជាភាសាអង់គ្លេសផងដែរ។ ភាសាអង់គ្លេសជាភាសាបរទេសមួយដែលមានសារៈសំខាន់ក្នុងវិធីសិក្សា បឋមសិក្សាទុតិយ មធ្យមសិក្សាទុតិយភូមិ ក៏ដូចជា ថ្នាក់ឧត្ដមសិក្សាផងដែរក្នុងការសិក្សាភាសាអង់គ្លេស ដែលបានបែងចែកជាបួនជំនាញ ដូចជា ជំនាញអាន ជំនាញសរសេរ ជំនាញស្ដាប់ និង ជំនាញនិយាយ។ នៅឆ្នាំ២០០០ ច្រើនជាង១០០០នាក់នៃសិស្សបើគិតជាមធ្យមក្នុងចំណោមសិស្ស២៤០០០នាក់ នៅសាលារដ្ឋ និងសាលាឯកជននៅគ្រឹះស្ថានឧត្ដមសិក្សា ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រភាសាអង់គ្លេស ខណៈពេលដែលសិស្សត្រឹមតែ២៥០នាក់រៀនភាសាបារាំង(Sun Somama, 2014;Ahrens & Kemmerer, 2002; Moeys, 2005) នាពេលបច្ចុប្បន្នភាសាអង់គ្លេសត្រូវបានប្រើជាភាសាសំខាន់ក្នុងការទំនាក់ទំនងការទូតរបស់កម្ពុជា ជាមួយប្រទេសដទៃទៀត។

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ

សមត្ថភាពស្ដាប់មានបញ្ហាប្រឈមចំពោះអ្នករៀនភាសាអង់គ្លេស ដែលមានការលំបាកជាច្រើនដែលម្នាក់ៗអាចប្រឈម ក្នុងការស្វែងយល់ការនិយាយ ការបង្រៀន ឬការសន្ទនាជាភាសាទីពីរ (ហើយពេលខ្លះសូម្បីតែភាសាដំបូងរបស់ពួកគេ)។ អ្នកនិយាយ ស្ថានភាព និងអ្នកស្ដាប់អាចជាបុព្វហេតុនៃការលំបាកទាំងនេះ។ សមត្ថភាពស្ដាប់ គឺជាជំនាញដែលមានមូលនិធិច្រើនបំផុតនៅក្នុងការរៀនសូត្រភាសា ប៉ុន្តែអស់រយៈពេលជាច្រើនទសវត្សរ៍ ជំនាញនេះមិនត្រូវបានគេទទួលស្គាល់ទេ។ តាមរយៈលោក Ekrem solak & Renandya, 2010 សមត្ថភាពស្ដាប់ ទទួលបានពីការយកចិត្តទុកដាក់ក្នុងការរៀន និង បង្រៀនភាសាបរទេស ពីព្រោះវិធីសាស្ត្របង្រៀនសង្កត់ធ្ងន់លើ Productime Skills និង ជំនាញស្ដាប់ ត្រូវបានគេចាត់ទុកជាអសកម្ម (Solak, April 2016)។ បើតាមការសិក្សាស្រាវជ្រាវរបស់លោក (Renukadevi,

2014) ការស្តាប់ គឺជាជំនាញមួយដែលគេធ្វេសប្រហេសក្នុងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅក្នុងប្រទេសបង់ក្លាដេស តាមរយៈការរៀនភាសាអង់គ្លេស១២ឆ្នាំ សិស្សមិនអាចបង្ហាញការស្តាប់អង់គ្លេសបាននៅថ្នាក់រៀន។ នៅពេលដែលសិស្សរៀនអក្សរសាស្ត្រអង់គ្លេសនៅសាកលវិទ្យាល័យ ពួកគេមានជំនាញស្តាប់ក្នុងវគ្គសិក្សា ដើម្បីរៀបចំអោយពួកគេយល់ពីអក្សរសាស្ត្រ និងការពិភាក្សាជាភាសាអង់គ្លេស។ ការលើកឡើងទាំងនេះជាបញ្ហាប្រឈម សំរាប់គ្រូបង្រៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់។

ក្នុងការសិក្សារបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ មានការធ្វេសប្រហែសមិនបានយកចិត្តទុកដាក់លើមុខវិជ្ជាភាសាអង់គ្លេសដែលមានជំនាញទាំងបួនដូចជា អាន សរសេរ ស្តាប់ និង និយាយ។ សិស្សថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មិនបានផ្តល់សារសំខាន់ទៅលើមុខវិជ្ជាភាសាអង់គ្លេស ពិសេសគឺជំនាញសមត្ថភាពស្តាប់ ដែលមិនបានដាក់បញ្ចូលក្នុងវិញ្ញាសាភាសាបរទេសក្នុងការប្រឡងសញ្ញាបត្រទុតិយភូមិ។ ចំពោះកម្មវិធីសិក្សាមុខវិជ្ជា ភាសាអង់គ្លេស ទាំងសិស្សថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានម៉ោងសិក្សាភាសាអង់គ្លេសសរុប ៧៦ម៉ោង ក្នុងរយៈពេលសរុប ៣៨សប្តាហ៍សម្រាប់ឆមាសទី១និងទី២ ចំពោះថ្នាក់ទី១១ និងថ្នាក់ទី១២ មានម៉ោងសិក្សាចំនួន២ម៉ោងក្នុងមួយសប្តាហ៍ ប្រើសៀវភៅសិក្សាគោល English For Cambodia book 5 សម្រាប់ថ្នាក់ទី១១ និង English For Cambodia book 6 សម្រាប់ថ្នាក់ទី១២ ដែលមាន១៣ជំពូកនិង៣៦មេរៀន(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។ ដោយកត្តាពេលវេលាមានត្រឹមតែ២ម៉ោងក្នុងមួយសប្តាហ៍ និង១ម៉ោងសិក្សាមាន៥០នាទី ធ្វើអោយការរៀននិងបង្រៀនភាសាអង់គ្លេសមានបញ្ហាប្រឈម ក្នុងការអនុវត្តន៍ទៅលើជំនាញទាំងបួន ជាពិសេសជំនាញស្តាប់ដែលទាមទារការប្រើប្រាស់សម្ភារឧបទ្ទេស ដូចជា បន្ទប់សោតទស្សន៍ ម៉ាញ៉េកាសែត ការសែតសម្លេងថាសសម្លេង CD VCDសម្រាប់មើលវីដេអូ។ ជាក់ស្តែងប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ការផ្គត់ផ្គង់សម្ភារឧបទសក្នុងការរៀននិងបង្រៀនភាសាបរទេស ពុំមានលក្ខណៈទំនើបទាំងស្រុង ទៅតាមស្ថានភាពជាក់ស្តែងនៃសាលារដ្ឋដែលមានទីតាំងជាយក្រុង តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល។ ចំនែកសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ១១ និងទី១២ ពុំទាន់ធ្វើការផ្លាស់ប្តូរ នៅបន្តប្រើសៀវភៅ English For Cambodia book 4, 5 &6 (EFC) ផលិតឆ្នាំ២០០១។

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

ដោយសារមានចម្ងល់ពាក់ព័ន្ធទៅនឹងគុណភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសនៅសាលារដ្ឋក៏ដូចជាការជួបបញ្ហាប្រឈមនៃដំណើរការបង្រៀន និងរៀនលើសមត្ថភាពស្ដាប់ភាសាអង់គ្លេស នៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិនាពេលបច្ចុប្បន្ននេះ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តជ្រើសរើសបញ្ហានេះមកធ្វើជាប្រធានបទស្រាវជ្រាវ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់អ្នកស្រាវជ្រាវ។ ការសិក្សានេះមានគោលបំណងពីរដូចខាងក្រោម៖

- សិក្សាពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនសមត្ថភាពស្ដាប់ទៅលើមុខវិជ្ជាភាសាអង់គ្លេស។
- សិក្សាពីបញ្ហាប្រឈមនានានៅក្នុងការបង្រៀន និងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ អ្នកសិក្សាស្រាវជ្រាវបានលើកយកនូវសំណួរស្រាវជ្រាវចំនួនពីរមានដូចជា៖

១.តើគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស ដើម្បីបង្កើនការស្ដាប់ភាសាអង់គ្លេសបានកម្រិតណា ?

២.តើការបង្រៀននិងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិជួបបញ្ហាប្រឈមអ្វីខ្លះ ?

## ១.៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវខាងលើប្រធានបទស្ដីពី បញ្ហាប្រឈមនៃការរៀន និងបង្រៀនលើសមត្ថភាពស្ដាប់ភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិដែលសាលារដ្ឋ នៅក្នុងរាជធានីភ្នំពេញដូចតទៅ៖

- យល់ដឹងពីបំណិនស្តាប់ជាភាសាអង់គ្លេស និងការសម្រេចរបស់គ្រូ ថាតើគាត់ជ្រើសរើសមេរៀន បំណិន ស្តាប់ ភាសាអង់គ្លេសបង្រៀននិងវិធីសាស្ត្របង្រៀនក្នុងថ្នាក់រៀន។

- យល់ដឹងពីយុទ្ធសាស្ត្ររៀនសមត្ថភាពស្តាប់ជាភាសាអង់គ្លេសរបស់សិស្ស ដែលអាចក្លាយជាធនធានមនុស្សចូលរួមចំណែកជួយកែលម្អពីផលអវិជ្ជមាន ឱ្យមានភាពប្រសើរឡើង ដល់ចំណេះដឹងដល់ការសិក្សាភាសាបរទេសរបស់សិស្ស។ បន្ថែមពីនេះ ដើម្បីលើកកម្ពស់ដល់ការទំនាក់ទំនងរបស់ពួកគាត់ក្នុងការប្រកួតប្រជែង ឱកាសការងារ និងជំនាញក្នុងជីវិតការងារ ដើម្បីឱ្យការសិក្សាមានភាពប្រសើរឡើង នៅពេលគេទៅបន្តការសិក្សានៅឧត្តមសិក្សារឺក្រៅប្រទេសនិងសម្រេចគោលដៅ។

## ១.៦.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ នឹងធ្វើទៅលើវិទ្យាល័យចំនួន៧ក្នុងខណ្ឌ៦នៅក្នុងរាជធានីភ្នំពេញ ដែលជាវិទ្យាល័យគោលដៅរួមមាន (១)ខណ្ឌជ្រោយចង្វា៖ សាលាគោលដៅមានមួយគឺវិទ្យាល័យព្រែកលៀប (២)ខណ្ឌឫស្សីកែវ៖ សាលាគោលដៅមានពីរគឺ វិទ្យាល័យឫស្សីកែវ និងវិទ្យាល័យជាស៊ីមចំរើនរដ្ឋ (៣)ខណ្ឌចំការមន៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យទួលទំពូង(៤)ខណ្ឌ៧មករា៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យបាក់ទូក (៥) ខណ្ឌព្រែកព្នៅ៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យសម្តេចមហាសេនាបតីតេជោហ៊ុន សែនសំរោង (៦)ខណ្ឌមានជ័យ៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យចម្រើនផល។ គណៈគ្រប់គ្រងសាលារៀន មាននាយក នាយិកា-នាយករង នាយិការងចំនួន ១៣នាក់ លោកគ្រូ-អ្នកគ្រូដែលជាបុគ្គលិកបង្រៀន មុខវិជ្ជាភាសាអង់គ្លេសចំនួន ២០នាក់ ដោយមួយវិទ្យាល័យជ្រើសរើសសិស្សចំនួន ៣០នាក់ សរុបសិស្សទាំងអស់ចំនួន១៩០នាក់ ដោយសិស្សមួយវិទ្យាល័យមានសិស្សថ្នាក់ទី១០ចំនួន ១០នាក់ និងទី១១ ចំនួន ១០នាក់ និងសិស្សទី១២ចំនួន ១០នាក់ ត្រូវបំពេញកម្រងសំណួរបិទ និងសំណួរបើកសម្រាប់ទទួលបានព័ត៌មានបន្ថែមពីសំណួរមួយចំនួន ដែលបានបំពេញលើកម្រងសំណួរដែលរៀបចំឡើងដោយអ្នកស្រាវជ្រាវ។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗ៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃកិច្ចការស្រាវជ្រាវ សំណួរស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាលើប្រធានបទ បញ្ហាប្រឈមនៃរៀន និងបង្រៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេស នៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។

**ជំពូកទី២៖** ការរំឭកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ បានប្រមូលទ្រឹស្តីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ដើម្បីជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ សៀវភៅកម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណ៍ណែនាំ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើជាទុនសម្រាប់ស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។

**ជំពូកទី៣៖** វិធីសាស្ត្រនៃការស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូ និងប្រភេទគំរូព្រមទាំងវិធីសាស្ត្រក្នុងការស្រាវជ្រាវ ការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖** លទ្ធផលនិងការពិភាក្សា នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អនិងចំណុចត្រូវកែលម្អក្នុងការរៀន និងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសជាក់ស្តែងរបស់សាលានីមួយៗ នៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរនៅក្នុងជំពូកនេះជាផ្នែកមួយ ដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួន

ក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សអោយកាន់តែល្អប្រសើរជាងមុន។

# ជំពូកទី២

## ការរំឭកទ្រឹស្តី

ការសិក្សាស្រាវជ្រាវនេះ ធ្វើការស្ទាបស្ទង់នៃការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេស ជាផ្នែកមួយដ៏សំខាន់ក្នុងការស្រាវជ្រាវ ដែលទាក់ទងនឹងបញ្ហាប្រឈមនានាលើការបង្រៀន និងរៀនលើសមត្ថភាពស្តាប់ដោយប្រើវិធីសាស្រ្តបង្រៀន និងការសម្រេចចិត្តលើការជ្រើសរើសអត្ថបទមេរៀនស្តាប់ក្នុងថ្នាក់រៀនរួមទាំងការប្រើប្រាស់សម្ភារឧបទេសបង្រៀន។ មិនត្រឹមតែចង់ដឹងពីវិធីសាស្រ្តបង្រៀននិងរៀនថាតើគ្រូបង្រៀន និងភាគីពាក់ព័ន្ធជួបបញ្ហាប្រឈមអ្វីខ្លះដោយផ្អែកលើការស្រាវជ្រាវមុនៗ ដែលទាក់ទងជាមួយសៀវភៅនិក្ខេបបទ ការសិក្សាស្រាវជាវ របាយការណ៍ ព័ត៌មាននានា ដែលមានទំនាក់ទំនងនឹងការរៀន និងបង្រៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេស ព្រមទាំងមធ្យោបាយក្នុងការដោះស្រាយបញ្ហាទាំងនោះផងដែរ។

ការសិក្សារស្រាវជ្រាវនេះ មិនត្រឹមតែផ្តោតទៅលើការសិក្សាសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងសិក្សាផ្តោតលើវិធីសាស្រ្តក្នុងការបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់គ្រូកម្រិតឧត្តមនៃវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញផងដែរ។ ប្រធានបទនេះមាននិយមន័យមួយចំនួន ដើម្បីយកមកបកស្រាយពន្យល់ពាក្យទាំងនោះរួមមាន៖ រៀន និងបង្រៀនសមត្ថភាពស្តាប់ ប្រភេទស្តាប់ វិធីសាស្រ្តស្តាប់។

## ២.១.និយមន័យ

### ២.១.១.សមត្ថភាពស្តាប់

នៅក្នុងភាសាបរទេសមានបំណិនចំនួនបួនដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ដែលបែងចែកវិធីសាស្រ្ត២យ៉ាងក្នុងការទំនាក់ទំនង *ការទំនាក់ទំនងផ្ទាល់* និង *និតិវិធីនៃការទំនាក់ទំនង* ផ្សេងៗទៀត (*ការសរសេរ* ឬ *ការនិយាយ*)។នៅក្នុងបំណិនភាសាបរទេស ដែលមាន «Input» (លទ្ធផល) គឺជាអ្វីដែលហៅថាការទទួល និង « Output» ដែលហៅថាផលិតកម្មក ។ **ការនិយាយ** ត្រូវបានគេស្គាល់ថា **ការ**

**និយាយផ្ទាល់មាត់**។ នៅក្នុងបំណិនទាំងបួន មានបំណិនអាន បំណិនស្តាប់ បំណិនសរសេរ និង បំណិននិយាយ ដែលគេអាចហៅថា Micro Skills នៅក្នុង Micro Skills មាន វេយ្យាករណ៍ ការបញ្ចេញសម្លេង ការប្រកបពាក្យ ។ល។ (chauhan, 2015)។

ការស្តាប់ជាការដំណើរការក្នុងការប្រាស្រ័យទាក់ទងគ្នាយ៉ាងសកម្ម វាត្រូវបង្ហាញដូចខាងក្រោម៖

| |
|---|
| (Input………..processig…………..Output) |
| (ធាតុចូល ដំណើរការ ធាតុចេញ) |

**ធាតុចូល** មានន័យថា ពាក្យដែលនិយាយដោយអ្នកនិយាយ។

**ធាតុចេញ** មានន័យថា ការឆ្លើយតបរបស់អ្នកស្តាប់ដំណើរការនៃការបញ្ចូលធាតុចូល និងធាតុចេញជាលទ្ធផល។ យោងតាមលោក Chauhan 2015 បានបង្ហាញថាធាតុចូលមានដំណើរការដូចខាងក្រោម៖

Bottom-up-procesing អ្នកស្តាប់ពឹងផ្អែកទៅលើការទទួលចូលប៉ុណ្ណោះ ធាតុចូលនៃអត្ថន័យនៃសារ។

Top down processing អ្នកស្តាប់ពឹងផ្អែកលើចំណេះដឹងរបស់ពួកគេស្រាប់ សម្រាប់ការយល់សារ ហេតុដូចនេះ ធាតុចូលមិនត្រឹមតែជាប្រភពនៃអត្ថន័យតែប៉ុណ្ណោះទេ (chauhan, 2015)។

## ២.១.២.ប្រភេទនៃការស្តាប់

**ការស្តាប់មាន៦ប្រភេទដូចខាងក្រោម៖**

**១ ការស្តាប់សកម្ម** (Active Listening) ការស្តាប់សកម្មគឺជាបច្ចេកទេសនៃការប្រាស្រ័យទាក់ទងដែលត្រូវការអ្នកស្តាប់ផ្តល់ព័ត៌មាន ត្រឡប់មកវិញ ដោយនិយាយឡើងវិញ ឬនិយាយរៀបឃ្លាឡើងវិញ ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ស្តាប់ដើម្បីបញ្ជាក់ការយល់របស់ភាគីទាំងពីរក្នុងការប្រាស្រ័យទាក់ទង។ នៅក្នុងការស្តាប់សកម្ម មិនត្រឹមតែវាសំដៅលើតែពាក្យសម្តីប៉ុណ្ណោះទេ វារួមបញ្ចូលទាំងភាសាកាយវិការ និងផ្តោតលើអ្វីផ្សេងៗទៀត។ ការស្តាប់សកម្មមានពីរប្រភេទ ការស្តាប់ជាមួយសំណួរចម្លើយ

Listening Conprehension និងការស្តាប់ដោយមានគោលបំណង Listening with a purpose (chauhan, 2015)។

**២ ការស្តាប់ដោយចិត្ត** Empathic Listening ជាការស្តាប់មួយដោយយកចិត្តទុកដាក់ និងផ្តល់ភាពជឿជាក់ដល់អ្នកស្តាប់ ដែលចង់បង្ហាញពីអារម្មណ៍របស់អ្នកនិយាយ។

**៣ ការស្តាប់ដោយត្រិះរិះពិចារណា** Critical Listening ជាវិធីសាស្ត្រមួយក្នុងចំណោម វិធីសាស្ត្រស្តាប់អាចជួយយើងដោយហ្វឹកហាត់ជំនាញស្តាប់ជាអ្នកគិតត្រិះរិះពិចារណា និងយើងអាច បែងចែកបួនប្រភេទនៃការស្តាប់។

**៤ ការស្តាប់ធម្មតា** Casual Listening ជាការស្តាប់ពីនរណាម្នាក់ រឺអ្វីមួយដោយគ្មានគោលបំណងជាក់លាក់ នៅពេលដែលអ្នកស្តាប់មិនសូវចាប់អារម្មណ៍ ហើយអ្នកស្តាប់យកចិត្តទុកដាក់ទៅលើចំណុចដែលទាក់ទាញអារម្មណ៍។ ការស្តាប់បែបធម្មតា ជារឿយៗតែងកើតឡើងនៅពេលធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងបរិបទសង្គម។

**៥ ការស្តាប់ដោយផ្តោតអារម្មណ៍** Focused Listening វាជាការស្តាប់ដោយយកចិត្តទុកដាក់ខ្លាំង (Intensive Listening) សម្រាប់ស្តាប់ រឺ ប្រតិបត្តិជំនួញ នោះអ្នកស្តាប់យកចិត្តទុកដាក់ និងផ្តោតលើអ្វីដែលអ្នកកំពុងនិយាយ។

## ២.១.៣.ជំហានក្នុងការបង្រៀនសមត្ថភាពស្តាប់

តាមរយៈលោក Ekrem Solak និង Vandergrift បានលើកឡើងថាការរៀននិងបង្រៀន សមត្ថភាពស្តាប់មានសារៈសំខាន់ ដើម្បីជួយដល់សិស្សក្នុងការពង្រឹងចំណេះដឹងពុទ្ធិ (Solak, April 2016)។ ការស្តាប់បែងចែកជាបីដំណាក់កាលមានដូចជា ការត្រៀមស្តាប់ (Pre-Listening) ខណៈពេលស្តាប់ (While-listening) និងក្រោយពេលស្តាប់ (Post-listening)។ ក្នុងដំណាក់កាលទាំងបីនេះ ខណៈពេលស្តាប់(While-listening)ការឆ្លើយតបទៅនឹងប្រធានបទដែលពួកគេបានស្តាប់។

**ការត្រៀមស្តាប់** (Pre-listenig) ជាសកម្មភាពដែលជួយដល់សិស្សត្រៀមនឹងស្តាប់ ជួយអោយតម្រុយអំពីសកម្មភាពដែលបានរំពឹងទុក។ គ្រូត្រូវទាញអារម្មណ៍ និងអាកប្បកិរិយារបស់សិស្សដើម្បីស្តាប់ ផ្តល់ចំណេះដឹងទូទៅដែលទាក់ទងនឹងអត្ថបទស្តាប់ មិនតែប៉ុណ្ណោះគ្រូត្រូវផ្តល់ហេតុផលដល់សិស្ស ថាតើហេតុអ្វីត្រូវស្តាប់អត្ថបទស្តាប់នេះ។ សិស្សព្យាយាមទាយ និងស្មានលើអត្ថបទ តាមរយៈរូបភាព តម្រុយ ការបំផុសលើការស្តាប់។

**ខណៈពេលស្តាប់** (While-listening) សំដៅទៅលើពេលវេលានៃការស្តាប់ក្នុងថ្នាក់ដោយប្រើសម្ភារៈបង្រៀន ដែលគ្រូភាគច្រើនចាក់ការសែតសម្រាប់សិស្ស។ ក្នុងកំឡុងពេលស្តាប់ គ្រូប្រើសកម្មភាពមួយចំនួនជួយលើកទឹកចិត្ត ផ្តល់តម្រុយដល់សិស្សដូចជា (ពាក្យ ប្រើពាក្យកាត ក្តារខៀន)។

**ក្រោយពេលស្តាប់** (Post-listening) នៅក្នុងជំហាននេះផ្តល់ឱកាសដល់សិស្សទទួលព័ត៌មាន និងជាសកម្មភាពដែលលើកទឹកចិត្តសិស្ស។ ក្នុងដំណើរការក្រោយពេលស្តាប់ មាន សំណួរដែលមានចម្លើយមានច្រើនជម្រើស (Multiple choices) សំណួរ ពិត/មិនពិត(True False questions) សំណួរចម្លើយ ដើម្បីឆ្លុះបញ្ចាំងការយល់របស់សិស្ស រីឯការកែកំហុសសិស្ស គ្រូត្រូវទុកមួយឡែក។សិស្សផ្លាស់ប្តូរចំនុចពិបាកក្នុងការស្តាប់ទៅវិញទៅមក បន្ទាប់មកគ្រូដាក់កិច្ចការដល់សិស្សដូចជា ការតស៊ូមតិ ការពិភាក្សាក្រុម ការដើរតួសម្តែង ដើម្បីអនុវត្តការនិយាយ ក៏ដូចជាការសរសេរផងដែរ។

## ២.២.វិធីសាស្រ្តបង្រៀនសម្ថតភាពស្តាប់

វិធីសាស្រ្តបង្រៀន គឺជាសមាសធាតុមួយដ៏សំខាន់ ដើម្បីអនុវត្តគោលដៅនៃការអប់រំនៅក្នុងដំណើរការនៃការបង្រៀននិងរៀនជាពិសេសនោះថ្នាក់រៀនជាភាសាអង់គ្លេស (Natsir, 2014, p.58)។ ដើម្បីឱ្យការបង្រៀននិងការរៀនទទួលបានជោគជ័យវាទាមទារឱ្យគ្រូបង្រៀនមានគុណវុឌ្ឍិគ្រប់គ្រាន់ និងវិធីសាស្រ្តបង្រៀនច្បាស់លាស់ ដែលមានលក្ខណៈបត់បែនទៅតាមស្ថានភាពថ្នាក់រៀនសម្រាប់បង្រៀនសិស្ស។ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងធ្វើការងារជាច្រើនដើម្បីលើកកម្ពស់គុណវឌ្ឍន៍របស់គ្រូ

បង្រៀនតាមរយៈ ការបណ្តុះបណ្តាលបុគ្គលិកបង្រៀនរៀងរាល់ឆ្នាំទៅលើវិធីសាស្រ្តបង្រៀនថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនរបស់សង្គមនាពេលបច្ចុប្បន្ន។

### ២.២.១.វិធីសាស្រ្តបង្រៀនសមត្ថភាពស្តាប់ដោយចាក់សម្លេង (The Audio Lingual Method)

លោក Brown, (2000) បានបង្ហាញគោលការមួយចំនួនដែលទាក់ទងទៅនឹងវិធីសាស្រ្ត(ALM) មានដូចខាងក្រោម៖

១.ខ្លឹមសារថ្មីៗត្រូវបានបង្ហាញនៅក្នុងទម្រង់សន្ទនា

២.ផ្តោតលើការចងចាំជាប្រយោគ

៣.សំណង់ប្រយោគមានភាពទាក់ទងគ្នាជាមួយខ្លឹមសារផ្សេងៗ ត្រូវបានបង្រៀនក្នុងពេលតែមួយ

៤. សំណង់ប្រយោគសំខាន់ៗ ត្រូវបាននង្រៀនតាមរយៈការហ្វឹកហាត់ថាតាម

៥.អាចមាន រឺមិនមានការពន្យល់វេយ្យាករណ៍តិចតួច ក្រោយពីពន្យល់រួចបង្កើតជាទ្រឹស្តី

៦.ស្រង់ពាក្យថ្មី ពីអត្ថបទតែមួយគត់

៧.ប្រើប្រាស់កាសែតសម្រាប់ស្តាប់

៨.ផ្តោតសំខាន់លើការបញ្ចេញសម្លេង

៩.ការប្រើប្រាស់ភាសាដើមកំណើតតិចតួចបំផុត ទាល់តែគ្រូអនុញ្ញាត

១០.ចម្លើយដែលត្រឹមត្រូវបានយកមកអនុវត្តភ្លាមៗ

១១.គ្រូជួយសិស្សប្រើប្រាស់ការបញ្ចេញសម្លេងដោយគ្មានកំហុស

១២.មាននិន្នាការទាញយកផលប្រយោជន៍ពីភាសាហើយខ្វល់ពីខ្លឹមសារ។

នៅក្នុងវិធីសាស្រ្ត(ALM) ផ្តោតលើឃ្លាជាជាងខ្លឹមសារមេរៀនលើសពីនេះទៅទៀតចាំបាច់ត្រូវការចងចាំឃ្លាសំខាន់ៗ ផ្អែកលើការសន្ទនាផងដែរ។ (Sothy, 2019)

### ២.២.២.វិធីសាស្ត្របង្រៀនដោយការចាក់ភ្លេង(Suggestopedia)

វិធីសាស្ត្របង្រៀនដោយការចាក់ភ្លេង(Suggestopedia) គឺជាវិធីសាស្ត្រមួយដែលគួរអោយចាប់អារម្មណ៍ត្រូវបានយកមករៀន តាមរយៈសិល្បនៃការរស់នៅ ដែលមានសារប្រយោជន៍សម្រាប់សោតទស្សន៍ (Shikare, 2017)។

**លក្ខណៈមួយចំនួនរបស់វិធីសាស្ត្របង្រៀនដោយការចាក់ភ្លេង (Suggestopedia)**

- **បរិស្ថានថ្នាក់មានផាសុកភាព** គឺជាការរៀបចំថ្នាក់រៀនកាន់តែងាយស្រួល និងមានផាសុកភាពដល់សិស្សានុសិស្ស។ កៅអី រឺកៅអីអង្គុយ ត្រូវបានរៀបចំជាពាក់កណ្ដាលរង្វង់ហើយប្រឈមមុខនឹងក្ដារខៀនធ្វើឱ្យសិស្សមានភាពធូរស្រាល និងអាចយកចិត្តទុកដាក់ជាងមុន។

- **ការប្រើប្រាស់តន្ត្រី** ការប្រើប្រាស់តន្ត្រី Baroque កំឡុងពេលសិក្សា ដែលមានកម្លាំងសម្លេង ៦០ប៊ីតក្នុង១វិនាទីនិងចង្វាក់ជាក់លាក់របស់វា ដែលជួយបន្ធូរអារម្មណ៍ដោយស្វ័យប្រវត្តិកាត់បន្ថយនៃកម្រិតសម្ពាធឈាម និងចង្វាក់បេះដូងអោយមានភាពងាយស្រួលនិងផាសុកភាព។

- **ការរៀនសើរៗខាងក្រៅ** សិស្សរៀនភាសាអង់គ្លេសមិនត្រឹមតែរៀនដោយផ្ទាល់ពីការណែនាំរបស់គ្រូបង្រៀន និងថែមទាំងទទួលការបង្ហាញដោយប្រយោលទៀតផង។ ទាំងនេះបានជំរុញនិងលើកទឹកចិត្តសិស្សតាមរយៈ ការប្រើប្រាស់សម្ភារឧបទ្ទេសសម្រាប់រៀនស្ដាប់។ សម្ភារឧបទេសសម្រាប់ស្ដាប់មានដូចជាផ្ទាំងរូបភាព ពណ្ណប្រកាស ការតុបតែងថ្នាក់ ក្រដាសផ្ទាំងធំៗ ដែលទាក់ទងនឹងវាក្យស័ព្ទ វេយ្យាករណ៍ផ្សេងៗដែលគេអាចយកមកផ្លាស់ប្ដូររាល់ថ្ងៃ។

- **មិនផ្ដោតលើកំហុស** ការព្យាយាមឆ្លើយតបនិងសកម្មភាពរបស់សិស្ស ក្នុងម៉ោងសិក្សាសិស្សតែងតែបង្កើតកំហុស ប៉ុន្តែត្រូវបានលើកលែងពីការចាប់កំហុសរបស់គ្រូ ដើម្បីអោយសិស្សមានចំណាប់អារម្មណ៍ធ្វើសកម្មភាពក្នុងថ្នាក់ដោយសប្បាយរីករាយ។

- **ការដាក់កិច្ចការផ្ទះមានកំណត់** គ្រូដាក់កិច្ចការផ្ទះអោយសិស្សដែលអាចអានរំលឹកឡើងវិញនៅពេលព្រឹក និងមានភាពងាយស្រួលទាំងអារម្មណ៍ និងកាយវិការតាមអ្វីដែលពួកគេចូលចិត្ត។
- **ការបញ្ចូលតន្ត្រី ល្ខោន សាច់រឿង និងសិល្បៈ** គ្រូគួរតែបញ្ចូលការមើលវីដេអូ ចម្រៀង ភាសាអង់គ្លេស រឿងនិយាយភាសាអង់គ្លេស ដែលជួយជំរុញអោយសិស្សមានចំណាប់អារម្មណ៍លើមេរៀនទាក់ទងនឹងមេរៀន។

**សកម្មភាពគ្រូក្នុងវិធីសាស្ត្របង្រៀនដោយការចាក់ភ្លេង(Suggestopedia)**

- មានភាពជឿជាក់លើខ្លួនឯងក្នុង Suggestopedia
- គ្រូត្រូវរៀបចំសម្ភារឧបទេសទៅតាមដំណើរការបង្រៀន Suggestopedia បញ្ចូលទាំងការចាក់ភ្លេង
- រក្សាអោយបានអត្តចរិតច្បាស់លាស់ក្នុងម៉ោងសិក្សា
- បង្កើតតេស្ត និងជួយសិស្សមានកម្រិតក្រោមមធ្យម
- សង្កត់ធ្ងន់ជាលក្ខណៈសកលជាជាងធ្វើការវិភាគលើតែការសិក្សានៃសម្ភារឧបទ្ទេសដែលរៀននោះទេ
- រក្សាភាពរីករាយក្នុងថ្នាក់រៀន

វិធីសាស្ត្របង្រៀនដោយការចាក់ភ្លេងពិតជាគួរឱ្យចាប់អារម្មណ៍សម្រាប់លោកគ្រូ-អ្នកគ្រូ ដែលបង្រៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់ វាផ្តល់គុណប្រយោជន៍ដល់សិស្សបង្កើនចំណេះដឹងពុទ្ធិ និងមានអារម្មណ៍ងាយស្រួលអាចបន្ធូរអារម្មណ៍ក្នុងថ្នាក់ (Shikare, 2017)។

## ២.២.៣.វិធីសាស្ត្រស្តាប់ដោយយល់ (Comprehensive Listening)

យោងតាមលោក Stephenនិង Lucas (1998) បានស្តែងថា " ស្តាប់ដោយយល់ គឺជាស្តាប់ដោយលះបង់ការយល់ទាំងស្រុងទៅលើអត្ថន័យខ្លឹមសាររបស់អ្នកនិយាយ ខណៈពេលយើងចូលរួមការបង្រៀនរបស់គ្រូ" (ទំព័រ៥៨) (chauhan, 2015)។

## ២.២.៤.ការបង្រៀនភាសាបែបទំនាក់ទំនង (Communicative Langauge Teaching)

វិធីសាស្ត្រនេះ មានការពេញនិយមប្រើប្រាស់យ៉ាងសកម្មក្នុងការបង្រៀននិងរៀនភាសាបរទេស។ ក្នុងការ បង្រៀនតាមបែបCLT គ្រូបង្រៀនខ្លឹមសារមេរៀនដោយប្រើភាសាដើមកំណើត តែក្នុងការទំនាក់ទំនងនៅថ្នាក់រៀន មិនអនុញ្ញាតអោយប្រើភាសាដើមកំនើតនោះទេ។ គ្រូព្យាយាមបង្រៀនពាក្យថ្មី ពន្យល់ពាក្យថ្មីទាំងនោះ សិស្សប្រាប់នូវអ្វីដែលពួកគេបានដឹង។ រីឯចំនុចវេយ្យាករណ៍ដែលគ្រូយកមកបង្រៀនដោយការពន្យល់ជាភាសាដើមកំនើត អោយសិស្សងាយយល់និងព្យាយាមទាញអារម្មណ៍សិស្សផ្តោតទៅលើខ្លឹមសារមេរៀនក្នុងអត្ថបទវិញ។ វិធីសាស្ត្រCLT បង្រៀនទាំងបួនជំនាញមាន ជំនាញអាន ជំនាញស្តាប់ ជំនាញសរសេរ និងជំនាញនិយាយ។ ក្នុងចំនោមជំនាញទាំងបួននេះ ប្រើការទំនាក់ទំនង លើការពិភាក្សា ការងារជាគូ ការងារជាក្រុម រឺសកម្មភាពក្នុងថ្នាក់ (Iv, 2019)។

## ២.២.៥.វិធីសាស្ត្របកប្រែ (The Grammar Translation Method)

វីធីសាស្ត្របង្រៀនតាមបែបបកប្រែគឺ ជាវិធីសាស្ត្រមួយដែលត្រូវបានគេប្រើប្រាស់ចាប់តាំងពីសតវត្សទី១៩មកម្ល៉េះ។ វិធីសាស្ត្រនេះមានប្រជាប្រិយបំផុតក្នុងចំណោមវិធីសាស្ត្រដទៃទៀត និងមានលក្ខណៈខុសគ្នាដាច់ពីវិធីសាស្ត្របង្រៀនបែបទំនាក់ទំនង(CLT) ដោយវាបានបង្រៀនឱ្យសិស្សចេះវិភាគភាសា ជួយឱ្យសិស្សក្នុងការអានអក្សរសិល្ប៍ ជាជាងឱ្យសិស្សប្រើភាសា។ វិធីសាស្ត្របង្រៀនតាមបែបបកប្រែ ១.បង្រៀនដោយប្រើប្រាស់ភាសាកំណើត(L1)។ ២.បង្រៀនពាក្យដោយបកប្រែទៅជាភាសាកំណើត។ ៣.សិស្សត្រូវយល់ពីវេយ្យាករណ៍មុននឹងអាចសរសេរឃ្លាប្រយោគបាន។ ៤.សម្ភារឧបទ្ទេសត្រូវបានផលិតដោយគ្រូ ដូចនេះសិស្សមិនមានភាពស៊ាំទៅនឹងសម្ភារៈទាំងនោះទេ។ ៥.សិស្សមិនត្រូវបានគេបង្ខំឱ្យប្រើប្រាស់ភាសាទីពីរក្នុងទំនាក់ទំនងទេ។ នៅក្នុងវិធីសាស្ត្រនេះគ្រូគឺជាធនធានសំខាន់នៅក្នុងថ្នាក់ ចំណែកសិស្សយកអ្វីដែលគ្រូដាក់ឱ្យ( គ្រូមជ្ឈមណ្ឌល) ហើយអាចសួរគ្រូបាន នៅពេលដែល ពួកគេមិនយល់តែប៉ុណ្ណោះ (Sanjaya, 2014)។ តាមលោក Natsir & Sanjaya (2014) ដដែលបានលើកឡើងថា ការបង្រៀនភាសាមានជំនាញបួនសំខាន់គឺ ជំនាញអាន ជំនាញស្តាប់ ជំនាញនិយាយ និងជំនាញសរសេរ។ ក្នុងវិធីសាស្ត្រ(GTM) បង្រៀនសង្កត់ធ្ងន់តែទៅលើពីរជំនាញប៉ុណ្ណោះ គឺជំនាញអាន និងជំនាញសរសេរ

ដែលជំនាញទាំងពីរនេះធ្វើឱ្យសិស្សផ្តោតទៅលើពាក្យ និងវេយ្យាករណ៍ ដោយមិន ផ្តោតទៅលើអ្វីផ្សេងនោះទេ ពោលគឺបង្រៀនសិស្សឱ្យចេះពីក្បួនច្បាប់នៃភាសាទីពីរ ហើយមិនយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ រហូតមកដល់ពេលនេះវិធីសាស្ត្រមួយនេះគឺមិនឆ្លើយតបទៅនឹង បរិបទសង្គមទេ។ ដូច្នេះ វិធីសាស្ត្រ(GTM) ជាវិធីមួយដែលមិនសមស្របសម្រាប់ការបង្រៀន និងរៀនភាសាទីពីរនោះទេ ទោះបីជាគ្រូបានបង្ហាញពីកំហុសរបស់សិស្សហើយកែនូវរាល់កំហុសទាំងនោះក៏ដោយ តែវាអាចជះឥទ្ធិពលដល់សិស្សអាចធ្វើឱ្យពួកគាត់បាត់បង់នូវទំនុកចិត្ត ហើយមិនហ៊ានប្រើប្រាស់ភាសា (Mart, 2013)។ តាមលោក Brown, (2000) បានបង្ហាញពីចរិតលក្ខណៈរបស់(GTM)ដូចខាងក្រោម៖

១. សិស្សទាំងអស់ត្រូវបានគេបង្រៀនជាភាសាទីមួយ (L1)។

២.ពាក្យថ្មីជាច្រើនត្រូវបានគេបង្រៀនក្នុងពេលតែមួយ និងជាពាក្យដាច់ពីគ្នាដោយមិនបានដាក់ជាឧទាហរណ៍ដើម្បីជួយឱ្យសិស្សចងចាំជាប្រចាំ និងចេះប្រើប្រាស់ពាក្យ ឃ្លាទាំងនោះ ឬជំរុញឱ្យសិស្សធ្វើដោយខ្លួនឯងនោះទេ។

៣.ប្រើពេលវេលាច្រើនក្នុងការពន្យល់វេយ្យាករណ៍។

៤.ក្បួនច្បាប់វេយ្យាករណ៍ត្រូវបានគេផ្តល់ឱ្យដោយគ្រាន់តែដាក់ពាក្យចូលគ្នា។

៥.ការអានអត្ថបទពិបាកចាប់ផ្តើមមុនការរៀន។

៦.មានការផ្តោតយកចិត្តទុកដាក់តិចតួចទៅលើខ្លឹមសារនៃអត្ថបទ តែផ្តោតទៅលើការវិភាគវេយ្យាករណ៍ច្រើន។

៧.ហ្វឹកហាត់ទៅលើលំហាត់ក្នុងការបកប្រែប្រយោគ ដែលមិនទាក់ទងគ្នាពីខ្លឹមសារមេរៀនទៅជាភាសាទីពីរ។

៨.មិនផ្តោត ឬផ្តោតអារម្មណ៍តិចតួចទៅលើការបញ្ចេញសម្លេង។

វិធីសាស្ត្រ (GTM) មិនអាចជួយសិស្សឱ្យប្រសើរឡើងក្នុងការប្រើប្រាស់ភាសាក្នុងការទំនាក់ទំនងទេ Brown(2000)។ មូលហេតុដែល (GTM) នៅតែមានគេយកមកប្រើប្រាស់ដោយសារតែការធ្វើតេស្ត

វេយ្យាករណ៍ និងការបកប្រែងាយស្រួលក្នុងការបង្កើត និងងាយស្រួលក្នុងការដាក់ពិន្ទុ វាយតម្លៃលើការសិក្សារបស់សិស្សផងដែរ (Iv, 2019)។

### ២.២.៦.ការបង្រៀនដោយផ្ទាល់ (The Direct Method)

ការអភិវឌ្ឍភាសាត្រូវបានដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការសិក្សាភាសាបរទេស។ ភាពស្ទាត់ជំនាញក្នុងការនិយាយ ត្រូវបានគេពិចារណាទៅលើគោលដៅនៃការរៀនភាសាបរទេសផងដែរ។ មានសេចក្តីសិន្នដ្ឋានមួយថា ភាសាដែលត្រូវបានរៀនបានល្អបំផុតនោះគឺនៅពេលដែលសិស្សទាំងអស់ប្រើប្រាស់វាយ៉ាងសកម្មនៅក្នុងថ្នាក់រៀន។ វិធីសាស្ត្រផ្ទាល់ (Direct Method) ត្រូវបានគេទទួលស្គាល់ថាជាវិធីសាស្ត្រធម្មជាតិ ឬវិធីសាស្ត្រសន្ទនាមានប្រជាប្រិយភាព នៅពេលដែលវាអាចធ្វើឱ្យសិស្សានុសិស្សអាចមានទំនាក់ទំនងគ្នាបាន ដោយប្រើប្រាស់ភាសាទីពីរដែលពួកគេកំពុងតែរៀន។ វិធីសាស្ត្រផ្ទាល់បានផ្តោតសំខាន់ទៅលើការប្រើប្រាស់ភាសាប្រចាំថ្ងៃ ការប្រើប្រាស់សំណួរនិងចម្លើយដែលសង្កត់ធ្ងន់ទៅលើខ្លឹមសារមេរៀននៅក្នុងការបង្រៀនភាសានិយាយ ( Mart, 2013)។ វិធីសាស្ត្រផ្ទាល់ត្រូវបានគេប្រើដើម្បីឱ្យមានទំនាក់ទំនងគ្នារវាង អត្ថន័យ និងខ្លឹមសារមេរៀនរបស់វានៅក្នុងថ្នាក់រៀនជៀសវាងមិនឱ្យប្រើប្រាស់ជាភាសាទីមួយរបស់ខ្លួននិងការបកប្រែពីភាសាទីមួយទៅភាសាទីពីរ ដែលនាំឱ្យសិស្សឈានទៅរកភាពស្ទាត់ជំនាញហើយគេប្រើជាមធ្យោបាយណែនាំ ឬទំនាក់ទំនង។ លោក Brown(2000) បានបង្ហាញពីគោលការណ៍នៃវិធីសាស្ត្រផ្ទាល់ដូចខាងក្រោម៖

១. ខ្លឹមសារមេរៀនត្រូវបានគេយកមកប្រើណែនាំក្នុងថ្នាក់រៀន។

២. ជ្រើសរើសយកពាក្យ និងឃ្លាប្រើប្រាស់ប្រចាំថ្ងៃមកបង្រៀន។

៣.ជំនាញក្នុងការទំនាក់ទំនងផ្ទាល់ត្រូវបានគេបង្កើតឡើងតាមរយៈ ការពិភាក្សាក្រុម គ្រូនិងសិស្ស។

៤. វេយ្យាករណ៍ត្រូវបានបង្រៀនតាមរបៀបពន្យល់រួចទាញជាទ្រឹស្តី។

៦. ពាក្យថ្មីត្រូវបានបង្រៀនតាមរយៈរូបភាព ការពន្យល់ ឬវត្ថុផ្សេងៗ។

៧.សមត្ថភាពនិយាយ និងស្តាប់ត្រូវបានគេបង្រៀន។

៨.សង្កត់ធ្ងន់ទៅលើការបញ្ចេញសម្លេងត្រឹមត្រូវ និងវេយ្យាករណ៍។

វិធីសាស្ត្រផ្ទាល់មិនមានដំណើរការល្អទេ នៅក្នុងការអប់រំសាធារណៈព្រោះវាត្រូវការចំណាយលុយ ពេលវេលា និងចំណេះដឹងគ្រូធ្វើឱ្យវិធីសាស្ត្រនេះពិបាកប្រើលោក Brown(2000)។

## ២.២.៧.ចំនុចត្រូវពង្រឹងក្នុងសមត្ថភាពស្ដាប់

- ត្រៀមទាំងផ្លូវកាយនិងផ្លូវចិត្តពេលស្ដាប់ក្នុងថ្នាក់។
- ត្រូវធ្វើខ្លួនជាអ្នកស្ដាប់ដ៏ល្អដូចដែលអ្នកបានគិត។
- ផ្ដោតទៅលើឋាមពលផ្លូវចិត្តក៏ដូចជាផ្លូវកាយចំពោះការស្ដាប់។
- ជៀសវាងការរំខានដល់អ្នកនិយាយក្នុងថ្នាក់។
- ទស្សនៈរបស់អ្នកត្រូវចេះបត់បែន។
- អនុវត្តការស្ដាប់លើធនធានដូចជាការស្ដាប់និទានកថាដែលពិបាកតិចទៅច្រើន។
- បង្កើនទំលាប់ស្ដាប់ពីការស្ដាប់ដែលងាយស្រួលទៅពិបាក (Solak, April 2016)។

យោងតាម លោក William បានបង្ហាញថាការប្រាស្រ័យទាក់ទងល្អធ្វើឱ្យមានការទំនាក់ទំនងល្អ (Doverspike, 2006)។ ដើម្បីពង្រឹងចំណេះបន្ថែមលើបំណិនស្ដាប់ភាសាអង់គ្លេស ឱ្យកាន់តែប្រសើរមាន ចំណុចសំខាន់ៗគួរអនុវត្តដូចខាងក្រោម៖

- កំណត់ការនិយាយរបស់អ្នក( ស្ដាប់ឱ្យបាន៩៩% និងនិយាយត្រឹមតែ១% ដើម្បីមានទំនាក់ទំនងល្អ)
- គិតឱ្យមានគំនិតដូចអ្នកកំពុងនិយាយ (អ្នកនឹងយល់ពីគំនិតអ្នកនិយាយច្រើនជាងមុន)
- ត្រូវចេះសួរសំណួរបញ្ជាក់បន្ថែម( បើអ្នកមិនយល់រឺមិនច្បាស់ គួរសួរបញ្ជាក់ម្ដងទៀត)
- កុំរំខាន ឬប្ដូរប្រធានបទ បើទោះជាអ្នកនិយាយ ផ្អាកបន្តិច រឺ មួយសន្ទុះ មិនប្រាកដថាគេអស់យោបល់ រឺឈប់និយាយនោះទេ
- កាត់បន្ថយការព្រួយបារម្ភពេលកំពុងស្ដាប់
- ធ្វើការកត់ត្រាទុក

- ស្តាប់ដើម្បីទទួលយកគំនិត មិនមែនស្តាប់យកតែពាក្យពេចន៍នោះទេប្រើការបញ្ជាក់ដោយឆ្លើយតបថា ខ្ញុំយល់ ទៅកាន់អ្នកស្តាប់
- ត្រៀមរៀបចំទុកជាមុន
- ប្រតិកម្មជាមួយគំនិត មិនមែនជាមួយបុគ្គលទេ
- កុំឈ្លោះសប្រកែកដោយអារម្មណ៍
- កុំឆាប់បូកសរុបមតិលឿនពេក។

### ២.២.៨.បញ្ហានៃការស្តាប់(Problem of listening Skills)

តាមរយៈលោក(Brown & Yule 1983b)បានបង្ហាញថាមានកត្តា៤ ដែលឱ្យជាកត្តាជះឥទ្ធិពលលើការស្តាប់ កង្វះការស្តាប់ផ្ទាល់៖

- ផ្អែកទៅលើអ្នកនិយាយ(មានចំនួនប៉ុន្មាន និយាយលឿនប៉ុណ្ណា ប្រើតុងនិយាយអ្វី)
- អ្នកស្តាប់(តួនាទីអ្នកស្តាប់ អ្នកចូលរួមស្តាប់ ឬក៏ លបស្តាប់) គោលបំណងនៃការតម្រូវការស្តាប់ការចាប់អារម្មណ៍លើប្រធានបទតែម្ខាងទេ។
- អត្ថន័យ ខ្លឹមសារ (វេយ្យាករណ៍, វាក្យស័ព្ទ, ព័ត៌មាន, ប្រវត្តិចំណេះដឹង)
- Support ការគាំទ្រ(បើទោះជាមានរូបភាព, បាឆាតឬសម្លេងជំនួយការគាំទ្រអត្ថបទ) (Brown & Yule (1983b)។

**តើអ្វីជាទម្លាប់អាក្រក់នៃការស្តាប់**

- ហៅអត្ថបទជាមុខវិទ្យាមិនគួរអោយចាប់អារម្មណ៍
- រិះគន់ការចែករំលែករបស់អ្នកនិយាយ
- ទទួលការរំញោចជ្រុលដោយចំណុចមួយចំនួននៅក្នុងសុន្ទរកថា
- អត់ធ្មត់ឬបង្កើតការរំខាន
- បណ្តោយទៅតាមអារម្មណ៍ការបញ្ចេញសម្តីបោះរបស់អ្នកនិយាយ

មិនតែប៉ុណ្ណោះ មានបញ្ហាមួយចំនួនអ្នកស្រាវជ្រាវបានបង្ហាញក្នុងនេះតាមរយៈអ្នកស្រាវជ្រាវមុនៗ ក្នុងចំណោមបញ្ហាទាំងនោះមានដូចជា ករណីទីមួយទាក់ទងទៅនឹងអ្នកស្តាប់ភាគច្រើនធ្វេសប្រហែស មិនបានយកចិត្តទុកដាក់ចំពោះការស្តាប់អត្ថន័យទាំងស្រុងក្នុងអំឡុងពេលស្តាប់(chauhan, 2015)។ ទន្ទឹមនឹងនោះការរៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេសមើលទៅហាក់ដូចជាមានការងាយស្រួល តែផ្ទុយទៅវិញពេលកំពុងស្តាប់ ការទទួលបានព័តមានពីអត្ថបទស្តាប់មិនបានច្បាស់លាស់ រឺទទេស្អាត។ លោកគ្រូ-អ្នកគ្រូដែលបានយកអត្ថបទស្តាប់កមបង្រៀនក្នុងថ្នាក់រៀន ក៏ជួបបញ្ហាស្រដៀងគ្នា នឹងការលើកឡើងនេះផងដែរ (chauhan, 2015)។

*សិស្សជាច្រើនមានការពិបាកធ្វើតាមការណែនាំរបស់លោកគ្រូ អ្នកគ្រូ កាន់តែធ្វើអោយមានឱនភាពក្នុងការចូលរួម និងយកចិត្តទុកដាក់ ដូចជាសិស្សខ្លះ មិនអាចសម្របខ្លួនបានសមស្របទៅនឹង ផលរំខាន ផ្សេងៗក្នុងថ្នាក់រៀន។*

ដោយឡែកលោក Anderson និង Lynch (1988)បានអះអាងថា ការរំខាននៅក្នុងថ្នាក់រៀនក្នុងអំឡុងពេលរៀននិងបង្រៀន វាបណ្តាលមកពីស្ថានភាពកម្រិតនៃការយកចិត្តទុកដាក់របស់សិស្សលើធាតុចូល Input " សិស្សអាចបិទការយកចិត្តទុកដាក់លើការស្តាប់ ដោយដឹងខ្លួន រឺមិនដឹងខ្លួន" ក្នុងដំណើរការស្តាប់។ បន្ថែមពីករណីនេះ កង្វះខាតចំណេះដឹងទូទៅពីមុន និងជំនាញលើសមត្ថភាពស្តាប់ លោក Anderson និង Lynch (1988)បានស្តែងថា "*ចន្លោះប្រហោងនៃចំណេះដឹងរបស់យើងអំពីវប្បធម៌ភាសាទី ២ របស់សមាគមន៍ និងឯកសារយោងនានាអាចប្រើប្រាស់បានសម្រាប់ជនជាតិដើម និងអាចយកមកកំណត់បង្ហាញឧបសគ្គនៃការយល់ដឹងក្នុងការទំនាក់ទំនងរវាងអ្នកនិយាយ និងអ្នកស្តាប់។*"

**២.២.៨.១.បញ្ហាប្រឈមរបស់គ្រូបង្រៀន**

យោងតាម (Alderson &Wall, 1993) គ្រូមួយចំនួនមានភាពភ័យខ្លាច និងការមានកំហុសបន្តិចបន្តួចរបស់ខ្លួនការអៀនខ្មាស់ ព្រមទាំងលទ្ធផលខ្សោយរបស់សិស្ស ជាកត្តាលំបាករបស់គ្រូ។ លើសពីនេះទៅទៀត ការអនុវត្តរបស់សិស្សដើម្បីទទួលបានលទ្ធផលជាផ្លែផ្កា ក្នុងការប្រលងឬធ្វើតេស្តជាសារធារណៈ

រីថ្នាក់ជាតិ ដែលអាចអោយគ្រូបង្រៀនភាសាអង់គ្លេសយកចិត្តទុកលើផ្នែក ដែលមានក្នុងតេស្តតែប៉ុណ្ណោះ។ ចំនែកឯលោក Brirjandi et al.,2006 បានរកឃើញបញ្ហាប្រឈមដែលគ្រូនៅប្រទេសអ៊ីរ៉ាក់ មានការធ្វេសប្រហែសមិនបានយកចិត្តទុកដាក់បង្រៀនលើបំណិនស្តាប់ក្នុងកម្មវិធីសិក្សា ភាគច្រើនមានទំនោរខ្លាំងលើការបង្រៀនបំណិនអំនានក្នុងចំណោមបំណិនទាំងបួន (Zahra, 2015)។

### ២.២.៨.២.បញ្ហារបស់សិស្ស

ការលើកឡើងរបស់(Oxford 2001) បានបញ្ជាក់ថា បញ្ហាប្រឈមរបស់គ្រូបង្រៀនគឺជាការមានជំនឿរបស់សិស្សលើការរៀនភាសាអង់គ្លេសចាត់ទុកជាមុខវិជ្ជាមួយដែលមាន ពាក្យ វេយ្យាករណ៍ ចាំបាច់ត្រូវ ទន្ទេញចាំ ឬបែងចែកជំនាញអោយដាក់លាក់មានដូចជា ជំនាញបញ្ចូលគ្នា និង ជំនាញបន្ទាប់បន្សំ។ (Akbari, 2015) ក្នុងស្ថានដែនោះដែរ គ្រូជួបបញ្ហាប្រឈមពាក់ព័ន្ធនឹងខ្លឹមសារអត្ថបទមេរៀននៃការរៀនភាសាអង់គ្លេសខ្ពស់ជាងកម្រិតយល់ដឹងរបស់ពួកគេ។ សិស្សនៅអ៊ីរ៉ាក់មានចំណេះដឹងកម្រិតខ្សោយ អាចនឹងបាក់ទឹកចិត្តក្នុងការរៀនសូត្រ និងអានទស្សនាវដ្ដី ការសែត រឺអត្ថបទយកការជាភាសាអង់គ្លេស។ មិនតែប៉ុណ្ណោះ ចំណេះដឹងរបស់សិស្ស មានកម្រិតទៅតាមតំបន់ដែលពួកគេទទួលការសិក្សាអប់រំដូចជា តំបន់ទីប្រជុំជន តំបន់ជាយក្រុង តំបន់ដាច់ស្រយាល។

## ២.២.៩.សម្ភារឧបទ្ទេសសម្រាប់បង្រៀនការស្តាប់

យោងតាមការស្រាវជ្រាវរបស់លោក Richard (2005)បានផ្តល់យោបល់ថាសម្ភារឧបទ្ទេសសំរាប់ការបង្រៀននិងរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសផ្អែកលើអត្ថបទមានអត្ថន័យពិតប្រាកដ ទូលំទូលាយឱ្យសមស្របនឹងបរិបទនៃភាសាទាំងពីរ រួមបញ្ចូលទាំងការសន្ទនារបស់អត្ថបទ (Solak, April 2016)។ លោកគ្រូ-អ្នកគ្រូត្រូវសម្រេចចិត្តជ្រើសរើសអត្ថបទស្តាប់មកបង្រៀនក្នុងថ្នាក់រៀន ដែលមានសិស្សមានកម្រិតចំណេះដឹងភាសាអង់គ្លេសមិនស្មើគ្នា ដើម្បីសមស្របនឹងបរិស្ថានថ្នាក់រៀននិងសមត្ថភាពភាសារបស់សិស្សអោយមានការចាប់អារម្មណ៍លើសមត្ថភាពភាសាអង់គ្លេស ដែលជាភាសាទីពីរ (Solak, April 2016)។ សម្ភារឧបទ្ទេស ដែលអាចយកមកបង្រៀនក្នុងថ្នាក់រៀនភាសាបរទេស មានដូចជា ការនិយាយរបស់លោកគ្រូ-អ្នកគ្រូ ការនិយាយរបស់សិស្ស ការទាយអ្នកនិយាយ សៀវភៅអត្ថបទស្តាប់ ទូរទស្សន៍

វីដេអូ DVD វិទ្យុ ចំរៀង និង អ៊ីនធើណេត។ ជាក់ស្តែងនៅប្រទេសកម្ពុជាកម្មវិធីសិក្សាលើសៀវភៅសិក្សាគោលនៃភាសាអង់គ្លេសសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិ នៅបន្តប្រើប្រាស់សៀវភៅ English For Cambodia Book 4,5&6 បើទោះបីជាមិនទាន់មានការសិក្សាជាច្រើនទាក់ទងនឹង ការវាយតម្លៃលើសៀវភៅភាសាអង់គ្លេសសម្រាប់កម្ពុជា នៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិ (EssaysUk, November 2018)។

តាមរយៈការសិក្សាស្រាវជ្រាវរបស់លោក សុខសុវណ្ណមករា បញ្ជាក់ថាបរិបទបច្ចុប្បន្នភាពនៃការសិក្សាលើអត្ថបទស្តាប់ចាំបាច់អ្នករៀនត្រូវមានចំណេះដឹង វប្បធម៌ សិល្បៈការរស់នៅថ្មីៗ ដែលមានសារប្រយោជន៍សម្រាប់អភិវឌ្ឍន៍សមត្ថភាពអន្តរវប្បធម៌ (Solak, April 2016) ការប្រើប្រាស់សម្ភារឧបទេសដែលអាចយកមកអនុវត្តនៅក្នុងថ្នាក់រៀន ដើម្បីជួយសម្រួលក្នុងការយល់ដឹងនិងការពង្រឹងចំណេះដឹង ពុទ្ធិដល់សិស្សក្នុងការពិចារណានិងយកមកអនុវត្តការស្តាប់ភាសាអង់គ្លេស។ ទាក់ទងនឹងសំភារឧបទ្ទេស ជាផ្នែកមួយជួយដល់លោកគ្រូ អ្នកគ្រូជ្រើសរើសវិធីសាស្រ្តបង្រៀនលើសមត្ថភាពស្តាប់ តាម រយៈការឆ្លើយសំណួរលើ ការសន្ទនា ការពិពណ៌នា ក្រោយពីបានស្តាប់ហើយ នោះអ្នកនិងចាប់បានការឆ្លើយតបការបញ្ចេញគំនិតយោបល់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់សិស្សដែលបានយល់បន្ទាប់ពីស្តាប់។ វិធីសាស្រ្តទាំងនេះពិតជាជួយក្នុងការបង្រៀនអោយកាន់តែបានលទ្ធផលប្រសើរជាងមុន ដែលលោកគ្រូ អ្នកគ្រូ រំពឹងទុកក្នុងគោលដៅមេរៀនក្នុងកិច្ចតែងការរបស់គាត់។ តាមទ្រឹស្តីរបស់លោក Brakash S.chauhan សម្ភារៈបង្រៀន និងរៀនចែកចេញជាបីប្រភេទសំខាន់ៗ ដែលអាចយកមកប្រើប្រាស់សម្រាប់មេរៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់ភាសាអង់គ្លេស ខណៈពេលកំពុងបង្រៀនសិស្សនៅក្នុងថ្នាក់រៀន (chauhan, 2015)។

សម្ភារៈបង្រៀននិងរៀនចែកចេញជាបីប្រភេទសំខាន់ៗមានដូចក្នុងតារាងខាងក្រោមៈ

| ប្រភេទសម្ភារៈ | សារប្រយោជន៍ | មិនមានសារប្រយោជន៍ |
|---|---|---|
| **សម្ភារៈស្តាប់ដែលត្រឹមត្រូវ** **Authentic listening materials** | • ស្តាប់ពីមេរៀនជីវិតពិត<br>• មានការប្រកួតប្រជែងពីអ្នករៀនមុនៗ<br>• វាមិនមែនជាភាសាអង់គ្លេសសិប្បនិម្មិត | • មិនអាចជាថ្នាក់<br>• ពិបាកពេកសម្រាប់កម្រិតសិស្សវិទ្យាល័យ<br>• ការនិយាយវាអាចច្រើនពេក |
| **អាត់សម្លេង Recorded** | • អ្នករៀនអាចឈប់ឆ្លើយតប<br>• អ្នករៀនអាចរៀនខ្លួនឯងដោយឯករាជ<br>• សម្លេង និង លើកដាក់សម្លេងមានច្រើន<br>• អ្នករៀនយកចិត្តទុកដាក់ស្តាប់ | • ការនិយាយវាអាចច្រើនពេក<br>• បញ្ហាបច្ចេកទេសអាចកើតឡើង<br>• គុណភាពនៃការចាក់ការសែត |
| **បន្តផ្ទាល់ Live** | • គ្រូអាចចាក់កាសែតទៅតាមកម្រិតរបស់សិស្ស។<br>• គ្រូអាចធ្វើ បន្ថយល្បឿនយឺត រឺ ភាពដែលអាច ទទួលយកបាន។ | • មិនអាចធ្វើឡើងវិញ |

## ២.៣.សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស

ភាសាអង់គ្លេសជាតម្រូវការចាំបាច់មួយដែលត្រូវបានគេប្រើវាជាភាសាសកល មិនតែប៉ុណ្ណោះវាជាមូលដ្ឋានគ្រឹះក្នុងការទំនាក់ទំនងដើម្បីជួយសម្រួលដល់ការរស់នៅប្រចាំថ្ងៃ។ ភាសាអង់គ្លេសត្រូវបានបំពេញសេចក្តី ត្រូវការនិងការប្រើប្រាស់សម្រាប់ជំនួញជួញដូរ មិនតែប៉ុណ្ណោះភាសាអង់គ្លេសមានសារៈសំខាន់សំរាប់ទំនាក់ទំនងឱកាសការងារ សម្រាប់រកចំណូលឱ្យកាន់តែប្រសើរ។ ប្រទេសមួយចំនួនក្នុងអាស៊ានប្រើប្រាស់ភាសាអង់គ្លេសមានភាពងាយស្រួល និង ធ្លាប់ជាប់ជាអាណានិគមនិយមអង់គ្លេស

និងអាមេរិក។ ជាអកុសលកម្ពុជាងាកមកប្រើប្រាស់ភាសាអង់គ្លេសចុងឆ្នាំ១៩៨៩ និង ការប្រើប្រាស់មានភាពយឺតយាវបន្តិច។ កម្ពុជាខិតខំប្រឹងប្រែងពង្រឹងភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព និង មានសមាជិកដែលជាធនធានមនុស្សផ្នែកភាសា អង់គ្លេសឱ្យកាន់តែទូលំទូលាយ ទៅតាមធនធាន ក៏ដូចជាតាមទីប្រជុំខេត្ត និងជនបទនានា (UK Totoring Service, 2020)។ យោងតាមលោក Rost (1991) បានសង្ខេបសេចក្តីនៃសារៈសំខាន់ការស្តាប់ភាសាអង់គ្លេសជាភាសាទីពីរមានដូចជា៖

១.ការស្តាប់មានសារៈសំខាន់នៅក្នុងថ្នាក់រៀនភាសាបរទេសពីព្រោះវាផ្តល់គំនិតដល់អ្នករៀន។ បើគ្មានការយល់ពីគំនិតដែលផ្តល់ឱ្យទៅតាមកម្រិតត្រឹមត្រូវនោះអ្នករៀននឹងមិនអាចចាប់បានដោយងាយ។

២.ការនិយាយភាសាជាក់លាក់មួយបង្ហាញពីបញ្ហាប្រឈមសម្រាប់អ្នករៀន ដើម្បីយល់ពីអ្នកនិយាយភាសាដើមកំណើត។

៣.លំហាត់ស្តាប់មិនបានផ្តល់ភាពចាំបាច់សម្រាប់ទាក់ទាញការយកចិត្តទុកដាក់របស់សិស្ស ឱ្យទៅជាទម្រង់ផ្សេងៗដូចជា (ពាក្យ វេយ្យាករណ៍ ឃ្លាវាក្យស័ព្ទ)នៅក្នុងភាសាបរទេស។ (Cheung, Yun Kul, 08-2010)។

សារប្រយោជន៍នៃការរៀនសមត្ថភាពស្តាប់ ទាំងគ្រូនិងសិស្សភាគច្រើនបរាជ័យក្នុងការយកចិត្តទុកដាក់ស្តាប់។ ទាំងនេះអាចកត់សំគាល់ថា អ្នករៀនជាញឹកញាប់និយាយថាការស្តាប់គឺជាបញ្ហាប្រឈមក្នុងចំនោមបំណិនផ្សេងក្នុងភាសាអង់គ្លេស (British council)

- ការស្តាប់ជួយឱ្យអ្នកអាចនិយាយបានល្អ។
- ការស្តាប់ផ្តល់ឱ្យមាននូវការទំនាក់ទំនងភាសា។

ការស្តាប់ដើរតួសំខាន់ក្នុងការត្រិះរិះពិចារណា ដែលបង្ហាញរូបរាងនៃលទ្ធផល និងពង្រឹងការនិយាយដោយផ្ទាល់ឱ្យកាន់តែមានប្រសិទ្ធភាព។ តាមរយៈលោក Rubin (1995)"សម្រាប់ភាសាទីពីរ រឺអ្នករៀនភាសាទីពីរ បំណិនស្តាប់ជាដំណើរការពិបាកដែលត្រូវប្រឹងប្រែងពីព្រោះអ្នករៀនត្រូវតែមាន ការផ្តុកក្នុងការចងចាំរយៈពេលខ្លី ស្របពេលដែលពួកគេត្រូវធ្វើការស្វែងយល់ពីព័ត៌មាននោះ។ (Cheung, Yun Kul, 08-2010)។

### ២.៣.២ ការប្រឡងស្តង់ដារអន្តរជាតិ

បំណិនស្តាប់ត្រូវបានដាក់ក្នុងការប្រឡងស្តង់ដារអន្តរជាតិដូចជា IBC , TOEFL , ILTS ដោយសម្រាប់ការប្រឡងដាក់អាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស។ មិនតែប៉ុណ្ណោះការសិក្សានៅក្រៅប្រទេសចាំបាច់មានពិន្ទុ TOEFL (Test of English fo Language) ឬ IELT(Interatronal English Language Test system)ជាប់ក្នុងស្តង់ដារតាមប្រទេស។ នៅក្នុងវិញ្ញាសាប្រឡង TOEFLឬ IELT មានបួនជំនាញ ស្តាប់ អាន សរសេរ និង និយាយ។

នៅក្នុងវិញ្ញាសា TOEFL (Test of English fo Language) នៅចុងឆ្នាំ២០០៥ TOEFL Internet-based test (IBT) ក្លាយជា CBT (Computer based Test) និង Paper-based-test អាល្លឺម៉ង់ និង អ៊ីតាលី ក្នុងឆ្នាំ ២០០៥ និង ប្រទេសដទៃទៀតក្នុងឆ្នាំ២០០៦។ ការប្រឡងTOEFL មានវិញ្ញាសាបំណិនស្តាប់រយៈពេល 41-57mintes ដែលមាន ៥-៧ pasage មាន៥-៦ សំណួរ ។ (contributors, 2020)

រីឯការប្រឡងIELTS (Interatronal English Language Test system): មាន4 សន្លឹកកិច្ចការ Listening Skills មាន៤០សំណួរមានរយៈពេល៣០នាទី បំណិនអាន ៤០សំណួរ ៦០នាទី បំណិនសរសេរ ចំនួន ៦០នាទី និងបំណិននិយាយមាន ៣ផ្នែក មានរយៈពេល ១១ទៅ១៤នាទី។ជនៅក្នុងសន្លឹកកិច្ចការប្រលងលើបំណិនស្តាប់ Listening Skills paper មាន៤ផ្នែក៖ ក្នុង១ផ្នែកមាន១០សំណួរ ដែលមានលំដាប់លំដោយព័ត៌មាននៅក្នុងអត្ថបទស្តាប់។ ដូច្នេះបេក្ខជនត្រូវឆ្លើយសំណួរទី១មុននឹងឆ្លើយសំណួរទី២បន្តបន្ទាប់។

## ២.៤.កម្មវិធីសិក្សាលម្អិតមធ្យមសិក្សាទុតិយភូមិ

សារៈសំខាន់នៃភាសាអង់គ្លេសនាសម័យសាលកលូបនីយកម្ម បានជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសជាច្រើននៅលើសកលលោក ងាកមកផ្តោតលើការយកចិត្តទុកដាក់លើកម្មវិធីអប់រំភាសាបរទេសមួយនេះ។ ជាក់ស្តែងនៅកម្ពុជា ភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលជាផ្លូវការនៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិចាប់ពីកម្រិតថ្នាក់ទី៤រហូតដល់ថ្នាក់ទី១២។ (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)

រយៈម៉ោងសិក្សា

រយៈម៉ោងសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវបានបែងចែកដូចជា៖

| ថ្នាក់ទី | ម៉ោងសិក្សា |
|---|---|
| ១០ | ១សប្តាហ៍ សិក្សា ៤ ម៉ោង (៤ម៉ោង* ៣៥ សប្តាហ៍ = ១៤០ ម៉ោង / ១ឆ្នាំសិក្សា) |
| ១១ | ១សប្តាហ៍ សិក្សា ៤ ម៉ោង (៤ម៉ោង* ៣៥ សប្តាហ៍ = ១៤០ ម៉ោង / ១ឆ្នាំសិក្សា) |
| ១២ | ១សប្តាហ៍ សិក្សា ៤ ម៉ោង (៤ម៉ោង* ៣៥ សប្តាហ៍ = ១៤០ ម៉ោង / ១ឆ្នាំសិក្សា) |

| ល.រ | លក្ខណៈពិសេស | ការពិពណ៌នា |
|---|---|---|
| ១ | ចំនួនសប្តាហ៍ក្នុង១ឆ្នាំ | ៣៥សប្តាហ៍ |
| ២ | ចំនួនម៉ោងក្នុង១ឆ្នាំ | ១៤០ម៉ោង |
| ៣ | ចំនួនម៉ោងក្នុង១សប្តាហ៍ | ៤ម៉ោង |
| ៤ | ចំនួនជំពូកក្នុង១កម្រិតថ្នាក់ | ថ្នាក់ទី១០មាន១១ជំពូក ដោយក្នុង១ជំពូកមាន៣ មេរៀន |
| | | ថ្នាក់ទី១១មាន១១ជំពូក ដោយក្នុង១ជំពូកមាន៣ មេរៀន |
| | | ថ្នាក់ទី១០២មាន១១ជំពូក ដោយក្នុង១ជំពូកមាន៣ មេរៀន |
| ៥ | ចំនួនម៉ោងក្នុង១មេរៀន | ៤ ម៉ោង (សម្រាប់ថ្នាក់ទី ១០, ១១ និងទី១២) |
| ៦ | លទ្ធផលរំពឹងទុក | (១) ការស្តាប់ (២) ការនិយាយ (៣) ការអាន (៤) ការសរសេរ (បូកថែមវេយ្យាករណ៍ និង ពាក្យស័ព្ទ) |
| ៧ | តម្លៃនៃការសិក្សា | ចំណេះសម្បទា បំណិនសម្បទា និងចរិយាសម្បទា |

ដើម្បីសម្រេចគោលបំណងនិងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិទទួលបានជោគជ័យគ្រូបង្រៀនត្រូវ៖

ក. បំណែងចែកកម្មវិធីសិក្សានិងកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមគោលការណែនាំ និងមានសកម្មភាពច្បាស់លាស់តាមមេរៀននីមួយៗ។

ខ. រៀបចំមេរៀនឱ្យទាក់ទាងគ្នា រំលឹកឡើងវិញ វាយតម្លៃដើម្បីបំពេញចំណុចខ្វះខាតរបស់សិស្ស។ គ្រូត្រូវសួរសំណួរបំផុស រួចសំយោគចម្លើយពីសិស្សមកវិញ។

គ. រៀបចំសកម្មភាពបង្រៀន និងរៀនស្របតាមកម្មវិធីសិក្សា លទ្ធផលសិក្សា និងបរិស្ថានសិក្សា។ ក្នុងការរៀបចំកិច្ចតែងការបង្រៀនត្រូវគោរពប្រាំជំហានៈ រដ្ឋាបាលថ្នាក់ រំលឹកមេរៀនចាស់ បង្រៀនមេរៀនថ្មី ពង្រឹងចំណេះដឹង និងដាក់កិច្ចការ ឱ្យសិស្ស ឬណែនាំសិស្សឱ្យស្វ័យសិក្សាមេរៀន។

ឃ. ធ្វើសកម្មភាពស្របតាមស្ថានភាពរស់នៅរបស់សិស្សនៅជុំវិញបរិបទជីវភាព វប្បធម៌ជាតិខ្មែរ និងតថភាពជាក់ស្តែងនៃជីវភាពរស់នៅប្រចាំថ្ងៃ។

ង. ជ្រើសរើសនិងផលិតសម្ភារៈងាយៗដែលមានតាមមូលដ្ឋានជាក់ស្តែងឬច្នៃប្រឌិតក្នុងការបង្រៀន។

**វិធីសាស្ត្របង្រៀនៈ**

- ការបង្រៀន គឺជាសកម្មភាពសម្របសម្រួលការបង្រៀនរបស់សិស្សដើម្បីឱ្យពួកគេមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលជាគោល
- ការបង្រៀន គឺជាសកម្មភាពជួយ និងលើកទឹកចិត្តសិស្ស ឱ្យចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្មមានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ធ្វើវិចារណ៍ អនុវត្តចំណេះដឹងសម្រាប់ការសិក្សា ការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រដូចជា សហការ សង្កេត និងអនុវត្តជាក់ស្តែង
- ការបង្រៀនត្រូវបន្តពង្រឹង និងពង្រឹងចំណេះដឹង បទពិសោធន៍ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រលាញ់ និងផ្តល់តម្លៃដល់ការសិក្សា

- ការបង្រៀនត្រូវតែផ្សាភ្ជាប់ទៅនឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព
- ការណែនាំ សម្របសម្រួលរាល់ការនាំសកម្មភាពសិក្សានៅក្នុងថ្នាក់ សាលារៀន និងក្រៅសាលាសិក្សាស្រាវជ្រាវ តាមរយៈសកម្មភាពបុគ្គល ដៃគូ ក្រុមតូច និងក្រុមធំ
- ការបង្រៀននិងរៀន ត្រូវយកចិត្តទុកដាក់លើខ្លឹមសារមេរៀនឱ្យបានច្បាស់លាស់ ដោយឱ្យសិស្សមានការហ្វឹកហាត់ អនុវត្តដោយផ្ទាល់និងមានការវាយតម្លៃជាប្រចាំ
- រៀបចំសិស្សឱ្យមានសកម្មភាពដូចជា ល្បែងដើរតួ ពិភាក្សា ដោយបណ្តុះនូវស្មារតីសហការ ចូលរួមសាមគ្គីភាព ភាពជាម្ចាស់ ការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចក្រុម ក្រោមការសម្របសម្រួលពីគ្រូ។

**ការប្រើប្រាស់សម្ភារៈ**

សម្ភារឧបទេសជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងដំណើរការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ សម្ភារឧបទេសរួមមាន៖ រូបភាពផ្ទាំងធំ បណ្ណរូបភាព បណ្ណពាក្យ សៀវភៅសិក្សាគោល សៀវភៅណែនាំជាដើម គឺជាធនធានដែលគ្រូនិងសិស្សយកមកប្រើប្រាស់ក្នុងការបង្រៀននិងរៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ ច្បាស់លាស់ ងាយចាប់បានមានការទាក់ទាញអារម្មណ៍សិស្សហើយអាចសម្រេចវត្ថុបំណងមេរៀនបានល្អប្រសើរ។

គ្រូត្រូវឱ្យសិស្សសង្កេត ពិចារណា ពិភាក្សា និងហាត់ប្រើសម្ភារៈដោយខ្លួនឯង ដើម្បីយល់ច្បាស់ពីខ្លឹមសារបង្រៀន។ កត្តាសំខាន់គ្រូត្រូវកំណត់សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ ទៅតាមតម្រូវការនៃមេរៀននីមួយៗ។

## ២.៥ ការលើកទឹកចិត្ត

ការលើទឹកចិត្តត្រូវបានគេចាត់ទុកថា ជាកត្តាដ៏ចម្បងមួយដែលដែលជះឥទ្ធពលដល់ល្បឿន និងកម្រិតនៃការសិក្សាភាសាបរទេសរបស់សិស្ស (Gardner, Jan 2006)។ ជាឧទាហរណ៍លោក

Gardner(2006) បានលើកឡើងថា សិស្សដែលមានកម្រិតនៃការលើកទឹកចិត្តខ្ពស់តែងតែធ្វើបានល្អជាងសិស្សដែលមានកម្រិតការលើកទឹកចិត្តទាបជាង។ ប្រសិនបើសិស្សមានការលើកទឹកចិត្តពួកគេមានហេតុផលគ្រប់គ្រាន់ ក្នុងការចូលរួមរាល់សកម្មភាពទាំងអស់។ (Elliot, S., Kratochil, T,.& Cook, J.,2000) មើលឃើញថាការលើកទឹកចិត្តជាសភាពលក្ខណៈខាងក្នុងដែលជំរុញឱ្យយើងធ្វើសកម្មភាព ដើម្បីឆ្ពោះទៅរកគោលដៅដែលខ្លួនចង់បាន និងជំរុញឱ្យយើងព្យាយាមស្វែងរកចំណេះដឹង និងជំនាញថ្មីៗ។ ចំណែកឯលោក Petty(1998) យល់ឃើញថា ប្រសិនបើសិស្សមិនចង់រៀន ប្រសិនភាពនៃការសិក្សារបស់ពួកគេប្រាកដជាយឺត ឬក៏គ្មានទទួលបានផលអ្វីទាំងអស់។ ដូច្នេះបើគ្រូបង្រៀនដឹងពីវិធីនៃការលើកទឹកចិត្តសិស្សគ្រូអាចជួយបង្កើនការសិក្សារបស់សិស្សឱ្យប្រសើរជាងមុន (Petty, 2004)។

ការលើកទឹកចិត្តគឺជាការគិត និងអារម្មណ៍ដែលអាចជំរុញឱ្យយើងបន្តធ្វើអ្វីមួយ ហើយប្រែក្លាយការគិតទាំងនោះទៅជាសកម្មភាព។ ចំណែកការលើកទឹកចិត្តក្នុងការរៀនភាសាអង់គ្លេសកាន់តែសំខាន់ ប៉ុន្តែវាអាចប្រែប្រួលទៅតាមអាយុ ពេលវេលា ទីកន្លែង និងសូម្បីតែការរៀនជាមួយគ្រូផ្សេងគ្នា។ មានកត្តាជាច្រើនដែលជះឥទ្ធិពល និងជំរុញលើកទឹកចិត្តឱ្យសិស្សចង់រៀនភាសាអង់គ្លេសដូចជា៖ ការយល់ពីសារៈសំខាន់នៃការរៀនភាសាអង់គ្លេស ការចាប់អារម្មណ៍ពីវប្បធម៌របស់ប្រទេសដែលប្រើប្រាស់ភាសាដែលសិស្សចង់រៀន និងការគាំទ្រពីមនុស្សដទៃទៀតជុំវិញខ្លួន។ គ្រូចាំបាច់ត្រូវជួយសិស្សដើម្បីបង្កើតឱ្យមានកម្លាំងជំរុញទឹកចិត្ត និងថែរក្សាវា (Spatt, M,Pulvemess,A., & Willams, M., 2005)។

ដោយបានសិក្សាពីអាកប្បកិរិយារបស់មនុស្សបានបញ្ជាក់ថា ឥរិយាបទចំពោះប្រទេស ក្រុម និងភាសាបានជួយយើងយល់ថា ហេតុអ្វីបានជាមនុស្សមួយចំនួនមានកម្លាំងចិត្តក្នុងការរៀនភាសាជាមួយដទៃ (Stern, 1983-03-24) ។ បន្ទាប់ពីការសង្កេតថ្នាក់រៀនមួយ អ្នកស្រាវជ្រាវបានជោគជ័យក្នុងការសិក្សា។ តាមរយៈលោក Shalaway(2005) លើកឡើងថា ការរៀបចំមេរៀនសម្រាប់បង្រៀនដោយផ្អែកលើចំណាប់អារម្មណ៍របស់សិស្សតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ គ្រូបង្រៀនចាំបាច់ត្រូវជួយជំរុញសិស្សជាច្រើនបានបែងចែកការជំរុញទឹកចិត្តជាពីប្រភេទ៖ ខាងក្នុង និង ខាងក្រៅ និងបានឱ្យនិយម

ន័យចំពោះការជំរុញទឹកចិត្តខាងក្នុងថាជាការធ្វើអ្វីមួយ ដោយសារការចូលចិត្តរបស់បុគ្គលនោះផ្ទាល់តែម្តង។ រីឯការជំរុញទឹកចិត្តខាងក្រៅថាកើតឡើងនៅពេលដែលមានកម្លាំងជំរុញពីខាងក្នុង ច្រើនទទួលបានលទ្ធផលនៃការសិក្សាខ្ពស់ជាងសិស្សដែលមានតែកម្លាំងជំរុញពីខាងក្រៅ (Deci, 2000)និងការលើកឡើងរបស់ លោក Kelvin និង Rosemary បានលើកឡើងថា ការលើកទឹកចិត្តជាមធ្យោបាយមួយ ដែលជួយឱ្យសិស្សកំណត់គោលដៅខ្លួនឯង សម្រាប់ការរៀនសូត្រនិងជួយគាំទ្រគោលដៅនោះឱ្យទទួលបានជោគជ័យក្នុងការសិក្សាដូចដែលគ្រូបង្រៀនបានរំពឹងទុក។ នោះការរំពឹងរបស់គ្រូក្នុងគោលបំណងប្រើប្រាស់ការលើកទឹកចិត្ត ដើម្បីទទួលលទ្ធផលនៃការសិក្សាប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលជាជាងមធ្យោបាយផ្សេងៗទៀត។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាការលើកទឹកចិត្តនោមិនមានទំនាក់ទំនងទៅនឹងអ្នករៀនសូត្រមានទំនោរទៅនឹងការរៀន ដោយប្រយោលនោះឡើយ (RosemarySutton, 2009)។

# ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ បញ្ហាប្រឈមនៃការរៀននិងបង្រៀនលើសមត្ថភាពស្ដាប់ភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ គឺស្វែងយល់ពីស្ថានភាពទូទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀននិងរៀនលើបំណិនស្ដាប់បានកម្រិតណា ការប្រើប្រាស់វិធីសាស្ត្របង្រៀនសមស្របនឹងសមត្ថភាពសិស្សដែរឬទេ រួមទាំងការប្រើប្រាស់សម្ភារៈគាំទ្រដល់ដំណើរការបង្រៀននិងរៀន ព្រមទាំងជួយឱ្យសិស្សរៀនសូត្រប្រកបដោយប្រសិទ្ធភាព និងរកបញ្ហាប្រឈមនានាលើការរៀននិងបង្រៀន។ រាល់ព័ត៌មានទាំងនោះនឹងត្រូវយកមកធ្វើការប្រៀបធៀបជាមួយការសិក្សាស្រាវជ្រាវកន្លងមក ដូច្នេះដើម្បីឱ្យការសិក្សាស្រាវជ្រាវឆ្លើយតបទៅនឹងប្រធានបទខាងលើ អ្នកស្រាវជ្រាវ បានប្រើប្រាស់មធ្យោបាយក្នុងដំណើរការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ(Qualitative Method) និង គុណវិស័យ(Qualitative Method)។ បន្ថែមពីនេះ ដើម្បីឱ្យវិធីសាស្ត្រស្រាវជ្រាវមានភាពងាយស្រួល អ្នកស្រាវជ្រាវនឹងរៀបចំជាកម្រងសំណួរតាមលំដាប់លំដោយដើម្បីដាក់ជូនគណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេសនិងសិស្ស នៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលជាសាលារដ្ឋក្នុងគោលបំណងទទួលយកទិន្នន័យ និងព័ត៌មានជាក់លាក់ដែលអ្នកស្រាវជ្រាវត្រូវការយកមកសិក្សាស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើ។

## ៣.១.ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេសដែលត្រូវការគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ដែលកំពុងបង្រៀនពីចំងាយតាម online ឬTelegram នៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិនៃវិទ្យាល័យទាំង៧ក្នុងរាជធានីភ្នំពេញក្នុងខណ្ឌចំនួន៦ ដើម្បីចង់ដឹងពីការប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់លោកគ្រូ-អ្នកគ្រូ លើមេរៀនបំណិនស្ដាប់នៅក្នុងថ្នាក់រៀនផ្អែកលើវិធីសាស្ត្រអ្វីខ្លះក្នុងពេលកំពុងរៀនបំណិនស្ដាប់។ ថាតើលោកគ្រូ-អ្នកគ្រូទាំង ៧ សាលា មានបញ្ហាប្រឈមអ្វីខ្លះក្នុងការបង្រៀនបំណិនស្ដាប់ បន្ថែមពីនេះអ្នកស្រាវជ្រាវចង់ដឹងពីបញ្ហាប្រឈមរបស់សិស្សដែលជួបកន្លងមក និងការជំរុញលើកទឹកសិស្សឱ្យរៀនទទួលបាននូវគុណភាព

និងប្រសិទ្ធភាពលើសមត្ថភាពស្ដាប់ភាសាអង់គ្លេស។ ហេតុដូច្នេះហើយ ទើបតម្រូវឱ្យបង្កើតនូវប្រព័ន្ធប្រមូលទិន្នន័យតាមបែបបរិមាណវិស័យនិងគុណវិស័យ ដើម្បីធ្វើការតាមដានលើការសម្រេចចិត្តនិងប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់លោកគ្រូអ្នកគ្រូ ព្រមទាំងបញ្ហាប្រឈមលើការរៀននិងបង្រៀន។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រងសំណួរត្រូវបានរៀបចំជាបួនផ្នែកសំខាន់៖

ផ្នែកទីមួយ៖ រៀបចំបង្កើតជាកម្រងសំណួរអំពីព័ត៌មានទូទៅសម្រាប់ឱ្យអ្នកចូលរួមបំពេញមានដូចជាតួនាទី កន្លែងបម្រើការងារ ភេទ អាយុ បទពិសោធន៍ការងារ កម្រិតសញ្ញាបត្រនិងភាសាបរទេស។

ផ្នែកទីពីរ៖ ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស។

ផ្នែកទីបី៖ បញ្ហាប្រឈមក្នុងការបង្រៀននិងរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស។

ផ្នែកទីបួន៖ សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស។

ឯកសារទាំងអស់នេះមានសារៈសំខាន់ សម្រាប់ធ្វើការស្វែងរកឱ្យឃើញកត្តាជះឥទ្ធិពលនានារបស់លោកគ្រូ-អ្នកគ្រូជាមួយស្ថានភាពកំពុងបង្រៀននាពេលបច្ចុប្បន្ន និងការអនុវត្តវិធីសាស្ត្របង្រៀឱ្យស្របតាមការណែនាំ និងសម្រេចគោលដៅលើលម្អិតកម្មវិធីសិក្សាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការបង្កើតកម្រងសំណួរ៖ កម្រងសំណួរត្រូវឆ្លងកាត់ការពិចារណាជាច្រើនដំណាក់កាល ដោយការពិភាក្សា ពិគ្រោះយោបល់យ៉ាងលម្អិតជាមួយគ្រូដឹកនាំបង្គោល។ ដំណាក់កាលទាំងនោះមានការប្រែប្រួលឬផ្លាស់ប្ដូរទៅតាមវត្ថុបំណងដែលបានកំណត់ខាងលើ និងដើម្បីយកកម្រងសំណួរនេះទៅជូនដល់ គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សតាមសាលាគោលដៅ ធ្វើការឆ្លើយតបដើម្បីទទួលបានទិន្នន័យជាក់លាក់ប្រសិទ្ធភាពខ្ពស់។

ការចងក្រងកម្រងសំណួរ៖ កម្រងសំណួរត្រូវបានបង្កើតឡើង តាមរយៈការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ទើបឈានទៅបង្កើតបានជាកម្រងសំណួរព្រាង សម្រាប់ធ្វើការសាកល្បងមុននឹងសម្រេចជ្រើសរើសសំណួរយកមកប្រើប្រាស់ជាមួយក្រុមគោលដៅដែលបានកំណត់។

ដំណាក់កាលសាកល្បង៖ ក្រោយពីកម្រងសំណួរព្រាងត្រូវបានបញ្ចប់ អ្នកស្រាវជ្រាវបានកំណត់នូវមុខសញ្ញាតាមសាលាមធ្យមសិក្សាទុតិយភូមិ ដែលប្រហាក់ប្រហែលទៅនឹងក្រុមគោលដៅដែលនឹងត្រូវឆ្លើយកម្រងសំណួរជាផ្លូវការ សម្រាប់ធ្វើការសាកល្បង ធ្វើយ៉ាងណាប្រើប្រាស់វិធីសាស្ត្រឱ្យអស់លទ្ធភាពដែលបានកំណត់ក្នុងវត្ថុបំណង។

ដំណាក់កាលកែលម្អ៖ បន្ទាប់ពីសាកល្បងចប់ សំណួរទាំងអស់ត្រូវបានធ្វើការពិចារណាឡើងវិញដើម្បីធ្វើការថ្លឹងថ្លែងលើចំណុចនីមួយៗ ថាតើមានភាពពិបាកពេក ងាយស្រួលពេក សំណួរណាត្រូវបានរក្សាទុក សំណួរណាត្រូវបន្ថែមលើចំណុចអ្វីខ្លះ និងធ្វើការកែលម្អសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

ដំណាក់កាលប្រើប្រាស់៖ មុននឹងយកកម្រងសំណួរនេះ ទៅប្រើប្រាស់ជាមួយមុខសញ្ញា លោកនាយក/នាយិកា លោកគ្រូ-អ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេស សិស្ស ត្រូវមានការណែនាំលម្អិតតាមចំណុចនីមួយៗជាមុន លើវិធីសាស្ត្រនៃការបំពេញកម្រងសំណួរ និងពិនិត្យតាមដានដើម្បប្រមូលយកមកវិញនូវទិន្នន័យ និងព័ត៌មានដែលមានគុណភាព អាចប្រើប្រាស់បាន សម្រាប់ធ្វើការវិភាគរកលទ្ធផលសមស្របទៅតាមការស្ថានភាពជាក់ស្តែងរបស់សាលារៀន ជាពិសេស វិធីសាស្ត្របង្រៀន ការប្រើប្រាស់សម្ភារឧបទេស បច្ចេកទេសក្នុងការបង្រៀន និងរៀនរបស់គ្រូបង្រៀន សិស្សនុសិស្ស ព្រមទាំងបញ្ហាប្រឈមនានាក្នុងការរៀននិងបង្រៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេស របស់លោកគ្រូ-អ្នកគ្រូ និងសិស្ស។

## ៣.២.ទីកន្លែងសិក្សាស្រាវជ្រាវ

នៅគ្រប់គ្រឹះស្ថានសិក្សារដ្ឋទាំងអស់ ការបង្រៀននិងរៀនភាសាបរទេស ជួបប្រទះបញ្ហាប្រឈមតែងតែកើតមានមិនដូចគ្នានៅគ្រប់សាលានោះទេ។ ការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសទីតាំង ៦ខណ្ឌ ក្នុងចំនោមទាំង១៤ខណ្ឌទូទាំងរាជធានី។ អ្នក

ស្រាវជ្រាវបានជ្រើសរើស វិទ្យាល័យចំនួន៧ នៃខណ្ឌ៦ ក្នុងចំណោមវិទ្យាល័យសរុបទាំង៤០ នៅក្នុងរាជធានីភ្នំពេញមកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្អែកលើកត្តាពេលវេលា និងធនធានមានកំណត់ ជាពិសេសស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជំងឺឆ្លង(Covid-19) និងការរក្សាគម្លាតសុវត្ថិភាពសង្គម ព្រមទាំងសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូតម្រូវឱ្យរៀននិងបង្រៀន ពីចម្ងាយតាមរយៈ ONLINE ZOOM TELEGRAM ការប្រគល់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ។ វិទ្យាល័យទាំង៧ ជាវិទ្យាល័យគោលដៅដែលត្រូវបានជ្រើសរើសរួមមាន (១) ខណ្ឌជ្រោយចង្វា៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យព្រែកលៀប (២) ខណ្ឌឫស្សីកែវ៖ សាលាគោលដៅមានពីរគឺ វិទ្យាល័យឫស្សីកែវ និង វិទ្យាល័យជាស៊ីមចំរើនរដ្ឋ (៣)ខណ្ឌចំការមន៖ សាលាគោលដៅមានមួយគឺ វិទ្យាល័ល ទួលទំពូង (៤)ខណ្ឌ៧មករា៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យបាក់ទូក (៥) ខណ្ឌព្រែកព្នៅ៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យសម្តេចមហាសេនាបតីតេជោហ៊ុន សែនសំរោង (៦) ខណ្ឌមានជ័យ៖ សាលាគោលដៅមានមួយគឺ វិទ្យាល័យចម្រើនផល។ ការជ្រើសរើសវិទ្យាល័យទាំង ៧ ក្នុងរាជធានីភ្នំពេញ ដែលបានកំណត់ខាងលើ អ្នកសិក្សាបានសម្រេចជ្រើសរើសយកសាលាមួយចំនួនស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ទីប្រជុំជនក្នុងរាជធានី និងមួយចំនួនទៀតជាសាលាដែលស្ថិតនៅជាយរាជធានីភ្នំពេញ។

***តារាង ៣.១. ឈ្មោះខណ្ឌ និងសាលា***

| ល.រ | ខណ្ឌ | ចំនួនសាលា |
|---|---|---|
| ១ | ខណ្ឌជ្រោយចង្វា | វិទ្យាល័យព្រែកលៀប |
| ២ | ខណ្ឌឫស្សីកែវ | វិទ្យាល័យឫស្សីកែវ<br>វិទ្យាល័យជាស៊ីមចំរើនរដ្ឋ |
| ៣ | ខណ្ឌចំការមន | វិទ្យាល័យទួលទំពូង |
| ៤ | ខណ្ឌ៧មករា | វិទ្យាល័យបាក់ទូក |
| ៥ | ខណ្ឌព្រែកព្នៅ | វិទ្យាល័យអគ្គមហាសេនបតីតេជោហ៊ុន សែន សំរោង |

| | | |
|---|---|---|
| ៦ | ខណ្ឌមានជ័យ | វិទ្យាល័យចម្រើនផល |
| សរុប | ៦ | ៧ |

## ៣.៣.ភាគសំណាក និងទំហំភាគសំណាក

ការសិក្សាស្រាវជ្រាវនេះធ្វើទៅលើគណៈគ្រប់គ្រងសាលា (នាយក/នាយិកា - នាយករង/នាយិការង) គ្រូបង្រៀនដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ (ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២) ព្រមទាំងសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ(ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២)ហើយមិនគិតថាជាថ្នាក់វិទ្យាសាស្រ្ត ឬវិទ្យាសាស្រ្តសង្គមឡើយ។ ចំពោះភាគសំណាកដែលត្រូវប្រមូលទិន្នន័យគឺគណៈគ្រប់គ្រងសាលារៀននាយក/នាយិកា-នាយករង/នាយិការងសាលា ចំនួន ១៣នាក់ លោកគ្រូ-អ្នកគ្រូដែលជាបុគ្គលិកបង្រៀនមុខវិជ្ជាភាសាអង់គ្លេសចំនួន ២០នាក់និងសិស្សមានចំនួន១៩០នាក់ ដោយមួយវិទ្យាល័យជ្រើសរើសចំនួន១០ទៅ៣០នាក់ ដោយសិស្សមួយវិទ្យាល័យមានសិស្សថ្នាក់ទី១០ ចំនួន១០នាក់ និងទី១១ ចំនួន១០នាក់ និង សិស្សទី១២ ចំនួន១០នាក់ ។

***តារាង*** *៣.២. ភាគសំណាក និងទំហំភាគសំណាក*

| ល.រ | ឈ្មោះសាលា | ចំនួនអ្នកចូលរួម | | | | |
|---|---|---|---|---|---|---|
| | | គណៈគ្រប់គ្រង | គ្រូបង្រៀន | សិស្សទី១០ | សិស្សទី១០ | សិស្សទី១២ |
| ១ | វិទ្យាល័យព្រែកលៀប | ២នាក់ | ៣នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |
| ២ | វិទ្យាល័យឫស្សីកែវ | ២នាក់ | ៤នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |
| ៣ | វិទ្យាល័យជាស៊ីមចំរើនរដ្ឋ | ២នាក់ | ៤នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |
| ៤ | វិទ្យាល័យទួលទំពូង | ២នាក់ | ១នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |
| ៥ | វិទ្យាល័យបាក់ទូក | ២នាក់ | ៣នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |
| ៦ | វិទ្យាល័យអគ្គមហាសេនាបតីតេជោរហ៊ុន សែន សំរោង | ២នាក់ | ២នាក់ | ១០នាក់ | ១០នាក់ | ១០នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | វិទ្យាល័យចម្រើនផល | ១នាក់ | ៣នាក់ | ១០នាក់ | ០នាក់ | ០នាក់ |
| សរុប | | ១៣នាក់ | ២០នាក់ | ៧០នាក់ | ៦០នាក់ | ៦០នាក់ |

## ៣.៤.ឧបករណ៍សម្រាប់ធ្វើការស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើក្នុងការប្រមូលទិន្នន័យ មានកម្រងសំណួរចំនួន៣ប្រភេទ(គណនៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្ស) ដែលកម្រងសំណួរមានលក្ខណៈជាទម្រង់បិទ និងកម្រងសំណួរទម្រង់បើក ។ ដើម្បីប្រមូលទិន្នន័យនេះបាន ត្រូវមានកម្រងសំណួរសម្រាប់លោកនាយកនាយិកាសាលារៀន កម្រងសំណួរសម្រាប់គ្រូបង្រៀន និងកម្រងសំណួសម្រាប់សិស្ស អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរជាបី(៣)ប្រភេទ ដែលក្នុងនោះរួមមាន (១) កម្រងសំណួរសម្រាប់ គណៈគ្រប់គ្រងសាលាចំនួន ១៨សំណួរ (២) កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូចំនួន ៤១ និង(៣) កម្រងសំណួរសម្រាប់សិស្សថ្នាក់ទី១០-១២ មានចំនួន ៣៧សំណួរ។ មុនពេលផ្តល់កម្រងសំណួរស្រាវជ្រាវនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងគឺអ្នកស្រាវជ្រាវបានទទួលលិខិតពីវិទ្យាស្ថានជាតិអប់រំ លេខៈ ១០៦ វជអ ផក ដើម្បីធ្វើការទំនាក់ទំនងជាមួយមន្ទីរអប់រំ យុវជននិងកីឡា រាជធានី ការិយាល័យអប់រំខណ្ឌ និងក្រោយមកបានធ្វើការទំនាក់ទំនងជួបផ្ទាល់ជាមួយនាយក/នាយិកា នាយករង/នាយិការងសាលា និងលោកគ្រូ-អ្នកគ្រូបង្រៀនភាសាអង់គ្លេសកម្រិតឧត្តម និងសិស្សថ្នាក់ទី១០-១២ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការបំពេញកម្រងសំណួរ។

### ៣.៤.១.កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បី

វាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្ស ។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ រូបមន្តនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Wannatawee,Worakham,&Panya, 2017)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{៥ - ១}{៥} = \frac{៤}{៥} = 0.៨0$$

| | | |
|---|---|---|
| ១.00 — ១.៨0 | មានន័យថា | ខ្សោយខ្លាំង |
| ១.៨១ — ២.៦0 | មានន័យថា | ខ្សោយ |
| ២.៦១ — ៣.៤0 | មានន័យថា | មធ្យម |
| ៣.៤១ — ៤.២0 | មានន័យថា | ល្អ |
| ៤.២១ — ៥.00 | មានន័យថា | ល្អណាស់ |

### ៣.៤.២.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់លោកនាយក/នាយិកាសាលា មានគោលបំណងស្វែងយល់អំពី ដំណើរការនៃការងារគ្រប់គ្រងរបស់លោកនាយក/នាយិកាសាលា និងការពង្រឹងគុណភាពសិក្សារបស់សិស្សនៅក្នុងសាលារៀនរបស់ខ្លួន។ កម្រងសំណួរនេះមានការបែងចែកជាពីរផ្នែកគឺ៖ ផ្នែកទី១ ស្ដីពីព័ត៌មានទូទៅ និង

ផ្នែកទី២ ស្តីពីការងារគ្រប់គ្រងដឹកនាំ ជាពិសេសទៅលើការងារពង្រឹងគុណភាពនៃការបង្រៀន និងរៀនរបស់គ្រូ និងសិស្សដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់គាត់ ការត្រួតពិនិត្យនិងវាយតម្លៃនិងលើកទឹកចិត្តដល់គ្រូបង្រៀន និងសិស្សរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស នៅតាមកន្លែងដែលបានព្រមព្រៀងគ្នារវាងអ្នកប្រមូលទិន្នន័យ និងអ្នកផ្តល់ព័ត៌មានដោយទទួលបានការអនុញ្ញាតពីប្រធានការិយាល័យអប់រំខណ្ឌផងដែរ។

## ៣.៤.៣.កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គ្រូបង្រៀន មានគោលបំណងរកឱ្យឃើញនូវនៃការការសម្រេចចិត្តលើការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ការអនុវត្តវិធីសាស្ត្របង្រៀន និងសម្ភារឧបទ្ទេសបង្រៀនព្រមទាំងបញ្ហាប្រឈមនានាក្នុងការបង្រៀនបំណិនស្តាប់ និងការជំរុញលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់ភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យរដ្ឋ ការពិនិត្យតាមដាន និងកែលម្អបច្ចេកទេសក្នុងការបង្រៀន និង ការអនុវត្តតួនាទីរបស់គ្រូបង្រៀនក្នុងពេលកំពុងបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស។ សំណួរ នេះចែកចេញជាបួនផ្នែកគឺៈ ផ្នែកទី១ ស្តីពីព័ត៌មានទូទៅ ផ្នែកទី២ ស្តីពីដំណើរការបង្រៀនសមត្ថភាពភាសាអង់គ្លេស ស្តីពីវិធីសាស្ត្របង្រៀននិង ការប្រើប្រាស់សម្ភារៈជំនួយការបង្រៀន និងរៀន ផ្នែកទី៣ៈ បញ្ហាប្រឈមក្នុងពេលបង្រៀនបំណិនស្តាប់និង ផ្នែកទី៤ៈ ស្តីពីសារៈសំខាន់នៃការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស។ នៅក្នុងកម្រងសំណួរនេះមានសំណួរទម្រង់បិទ និងទម្រង់បើកដោយបានទទួលការអនុញ្ញាតពីសាមីខ្លួនព្រមទាំងលោកនាយក/នាយិកាសាលាផងដែរ។

## ៣.៤.៤.កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរនេះ មានគោលបំណងស្វែងយល់ពីដំណើរការរៀននិងការអនុវត្តវិធីសាស្ត្ររៀនដើម្បីបង្កើនបំណិនស្តាប់និងចង់សិក្សាស្វែងយល់ពីការរៀន ដែលជួបផលវិបាកពេលរៀនបំណិនស្តាប់ភាសាអង់គ្លេសក្នុងថ្នាក់រៀនរបស់ពួកគាត់។ កម្រងសំណួរនេះមានការបែងចែកជាបីផ្នែកគឺៈ ផ្នែកទី១ៈ ស្តីពីព័ត៌មានទូទៅ និងផ្នែកទី២ៈ ស្តីពីការយល់ឃើញរបស់សិស្សទៅលើសមត្ថភាពភាសាអង់គ្លេសរបស់ខ្លួន

ការប្រើវិធីសាស្ត្ររៀន និងការសម្ភារៈរៀន និង ផ្នែកទីបី៖ ស្ដីពីបញ្ហាប្រឈមក្នុងការរៀនបំណិនស្ដាប់ភាសាអង់គ្លេស ។ ដោយសារស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជំងឺឆ្លង(Covid-19) និងការរក្សា គម្លាតសុវត្ថិភាពសង្គម ការធ្វើកម្រងសំណួរគឺធ្វើឡើងតាមរយៈ Google form តាមរយៈការឆ្លើយតាមការបោះលីងក្នុងតេឡេក្រាម រឺការឆ្លើយតាមរយៈកម្រងសំណួរ ដែលចែកចុះផ្ទាល់ទៅតាមសាលានីមួយៗ ដែលជាសាលាគោលដៅ។

## ៣.៥.វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះប្រើវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យក្នុងការប្រមូលទិន្នន័យ។ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យ និងគុណវិស័យ គឺធ្វើការស្នើរសុំលោកនាយក/នាយិកាសាលារៀនគោលដៅ និងស្នើសុំឱ្យបំពេញកម្រងសំណួរសម្រាប់លោកគ្រូ-អ្នកគ្រូបង្រៀន និងសិស្សដោយប្រើកម្រងសំណួរសំណួរ (Questionnaires) ដែលបានរៀបចំទុកជាមុនស្របតាមគោលបំណងនៃការស្រាវជ្រាវខាងលើ។ តារាងសំណួរត្រូវបានរៀបចំឡើង ដោយបញ្ចូលព័ត៌មានដែលត្រូវសួរដូចជា ផ្នែកទី១៖ ស្ដីពីព័ត៌មានផ្ទាល់ខ្លួនរបស់គាត់ និងផ្នែកទី២៖ការគ្រប់គ្រងដឹកនាំ និងតាមដានវាយតម្លៃរបស់នាយកនាយការ លើការងារបង្រៀនរបស់លោកគ្រូអ្នកគ្រូ និង ការរៀនរបស់សិស្ស។ ព័ត៌មានទាំងនេះត្រូវបានសាកសួរឆ្លើយតបទៅនឹងគោលបំណង ដែលចង់ដឹងមានដំណើរការរៀននិងបង្រៀនយ៉ាងដូចម្ដេច បញ្ហានានាដែលលោកគ្រូអ្នកគ្រូ និងសិស្សមានបញ្ហាប្រឈមយ៉ាងដូចម្ដេចខ្លះ ទៅលើកិច្ចការបង្រៀន និងរៀនបំណិនស្ដាប់ភាសាអង់គ្លេសរបស់លោកគ្រូ-អ្នកគ្រូ និងសិស្ស ។

## ៣.៦.ដំណើរការក្នុងការប្រមូលទិន្នន័យ

ក្នុងការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងដោយបានធ្វើការទំនាក់ទំនង និងសុំការអនុញ្ញាតពីមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ ការិយាល័យអប់រំខណ្ឌ ព្រមទាំងគ្រឹះស្ថានសិក្សាគោលដៅ។ ជាដំបូងអ្នកសិក្សាស្រាវជ្រាវបានចុះជួបជាមួយមន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ដើម្បីសុំការអនុញ្ញាត សាកសួរព័ត៌មានបន្ថែមអំពីទីតាំង និងពេលវេលាណាត់ជួប ដែលបានកំណត់ទុកសម្រាប់ធ្វើការ

សិក្សាស្រាវជ្រាវ។ បន្ទាប់ពីបានកំណត់ទីតាំងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវរួចហើយ អ្នកសិក្សាស្រាវជ្រាវបានសុំជួបជាមួយនឹងប្រធានការិយាល័យអប់រំយុវជន និងកីឡាតាមខណ្ឌ ដើម្បីសុំការអនុញ្ញាតចុះទៅដល់សាលាគោលដៅដែលបានកំណត់។ ក្រោយមកអ្នកសិក្សាស្រាវជ្រាវធ្វើការទំនាក់ទំនងជាមុន ដើម្បីណាត់ជួប ក្រោយពីបានជួបជាមួយលោកនាយក នាយិកាសាលា លោកគ្រូ-អ្នកគ្រូនៅតាមសាលានានាដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះធ្វើការសិក្សាស្រាវជ្រាវនេះ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំការសម្របសម្រួលពីលោកនាយក នាយិកាសាលា និងលោកគ្រូ-អ្នកគ្រូក្នុងដំណើរបំពេញកម្រងសំណួរ និងការណែនាំពីរបៀបបំពេញកម្រងសំណួរ។ បន្ទាប់ពីបានជ្រើសរើសលោកគ្រូ-អ្នកគ្រូឱ្យចូលរួមក្នុងការផ្តល់ព័ត៌មាន សម្រាប់កម្រងសំណួរ និងណែនាំពីរបៀបនៃការបំពេញកម្រងសំណួររួចរាល់ហើយ អ្នកស្រាវជ្រាវក៏បានផ្តល់កម្រងសំណួរដល់ពួកគាត់ដើម្បីបំពេញនិងទំនាក់ទំនងជាមួយលោកគ្រូ-អ្នកគ្រូ ដែលមិនបានចូលរួម អ្នកស្រាវជ្រាវនិងផ្តល់កម្រងសំណួរតាម Google form ដើម្បីឱ្យ ពួកគាត់បំពេញ រីឯសិស្សក៏ដូចគ្នាផងដែរ។ បន្ទាប់ពីបានបំពេញរួចរាល់ អ្នកសិក្សាស្រាវជ្រាវបានប្រមូលកម្រងសំណួរពីលោកគ្រូ-អ្នកគ្រូ និងបានត្រួតពិនិត្យផ្ទៀងផ្ទាត់កម្រងសំណួរគ្រប់ជ្រុងជ្រោយ បានបំពេញត្រឹមត្រូវហើយ យកមកវិញដើម្បីធ្វើការវិភាគ។

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានចុះទៅសិក្សាតាមទីតាំងសាលារៀនដែលបានកំណត់ជ្រើសរើស ដោយប្រើប្រាស់រយៈពេលប្រហែល២៥ថ្ងៃ ចាប់ពីថ្ងៃទី ០១ សីហា ២០២០ ដល់ ២៥ សីហា ២០២០។

## ៣.៧.ការវិភាគទិន្នន័យ

ដោយផ្អែកលើចម្លើយរបស់ការបំពេញកម្រងសំណួរជាព័ត៌មានជាក់លាក់ ដែលបានមកពីនាយក នាយិកាសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សតាមសាលានីមួយៗ ការវិភាគនេះគឺបានធ្វើឡើងដោយប្រើវិធីសាស្ត្របែបវិភាគតាមទិន្នន័យបរិមាណវិស័យ និងគុណវិស័យ។ ការសិក្សានេះ បានអនុវត្តការវិភាគតាមបែបស្ថិតិមានដូចជា ការវិភាគបែបពណ៌នាដើម្បីផ្តុំទិន្នន័យ ដើម្បីរកឃើញពីកត្តាជះឥទ្ធពល និងបញ្ហា

ប្រឈមនានាក្នុងការរៀន និងបង្រៀនបំណិនស្ដាប់តាមសាលានានាក្នុងពេលបច្ចុប្បន្ននេះ ដោយប្រើប្រាស់កម្មវិធី Microsoft Excel 2010 ដើម្បី រកភាគរយ(Percentage) និងតម្លៃមធ្យមភាគ (Mean) ដើម្បីបកស្រាយលទ្ធផលស្រាវជ្រាវ និងវិភាគទិន្នន័យដោយសិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករនីមួយៗ ។

## ៣.៨.ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវបានធ្វើការណែនាំខ្លួន និងប្រាប់ពីគោលបំណងនិងរបៀបនៃការបំពេញកម្រងសំណួរ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជា រក្សាការសម្ងាត់ជូនដល់អ្នកបំពេញ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ ក្នុងគោលបំណងផ្សេងទៀតឡើយ អ្នកស្រាវជ្រាវប្រើព័ត៌មាននេះក្នុងគោលបំណងសិក្សាស្រាវជ្រាវលើប្រធានបទខាងលើតែប៉ុណ្ណោះ។ ក្នុងដំណើរការបំពេញកម្រងសំណួរដល់គណៈនាយក នាយិការ លោកគ្រូអ្នកគ្រូ និងសិស្សដោយកត្តាបរិបទនៃការរាតត្បាត កូវិត-១៩ គម្លាតសុវត្ថិភាពសង្គម និងមិនមានការប្រមូលផ្ដុំគ្នាលើសពី២០នាក់ ការណាត់ជួបត្រូវបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ ការណាត់ជួបសិស្សកម្រិតថ្នាក់ទី១០ ១១និងទី១២ ត្រូវបែងចែកពេលវេលាខុសគ្នា ដោយមធ្យោបាយដូចជា ការបោះលីង Google form (កម្រងសំណួរ ) ទៅឱ្យគ្រូក៏ដូចជាសិស្សដែលមិនបានចូលរួមផ្ទាល់។ លើសពីនេះទៅទៀតការចុះផ្ទាល់ អ្នកសិក្សាស្រាវជ្រាវបានរៀបចំខ្លួនដោយមានសម្លៀកបំពាក់ សមរម្យ ទឹកមុខស្រស់ស្រាយញញឹមរួសរាយ និងបង្ហាញនូវភាពស្និទ្ធស្នាលប្រើកាយវិការទន់ភ្លន់ និងត្រៀមជាស្រេចនូវកម្រងសំណួរចែកជូនគណៈនាយក នាយិការ លោកគ្រូ-អ្នកគ្រូ និងសិស្សដែលបានទំនាក់ទំនងរួចហើយ ជាពិសេសអ្នកសិក្សាស្រាវជ្រាវមិនធ្វើការផ្ដល់យោបល់ ឬអនុសាសន៍ផ្សេងៗដល់អ្នកត្រូវបំពេញកម្រងសំណួរជាដាច់ខាត។

## ៣.៩.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្ដោតទៅលើការ បញ្ហាប្រឈមក្នុងរៀននិងបង្រៀនលើសមត្ថភាពស្ដាប់ភាសាអង់គ្លេស ក្នុងគោលបំណងពង្រឹងការងារបង្រៀន និងលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្ស

នៅថ្នាក់មធ្យមសិក្សាទុតិយភូមិ ក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ។ រាល់កម្រងសំណួរគឺមិនបានសួរពីអ្វីដែលមិនពាក់ព័ន្ធនឹងប្រធានបទ នៃការសិក្សាស្រាវជ្រាវខាងលើនោះទេ។ ព័ត៌មានដែលទទួលបាន ត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនបានយកឈ្មោះ ឬអ្វីដែលបញ្ជាក់អត្តសញ្ញាណរបស់ពួកគាត់នោះទេ។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយចង់ដឹងការប្រើវិធីសាស្ត្ររៀននិងបង្រៀន និងការយល់ឃើញ ក៏ដូចជាបញ្ហាប្រឈមនៃការរៀន និងបង្រៀនបំណិនស្តាប់នៅតាមសាលារៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ដល់១២)។ ម៉្យាងទៀតចំពោះតំបន់ដែលបានធ្វើការសិក្សាស្រាវជ្រាវ មានលក្ខណៈតូចនៅឡើយ តំណាងតែរាជធានីភ្នំពេញ ដូច្នេះមិនអាចតំណាងឱ្យតំបន់ឬខេត្តផ្សេងៗទៀតបាននោះទេ។

# ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងការឆ្លើយសំណួរបើកដោយមានគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្ស។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស និងការជួបបញ្ហាប្រឈមនានានៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស នាពេលកន្លងមកត្រូវបានលើកយកមកបកស្រាយ និងពិភាក្សា។

## ៤.១.ទិន្នន័យព័ត៌មានទូទៅ(គ្រូបង្រៀន សិស្សនិងគណៈគ្រប់គ្រង)

### ៤.១.១.ព័ត៌មានទូទៅរបស់អ្នកចូលរួម

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកខណ្ឌចំនួន៦ ក្នុងចំណោមខណ្ឌ១៤ក្នុងរាជធានីភ្នំពេញ ជាគោលដៅនៃការសិក្សាស្រាវជ្រាវដែលមាន៖ (១)ខណ្ឌឫស្សីកែវ (២)ខណ្ឌជ្រោយចង្វា (៣)ខណ្ឌព្រែកព្នៅ (៤)ខណ្ឌមានជ័យ (៥)ខណ្ឌពមករា (៦)ខណ្ឌចំការមន។ នៅក្នុងផ្នែកនេះបង្ហាញពីព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សដែលជាសំណាកស្រាវជ្រាវទាំងអស់ មានព័ត៌មានលម្អិតពី កម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍បង្រៀន និងមុខវិជ្ជាឯកទេសដូចក្នុងតារាងខាងក្រោម៖

#### ៤.១.១.១.ព័ត៌មានទូទៅពីគ្រូបង្រៀន

**តារាង៤.១ ទិន្នន័យព័ត៌មានទូទៅពីគ្រូបង្រៀន**

| ល.រ | បរិយាយ | | វិទ្យាល័យ | | | | | | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឫស្សីកែវ | ជាស៊ីមចំរើនរដ្ឋ | ចំរើនផល | ទួលទំពូង | សំពោង | ព្រែកលៀប | បាក់ទូក | ចំនួន | ភាគរយ |
| | តួនាទី | គ្រូបង្រៀន | ៤ | ៤ | ៣ | ១ | ២ | ៣ | ៣ | ២០ | ១០០% |
| | | សរុប | ៤ | ៤ | ៣ | ១ | ២ | ៣ | ៣ | ២០ | ១០០% |
| ១ | ភេទ | ប្រុស | ២ | ២ | ១ | ០ | ១ | ២ | ២ | ១០ | ៥០% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ស្រី | ២ | ២ | ២ | ១ | ១ | ១ | ១ | ១០ | ៥០% |
| | | **សរុប** | **៤** | **៤** | **៣** | **១** | **២** | **៣** | **៣** | **២០** | **១០០%** |
| ២ | អាយុ | ២៥ - ៣០ ឆ្នាំ | ១ | ០ | ០ | ០ | ០ | ២ | ០ | ៣ | ១៥% |
| | | ៣១ - ៣៥ ឆ្នាំ | ០ | ១ | ២ | ០ | ០ | ១ | ២ | ៦ | ៣០% |
| | | ៣៦ - ៤០ ឆ្នាំ | ១ | ១ | ០ | ០ | ០ | ០ | ១ | ៣ | ១៥% |
| | | លើសពី ៤០ឆ្នាំ | ២ | ២ | ១ | ១ | ២ | ០ | ០ | ៨ | ៤០% |
| | | **សរុប** | **៤** | **៤** | **៣** | **១** | **២** | **៣** | **៣** | **២០** | **១០០%** |
| ៣ | កម្រិតសញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | ២ | ២ | ១ | ១ | ០ | ១ | ២ | ៩ | ៤៥% |
| | | បរិញ្ញាបត្រ | ២ | ២ | ២ | ០ | ២ | ២ | ១ | ១១ | ៥៥% |
| | | ចប់ថ្នាក់ទី១២ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | 0% |
| | | **សរុប** | **៤** | **៤** | **៣** | **១** | **២** | **៣** | **៣** | **២០** | **១០០%** |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ ឆ្នាំ | ០ | ១ | ១ | ០ | ១ | ១ | ០ | ៤ | ២០% |
| | | ៦ ដល់ ១០ ឆ្នាំ | ១ | ០ | ១ | ០ | ០ | ២ | ០ | ៤ | ២០% |
| | | ១១ ដល់ ១៥ ឆ្នាំ | ១ | ១ | ១ | ០ | ០ | ០ | ១ | ៤ | ២០% |
| | | លើសពី១៥ឆ្នាំ | ២ | ២ | ០ | ១ | ១ | ១ | ១ | ៨ | ៤០% |
| | | **សរុប** | **៤** | **៤** | **៣** | **១** | **២** | **៣** | **៣** | **២០** | **១០០%** |
| ៤ | ឯកទេស | ភាសាអង់គ្លេស | ៣ | ២ | ៣ | ១ | ២ | ២ | ៣ | ១៦ | 80% |
| | | ភាសាអង់គ្លេស+អប់រំ | ០ | ០ | ០ | ០ | ០ | ១ | ០ | ១ | ៥% |
| | | ភាសាអង់គ្លេស+ICT | ០ | ១ | ០ | ០ | ០ | ០ | ០ | ១ | ៥% |
| | | ភាសាអង់គ្លេស+ខ្មែរ | ១ | ១ | ០ | ០ | ០ | ០ | ០ | ២ | ១០% |
| | | **សរុប** | **៤** | **៤** | **៣** | **១** | **២** | **៣** | **៣** | **២០** | **១០០%** |

តាមតារាង ៤.១ បង្ហាញថាគ្រូភាគច្រើនជាគ្រូដែលបង្រៀនថ្នាក់ទី១០ដល់ទី១២។

ភេទ៖ គ្រូភេទប្រុសមានចំនួន ៥០% នៃចំនួនសរុប២០នាក់ ក្រៅពីនេះជាគ្រូភេទស្រី។

អាយុ៖ គ្រូបង្រៀនភាគច្រើនមានអាយុលើសពី៤០ឆ្នាំ ចំនួន៤០% ហើយគ្រូបង្រៀនភាគតិចមានអាយុចន្លោះពី២០ ដល់ ២៥ ឆ្នាំ ចំនួន ១៥% និង ៣១ដល់៣៥ឆ្នាំ ចំនួន ៣០% ក្រៅពីនេះគឺ អាយុចន្លោះពី ៣៦ ដល់ ៤០ ឆ្នាំ ចំនួន១៥%។

កម្រិតសញ្ញាបត្រ៖ គ្រូបង្រៀនភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រចំនួន៥៥%។ រីឯគ្រូបង្រៀនភាគតិចមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ចំនួន៤៥%។

បទពិសោធន៍បង្រៀន៖ គ្រូបង្រៀនភាគច្រើនសុទ្ធតែមានបទពិសោធន៍បង្រៀនលើសពី១៥ឆ្នាំ ចំនួន ៤០% គ្រូបង្រៀនដែលភាគតិចមានបទពិសោធន៍បង្រៀនចន្លោះពី១ដល់ ៥ ឆ្នាំ មានចំនួន២០%។ ក្រៅពីនេះគឺគ្រូដែលមានបទពិសោធន៍បង្រៀនចន្លោះពី ៦ ដល់ ១០ ឆ្នាំ ចំនួន២០% និង បទពិសោធន៍បង្រៀនចន្លោះពី ១១ ដល់ ១៥ ឆ្នាំ ចំនួន២០%។

មុខវិជ្ជាឯកទេស៖ គ្រូបង្រៀនភាគច្រើនមានមុខវិជ្ជាឯកទេសភាសាអង់គ្លេស មានចំនួន ៨០% និង គ្រូបង្រៀនភាគតិចមានមុខវិជ្ជាឯកទេសភាសាអង់គ្លេសនិងភាសាខ្មែរ ចំនួន១០% និង ភាសាអង់គ្លេស+ICT និង ភាសាអង់គ្លេសនិងអប់រំ ចំនួន ១០%។

### ៤.១.១.២.ព័ត៌មានទូទៅពីសិស្ស

តារាង៤.២ ទិន្នន័យព័ត៌មានទូទៅពីសិស្ស

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ថ្នាក់ | ថ្នាក់ទី១០ | ៧០ | ៣៧% |
| | | ថ្នាក់ទី១១ | ៦៤ | ៣៤% |
| | | ថ្នាក់ទី១២ | ៥៦ | ២៩% |
| | | **សរុប** | **១៩០** | **១០០%** |
| ៣ | មកពីវិទ្យាល័យ | ឫស្សីកែវ | ៣០ | ១៦% |
| | | ជាស៊ីមចំរើនរដ្ឋ | ៣០ | ១៦% |
| | | ចំរើនផល | ១០ | ៥% |
| | | ទួលទំពូង | ៣០ | ១៦% |
| | | សំរោង | ៣០ | ១៦% |
| | | ព្រែកលៀប | ៣០ | ១៦% |
| | | បាក់ទូក | ៣០ | ១៦% |

| | | | | |
|---|---|---|---|---|
| | | **សរុប** | **១៩០** | **១00%** |
| ២ | ភេទ | ប្រុស | ៨០ | ៤២% |
| | | ស្រី | ១១០ | ៥៨% |
| | | **សរុប** | ១៩០ | ១00% |
| ៤ | កម្រិតភាសាអង់គ្លេស | ខ្សោយ | ៣៤ | ១៨% |
| | | មធ្យម | ១៥១ | ៨0% |
| | | ល្អ | ៥ | ២% |
| | | **សរុប** | **១៩០** | **១00%** |

តាមតារាង ៤.២ បានបង្ហាញថា៖

ថ្នាក់៖ សិស្សថ្នាក់ទី១០ មានចំនួន៧០នាក់ស្មើ៣៧% និងសិស្សថ្នាក់ទី១១ មានចំនួន៦៤នាក់ស្មើ៣៤% និងសិស្សថ្នាក់ទី១២មានចំនួន៥៦នាក់ស្មើ២៩%។

មកពីវិទ្យាល័យ៖ សិស្សមកពី វិទ្យាល័យឫស្សីកែវមានចំនួន៣០នាក់ស្មើ១៦% សិស្សមកពីវិទ្យាល័យជាស៊ីមចំរើនរដ្ឋមានចំនួន៣០នាក់ស្មើ១៦% សិស្សមកពីវិទ្យាល័យចំរើនផលមានចំនួន១០នាក់ស្មើ៥% សិស្សមកពីវិទ្យាល័យទួលទំពូងមានចំនួន៣០នាក់ស្មើ១៦% សិស្សមកពីវិទ្យាល័យសអគ្គមហាសេនាតេជោហ៊ុនសែនសំរោងមានចំនួន៣០នាក់ស្មើ១៦% សិស្សមកពីវិទ្យាល័យព្រែកលៀបមានចំនួន៣០នាក់ស្មើ១៦% សិស្សមកពីវិទ្យាល័យបាក់ទូកមានចំនួន៣០នាក់ស្មើ១៦%។

ភេទ៖ សិស្សភេទប្រុសមានចំនួន ៤០% នៃចំនួនសរុប១៩០នាក់ ក្រៅពីនេះជាសិស្សភេទស្រីចំនួន៦០%។

កម្រិតភាសាបរទេស៖ សិស្សភាគច្រើនមានកម្រិតភាសាបរទេស "មធ្យម" មានចំនួន១៥១នាក់ស្មើ៨០% និង "ខ្សោយ" មានចំនួន៣៤នាក់ស្មើ ១៨% រីឯ "ល្អ" មានចំនួន៥នាក់ ស្មើ២%។

### ៤.១.១.៣.ព័ត៌មានទូទៅពីគណៈគ្រប់គ្រង

តារាង៤.៣ ទិន្នន័យព័ត៌មានទូទៅពីគណៈគ្រប់គ្រង

| ល.រ | បរិយាយ | | វិទ្យាល័យ | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ឬស្សីកែវ | ជាស៊ីមចំរើនរដ្ឋ | ចំរើនផល | ទួលទំពូង | អ. សំរោង | ព្រៃកលៀប | បាក់ទូក | សរុប | ភាគរយ |
| ១ | ភេទ | ប្រុស | ២ | ២ | ១ | ២ | ២ | ១ | ២ | ១២ | ៩២% |
| | | ស្រី | ០ | ០ | ០ | ០ | ០ | ១ | ០ | ១ | ៨% |
| | | **សរុប** | **២** | **២** | **១** | **២** | **២** | **២** | **២** | **១៣** | **១០០%** |
| ២ | អាយុ | ២៥ - ៣០ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០% |
| | | ៣១ - ៣៥ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០% |
| | | ៣៦ - ៤០ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ១ | ០ | ១ | ៨% |
| | | លើសពី ៤០ឆ្នាំ | ២ | ២ | ១ | ២ | ២ | ១ | ២ | ១២ | ៩២% |
| | | **សរុប** | **២** | **២** | **១** | **២** | **២** | **២** | **២** | **១៣** | **១០០%** |
| ៣ | កម្រិតសញ្ញាបត្រ | បរិញ្ញាបត្រជាន់ខ្ពស់ | ២ | ១ | ១ | ១ | ២ | ១ | ០ | ៨ | ៦២% |
| | | បរិញ្ញាបត្រ | ០ | ១ | ០ | ០ | ០ | ១ | ១ | ៣ | ២៣% |
| | | ចប់ថ្នាក់ទី១២ | ០ | ០ | ០ | ១ | ០ | ០ | ១ | ២ | ១៦% |
| | | **សរុប** | **២** | **២** | **១** | **២** | **២** | **២** | **២** | **១៣** | **១០០%** |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០% |
| | | ៦ ដល់ ១០ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ១ | ០ | ១ | ៨% |
| | | ១១ ដល់ ១៥ ឆ្នាំ | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ៨% |
| | | លើសពី ១៥ឆ្នាំ | ២ | ២ | ១ | ២ | ២ | ១ | ១ | ១១ | ៨៤% |
| | | **សរុប** | **២** | **២** | **១** | **២** | **២** | **២** | **២** | **១៣** | **១០០%** |

តាមតារាង ៤.៣ បង្ហាញថាពីការឆ្លើយតបរបស់គណៈគ្រប់គ្រង៖

ភេទ៖ គណៈគ្រប់គ្រងមានភេទប្រុសចំនួន១២នាក់ស្មើនឹង ៩២% នៃចំនួនសរុប ១៣នាក់ ក្រៅពីនេះមានគណៈគ្រប់គ្រងចំនួន០១នាក់ជាភេទស្រី ស្មើនឹង០៨%។

អាយុ៖ គណៈគ្រប់គ្រងភាគច្រើន មានអាយុលើសពី ៤០ឆ្នាំចំនួន១២នាក់ស្មើនឹង ៩២%និង គណៈគ្រប់គ្រងមានអាយុចន្លោះពី ៣៦ ដល់ ៤០ ឆ្នាំចំនួន០១នាក់ ស្មើនឹង ០៨%។

កម្រិតសញ្ញាបត្រ៖ គណៈគ្រប់គ្រងភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន០៨នាក់ស្មើ៦២%។ រីឯគណៈគ្រប់គ្រងភាគតិចមានសញ្ញាបត្រចប់ថ្នាក់ទី១២មានចំនួន០២នាក់ស្មើ១៥%។ ក្រៅពីនេះគឺគណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រ មានចំនួន០៣នាក់ស្មើ២៣%។

បទពិសោធន៍៖ គណៈគ្រប់គ្រងភាគច្រើនសុទ្ធតែមានបទពិសោធន៍បង្រៀនយូរឆ្នាំ ក្នុងនោះលើសពី ១៥ឆ្នាំ មានចំនួន១១នាក់ស្មើ៨៤% គណៈគ្រប់គ្រងភាគតិចដែលមានបទពិសោធន៍គឺចន្លោះពី ៦ ដល់ ១ឆ្នាំ មានចំនួន០១នាក់ស្មើ៨% និង មានបទពិសោធន៍ពីចន្លោះ១០ដល់១៥ឆ្នាំ មានចំនួន០១នាក់ស្មើ ៨%។

## ៤.២.ការប្រើប្រាស់វិធីសាស្ត្របង្រៀននិងរៀនបំណិនស្តាប់ភាសាអង់គ្លេស

### ៤.២.១.និន្នន័យការឆ្លើយតបរបស់គណៈគ្រប់គ្រងលើការគ្រប់គ្រងនិងដឹកនាំលើការបង្រៀនភាសាអង់គ្លេស

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃ

សូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, ១៩៨១)៖

១.00 – ១.៨០ មានន័យថា ខ្សោយខ្លាំង

១.៨១ – ២.៦០ មានន័យថា ខ្សោយ

២.៦១ – ៣.៤០ មានន័យថា មធ្យម

៣.៤១ – ៤.២០ មានន័យថា ល្អ

៤.២១ – ៥.០០ មានន័យថា ល្អណាស់

តារាង៤.៤ ការគ្រប់គ្រងនិងតាមដានគ្រូបង្រៀនភាសាអង់គ្លេស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | បានចូលរួមផ្នាក់និទស្សន៍របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៣៦ | ០.៨៧ | **មធ្យម** |
| ២ | ធ្វើការតាមដាន និងវាយតម្លៃលើលោកគ្រូ-អ្នកគ្រូបានបង្រៀនបំណិនស្តាប់តាមរយៈប្រធាន/អនុប្រធានក្រុមបច្ចេកទេសភាសាអង់គ្លេស។ | ៣.៨៥ | ០.៨០ | **ល្អ** |
| ៣ | បានផ្តល់និងផ្គត់ផ្គង់សម្ភារឧបទេសតាមសំណើរបស់លោកគ្រូ-អ្នកគ្រូបង្រៀនភាសាអង់គ្លេសដើម្បីជួយគាំទ្រការរៀនបំណិនស្តាប់។ | ៣.៤៦ | ១.១២ | **ល្អ** |
| ៤ | ផ្តល់បន្ទប់ទំនេរសម្រាប់ធ្វើជាបន្ទប់ស្តាប់ និងរៀនភាសាអង់គ្លេស។ | ២.៦២ | ១.៣២ | **មធ្យម** |
| ៥ | បានផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធឺណេតដល់លោកគ្រូ-អ្នកគ្រូនិងសិស្សប្រើសម្រាប់បំណិនស្តាប់ក្នុងថ្នាក់។ | ២.៧៧ | ១.១១ | **មធ្យម** |
| ៦ | លើកទឹកចិត្ត លោកគ្រូ-អ្នកគ្រូនិងសិស្សឱ្យចូលចិត្តអនុវត្តការស្តាប់ភាសាអង់គ្លេសតាមរយៈ ស្តាប់ព័ត៌មាន ចម្រៀង រឿងភាគ រឿងខ្លី ជាភាសាអង់គ្លេសក្នុងថ្នាក់។ | ៣.៣១ | ០.៨៥ | **មធ្យម** |
| ៧ | លើកទឹកចិត្តលោកគ្រូ-អ្នកគ្រូ បង្កើតសម្ភារៈឧបទេសដែលមានស្រាប់( Smart phone, Speaker )សម្រាប់ដោនលោតអត្ថបទស្តាប់ | ៣.៥៤ | ០.៩០ | **ល្អ** |

| | | | | |
|---|---|---|---|---|
| | website របស់ក្រសួងអប់រំ យុវជននិ ងកីឡា ជួយការបង្រៀន បំណិនស្ដាប់។ | | | |
| | **សរុប** | **៣.២៧** | **០.៩៩** | **មធ្យម** |

នៅក្នុងតារាង៤.៤ ទិន្នន័យនេះបង្ហាញពីមធ្យមភាគនៃការគ្រប់គ្រងនិងតាមដានរបស់គណៈគ្រប់គ្រងទៅលើការបង្រៀនបំណិនស្ដាប់ភាសាអង់គ្លេស របស់គ្រូនៅមធ្យមសិក្សាទុតិយភូមិក្នុងរាជធានីភ្នំពេញគឺទទួលបានការយល់ស្របក្នុងកម្រិត " មធ្យម " (មធ្យមភាគ=៣.២៧)។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៨៥) គឺ " ធ្វើការតាមដាន និងវាយតម្លៃលើលោកគ្រូ-អ្នកគ្រូបង្រៀនបំណិនស្ដាប់ តាមរយៈប្រធាន/អនុប្រធានក្រុមបច្ចេកទេសភាសាអង់គ្លេស។ ដោយឡែកសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម " (មធ្យមភាគ= ២.៧៧ )គឺ" ផ្ដល់បន្ទប់ទំនេរសម្រាប់ធ្វើជាបន្ទប់ស្ដាប់ និងរៀនភាសាអង់គ្លេស"។

តាមរយៈការឆ្លើយតបរបស់គណៈគ្រប់គ្រងភាគច្រើន បានបង្ហាញពីការចូលរួមក្នុងការតាមដាន និងវាយតម្លៃព្រមទាំងលើកទឹកចិត្តនិងជំរុញលើការបង្រៀនរបស់គ្រូភាសាអង់គ្លេស តាមរយៈការចូលរួមថ្នាក់និទស្សន៍ និងប្រជុំក្រុមបច្ចេកទេសដោយយកចិត្តទុកដាក់បានល្អ។ ដោយឡែកការផ្គត់ផ្គង់សម្ភារឧបទេសទៅលើមុខវិជ្ជាភាសាអង់គ្លេស ជាពិសេសសម្ភារៈទ្រទ្រង់ការបង្រៀននិងរៀនបំណិនស្ដាប់ភាសាអង់គ្លេសដូចជា ម៉ាញេចាក់ការសែតកា សែតសម្លេង ថាសសម្លេង(CD, VCD) ឧបករណ៍បំប៉ងសម្លេង មិនតែប៉ុណ្ណោះសាលាមិនទាន់មានបន្ទប់សោតទស្សន៍ភាសាបរទេសសម្រាប់គ្រូបង្រៀន និងសិស្ស ដែលមានសារៈសំខាន់ក្នុងការហាត់ស្ដាប់សម្លេង និងបណ្ណាល័យនៅខ្វះសៀវភៅអានភាសាអង់គ្លេសសម្រាប់សិក្សាស្រាវជ្រាវបន្ថែម នៅមានកម្រិតមធ្យមមិនទាន់គ្រប់គ្រាន់ទៅតាមតម្រូវការរបស់គ្រូបង្រៀន ដែលមានភាពចាំបាច់ជួយគាំទ្រក្នុងការបង្រៀននិងពង្រឹងការស្ដាប់បាននៅឡើយទេ។

## ៤.២.២.ទិន្នន័យការឆ្លើយតបរបស់គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀន

### ក. វិធីសាស្ត្របង្រៀនបំណិនស្តាប់ភាសាអង់គ្លេស

តារាង ៤.៥ ការប្រើវិធីសាស្ត្របង្រៀនបំណិនស្តាប់

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | ប្រើពាក្យ និងឃ្លាសាមញ្ញក្នុងជីវភាពប្រើប្រាស់ប្រចាំថ្ងៃដើម្បីសិស្សងាយយល់ (Direct method)។ | ៣.៦០ | ០.៨២ | ល្អ |
| ២ | គ្រូពន្យល់ណែនាំសិស្សកំពុងបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ដោយបកប្រែជាភាសាខ្មែរ (Translation method)។ | ៣.០៥ | ០.៩០ | មធ្យម |
| ៣ | គ្រូឱ្យសិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការចាក់កាសែត (Critical Listening method)។ | ២.៨០ | ០.៧៦ | មធ្យម |
| ៤ | គ្រូអានអត្ថបទផ្ទាល់សម្រាប់សិស្សស្តាប់សម្រាប់បំណិនស្តាប់ (The Audio Lingual method)។ | ៣.០០ | ០.៧១ | មធ្យម |
| ៥ | គ្រូឱ្យសិស្សពិភាក្សាគ្នាជាដៃគូរ ឬក្រុម ជាភាសាអង់គ្លេស(students Centre)។ | ៣.៦០ | ០.៥១ | ល្អ |
| ៦ | គ្រូឱ្យសិស្សស្តាប់ដោយការយល់ហើយឆ្លើយសំណួរ សំណួរពិត ឬមិនពិត ផ្គូរផ្គង សំណួរជ្រើសរើស (Comprehensive listening Method)។ | ៤.១០ | ០.៦២ | ល្អ |
| ៧ | គ្រូចាក់អត្ថបទស្តាប់ដោយ កាសែត CD ក្នុងបន្ទប់រៀន។ | ២.៩៥ | ០.៩០ | មធ្យម |
| | **សរុប** | **៣.៤៨** | **០.៧៥** | **ល្អ** |

តារាង៤.៥ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើការប្រើប្រាស់វិធីសាស្រ្តបង្រៀនបំណិនស្តាប់ភាសាអង់គ្លេសរបស់គ្រូបង្រៀន ដែលជ្រើសរើសវិធីសាស្រ្តបង្រៀនឱ្យសមស្របទៅនឹងសមត្ថភាពសិស្សរៀនមុខវិជ្ជាភាសាអង់គ្លេសលើបំណិនស្តាប់នៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ គឺទទួលបានការយល់ស្របក្នុងកម្រិត " ល្អ " (មធ្យមភាគ= ៣.៤៨ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៤.១០) គឺ "គ្រូឱ្យសិស្សស្តាប់ដោយការយល់ហើយឆ្លើយសំណួរសំណួរពិត ឬមិនពិត ផ្គូរផ្គង សំណួរជ្រើសរើស(Comprehensive listening Method)" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "មធ្យម" (មធ្យមភាគ= ២.៨០ )គឺ "ឱ្យសិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការចាក់កាសែត ( Critical Listening method)"។

តាមទិន្នន័យសរុប បង្ហាញពីការអនុវត្តន៍វិធីសាស្រ្តបង្រៀនបំណិនស្តាប់របស់គ្រូបង្រៀនភាគច្រើនប្រើ វិធីសាស្រ្តCLM និងDM ដែលអាចប្រើសម្ភារបង្រៀនងាយរកបាន រីឯវិធីសាស្រ្ត ALM ត្រូវប្រើសម្ភារបង្រៀន ដូចជាមាញ៉េកាសែត ការសែតសម្លេង ថាសសម្លេង(CD, VCD) ឧបករណ៍បំប៉ងសម្លេង ដែលនៅមានការខ្វះខាតនាំឱ្យការបង្រៀន និងរៀនមិនទាន់បានមានប្រសិទ្ធភាព ដោយសារតែគ្រូភាគច្រើនប្រើវិធីសាស្រ្តអានឱ្យសិស្សស្តាប់លើបំណិនស្តាប់ ដែលចាំបាច់ត្រូវប្រើសម្ភារឧបទេសជាជំនួយដល់ការអនុវត្តការបញ្ចេញសម្លេងរបស់ម្ចាស់ភាសាដើមកំណើត ទន្ទឹមនឹងនោះគ្រូបង្រៀនគួរគប្បីចូលរួមក្នុងការបង្រៀនដោយគោរពក្រមសីលធម៌វិជ្ជាជីវៈនិងខិតខំប្រឹងប្រែងនិងបំពេញតួនាទីរបស់ខ្លួន ដើម្បីសម្រេចគោលដៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ និងលទ្ធផលសិក្សារបស់សិស្សឱ្យមានភាពប្រសើរឡើង។

**ខ.ការប្រើប្រាស់សម្ភារឧបទ្ទេស**

តារាង ៤.៦ ការប្រើប្រាស់សម្ភារឧបទេសជំនួយដល់ការបង្រៀន

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | លោកគ្រូ-អ្នកគ្រូ បានប្រើប្រាស់សម្ភារឧបទេសរាល់ពេលបង្រៀនបំណិនស្តាប់ភាសាអង់គ្លេសក្នុងថ្នាក់។ | ៣.៦៥ | ១.១៣ | ល្អ |
| ២ | លោកគ្រូ-អ្នកគ្រូប្រើសៀវភៅសិក្សាគោល English For Cambodia ( EFC ) តែមួយប៉ុណ្ណោះ។ | ៣.៧៥ | ១.២៥ | ល្អ |
| ៣ | លោកគ្រូ-អ្នកគ្រូមានចំណាប់អារម្មណ៍ខ្លាំងលើភៅសិក្សាគោល English For Cambodia ( EFC )។ | ៣.១៥ | ១.២៦ | មធ្យម |
| ៤ | លោកគ្រូ-អ្នកគ្រូបានចាក់កាសែតឱ្យសិស្សស្តាប់អត្ថបទភាសាអង់គ្លេសក្នុងថ្នាក់រៀនញឹកញាប់។ | ២.៩៥ | ១.៣៦ | មធ្យម |
| ៥ | លោកគ្រូ-អ្នកគ្រូបានបង្កើតសម្ភារឧបទេសជំនួយក្នុងការបង្រៀនដូចជា ពាក្យកាត់ ផ្ទាំងរូបភាពតូច-ធំ cassette player radio DVD Video clip ជាភាសាអង់គ្លេស។ | ៣.១០ | ១.០១ | មធ្យម |
| | **សរុប** | **៣.៣១** | **១.០២** | **មធ្យម** |

តារាង៤.៦ខាងលើ បានបង្ហាញពីមធ្យមភាគទៅលើការប្រើប្រាស់សម្ភារឧបទ្ទេសដើម្បីគាំទ្រការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់គ្រូបង្រៀន ដែលឆ្លុះបញ្ចាំងពីការបង្រៀននិងការប្រើសម្ភារឧបទេសជំនួយក្នុងការបង្រៀនបំណិនស្តាប់នៅមធ្យមសិក្សាទុតិយភូមិ រាជធានីភ្នំពេញ គឺទទួលបានការយល់ស្របក្នុងកម្រិត " មធ្យម " (មធ្យមភាគ= ៣.៣១ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "មធ្យម" ( មធ្យមភាគ= ៣.៧៥ ) គឺ " លោកគ្រូ-អ្នកគ្រូប្រើសៀវភៅសិក្សាគោល English For Cambodia ( EFC ) តែមួយប៉ុណ្ណោះ" និងសូចនាករដែលទទួលបានការយល់ស្របទាបជាង

គេក្នុងកម្រិត " មធ្យម " (មធ្យមភាគ= ២.៩៥ )គឺ" លោកគ្រូ-អ្នកគ្រូបានចាក់កាសែតឱ្យសិស្សស្តាប់អត្ថបទភាសាអង់គ្លេសក្នុងថ្នាក់រៀនញឹកញាប់។

សរុបលើការឆ្លើយតបរបស់គ្រូបង្ហាញពីការប្រើប្រាស់សម្ភារឧបទេសទ្រទ្រង់ការបង្រៀន នៅមានកម្រិតមធ្យមទុតិយភូមិរាជធានីភ្នំពេញ នៅមានកម្រិតមិនទាន់គ្រប់គ្រាន់ និងទាន់ពេលទៅលើសម្ភារៈបង្រៀនដូចជា ម៉ាញេចាក់កាសែត កាសែតសម្លេង ថាសសម្លេង(CD, VCD) និងឧបករណ៍បំប៉ងសំលេង ដែលមានភាពចាំបាច់សម្រាប់ប្រើប្រាស់ក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលដល់ការស្តាប់ចំពោះការហ្វឹកហាត់ផ្ទាល់តុង សម្លេងភាសាដើមកំណើតទី១ដល់សិស្សរៀនភាសាភាសាអង់គ្លេសដែលជាភាសាទីពីរ។ យោងតាមការស្រាវជ្រាវរបស់លោក Richard (2005)បានបញ្ជាក់ថាសំភារឧបទ្ទេសសំរាប់ការបង្រៀន និងរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសមានសារប្រយោជន៍ (Solak, April 2016) ដែលជាហេតុផលគ្រូបង្រៀនចាំបាច់ប្រើប្រាស់សម្ភារឧបទេសជួយទ្រទ្រង់ការបង្រៀននិងរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស។ បន្ថែមពីនេះស្របតាមការលើកឡើងរបស់ក្រសួងអប់រំ យុវជន និងកីឡា គ្រូត្រូវឱ្យសិស្សសង្កេត ពិចារណា ពិភាក្សា និងហាត់ប្រើសម្ភារៈដោយខ្លួនឯង ដើម្បីយល់ច្បាស់ពីខ្លឹមសារបង្រៀន។ កត្តាសំខាន់គ្រូត្រូវកំណត់សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ទៅតាមតម្រូវការនៃមេរៀននីមួយៗ (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)។

### គ.ការជំរុញនិងលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់

**តារាង ៤.៧ ការជំរុញនិងលើកទឹកចិត្ត**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | លោកគ្រូ-អ្នកគ្រូ ផ្តល់យុទ្ធវិធីក្នុងការបង្កើនចំណេះដឹងការស្តាប់បានល្អប្រសើរជាងមុន។ | ៣.៦០ | ០.៦៨ | ល្អ |
| ២ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សឱ្យចូលចិត្តអនុវត្តការស្តាប់ភាសាអង់គ្លេសតាមរយៈ ស្តាប់ព័ត៌មាន ចំរៀង រឿងភាគ រឿងខ្លី ជាភាសាអង់គ្លេស។ | ៣.៨៥ | ០.៩៣ | ល្អ |

| | | | | |
|---|---|---|---|---|
| ៣ | លោកគ្រូ-អ្នកគ្រូ បានផ្តល់កំណែ/ព័ត៌មានត្រឡប់ទៅសិស្សវិញក្រោយពីការប្រគល់កិច្ចការនៅផ្ទះ។ | ៤.០៥ | ០.៧៥ | ល្អ |
| ៤ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សដោយការសរសើរ (បណ្ណសរសើរ ពាក្យសរសើរ)។ | ៣.០០ | ០.៦៤ | មធ្យម |
| ៥ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សដោយការសរសើរការ ផ្តល់រង្វាន់។ | ៣.១៥ | ០.៩៨ | មធ្យម |
| | **សរុប** | **៣.៥៣** | **០.៧៩** | **ល្អ** |

តារាង៤.៧ខាងលើ បានបង្ហាញពីមធ្យមភាគ ទៅលើការជំរុញលើកទឹកចិត្តរបស់គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើន មានមតិយល់ស្រប ក្នុងកម្រិត"ល្អ" (មធ្យមភាគ ៣.៥៣)។ សូចនាករដែលមានកម្រិតយល់ស្របជាងគេ ក្នុកម្រិតល្អ (មធ្យមភាគ=៤.០៥) គឺ "លោកគ្រូ-អ្នកគ្រូ បានផ្តល់កំណែ/ព័ត៌មានត្រឡប់ទៅសិស្សវិញក្រោយពីការប្រគល់កិច្ចការនៅផ្ទះ" ដោយឡែកសូចនាករដែលមានកម្រិតទាបជាងគេក្នុងកម្រិត "មធ្យម" (មធ្យមភាគ ៣.០)"លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សដោយការសរសើរ (បណ្ណសរសើរ ពាក្យសរសើរ)"។

សរុបទិន្នន័យតាមរយៈការឆ្លើយតបរបស់គ្រូ ដែលបង្ហាញឱ្យឃើញថាការជំរុញនិងលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់ក្នុងកម្រិត "ល្អ" បង្ហាញពីគ្រូបង្រៀនបានប្រើវិធីសាស្ត្រ ផ្តល់ព័ត៌មានត្រឡប់ទៅឱ្យសិស្សបានញឹកញាប់ទៅលើសន្លឹកកិច្ចការ ក៏ដូចជាផ្តល់កំណែដល់កិច្ចការនៅផ្ទះ និងលើកទឹកចិត្តសិស្សឱ្យចូលចិត្តអនុវត្តការស្តាប់ភាសាអង់គ្លេសតាមរយៈ ស្តាប់ព័ត៌មាន ចំរៀង រឿងភាគ រឿងខ្លី ជាភាសាអង់គ្លេសដើម្បីហ្វឹកហាត់ស្តាប់ការបញ្ចេញសម្លេងនិងយល់ពីខ្លឹមសារ។ លើសពីនេះទៅទៀតគ្រូបានផ្តល់យុទ្ធវិធីរៀន និងជួយពង្រឹងសិស្សឱ្យសិស្សចូលចិត្តរៀនបំណិនស្តាប់នៅក្នុងសាលារដ្ឋផងដែរ។ គ្រូខិតខំប្រឹងប្រែង ការយកចិត្តទុកដាក់ចំពោះសិស្សទៅលើការរៀនសូត្ររបស់សិស្សដោយលើកទឹកចិត្ត និងជួយជំរុញដល់សិស្សឱ្យស្រឡាញ់ពេញចិត្តរៀនមុខវិជ្ជាភាសាអង់គ្លេស។

## ឃ.សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់

តារាង៤.៨ ការយល់ឃើញរបស់គ្រូនៃសារប្រយោជន៍ការរៀននិងបង្រៀនសមត្ថភាពស្តាប់

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | អ្នកស្តាប់បានល្អនោះអ្នកនឹងក្លាយជាអ្នកនិយាយមានការពិនប្រសព្វនិយាយ។ | ៤.០៥ | ០.៧៥ | ល្អ |
| ២ | ការស្តាប់បានល្អ អ្នកមានភាពងាយស្រួលក្នុងការទំនាក់ ទំនង។ | ៤.២០ | ០.៨៣ | ល្អ |
| ៣ | អ្នកចេះភាសាអង់គ្លេសព្រមទាំងស្តាប់បានមានឱកាសការងារល្អ។ | ៤.៥៥ | ០.៦០ | ល្អ |
| | **សរុប** | **៤.២៦** | **០.៧៣** | **ល្អ** |

តារាង៤.៨ ខាងលើបានបង្ហាញពីមធ្យមភាគសរុបដែលសំដៅពីសារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ដែលមានគ្រូភាគច្រើនយល់ស្របក្នុងកម្រិត ″ល្អ″ (មធ្យមភាគ=៤.២៦)។សូចនាករដែលមានកម្រិតយល់ស្របជាងគេ ក្នុងកម្រិតល្អ (មធ្យមភាគ=៤.៥៥) គឺ "អ្នកចេះភាសាអង់គ្លេសព្រមទាំងស្តាប់បានមានឱកាសការងារល្អ″ ដោយឡែកសូចនាករដែលមានកម្រិតទាបជាងគេ ក្នុងកម្រិត មធ្យម (មធ្យមភាគ=៤.០) គឺ "អ្នកស្តាប់បានល្អនោះអ្នកនឹងក្លាយជាអ្នកមានការពិនប្រសព្វនិយាយ″។

សរុបការឆ្លើយតបរបស់គ្រូបង្រៀនពីការយល់ឃើញពីសារប្រយោជន៍នៃការរៀននិងបង្រៀនបំណិនស្តាប់ភាសាអង់គ្លេសមានកម្រិត"ល្អ" ដែលជាគោលគំនិតជួយដល់គ្រូណែនាំដល់សិស្សពីសារប្រយោជន៍ និងផ្តល់ការលើកទឹកចិត្តសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រ និងទទួលបានលទ្ធផលល្អប្រសើរស្របតាមលោកRost (1991)បង្ហាញពីសារៈសំខាន់ការស្តាប់ភាសាអង់គ្លេសជាភាសាទីពីរ។ ទន្ទឹងនឹងនោះសិស្សអាចយកចំណេះដឹងភាសាអង់គ្លេស ទៅប្រើប្រាស់ក្នុងការសិក្សារៀនសូត្របន្តនៅកម្រិតឧត្តមសិក្សា ឬបន្តការសិក្សានៅក្រៅប្រទេស និងទៅបំរើការងារ ដែលត្រូវការភាសាអង់គ្លេសបានដោយជោគជ័យ។

### ៤.២.៤ ទិន្នន័យសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន

**តារាង៤.៩ ទិន្នន័យសរុបនៃការឆ្លើយតបរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ក | វិធីសាស្ត្របង្រៀនបំណិនស្តាប់ភាសាអង់គ្លេស | ៣.៤៨ | ០.៧៥ | ល្អ |
| ខ | ការប្រើប្រាស់សម្ភារឧបទ្ទេស | ៣.៣១ | ១.០២ | មធ្យម |
| គ | ការជំរុញនិងលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់ | ៣.៥៣ | ០.៧៩ | ល្អ |
| ឃ | សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ | ៤.២៦ | ០.៧៣ | ល្អ |
| | **សរុប** | **៣.៦៥** | **០.៨២** | **ល្អ** |

តារាង៤.៩ ខាងលើបានបង្ហាញថាពីមធ្យមភាគ ទៅលើទិន្នន័យសរុបរបស់គ្រូបង្រៀនដែលមានមតិយល់ស្របទៅលើការប្រើប្រាស់វិធីសាស្ត្របង្រៀន ដែលជួយដល់សិស្សក្នុងការរៀនបំណិនស្តាប់ភាសាអង់គ្លេស ក៏ដូចជាការប្រើសម្ភារៈបង្រៀនតាមលទ្ធភាពដែលអាចធ្វើទៅបាន ព្រមទាំងប្រើការជំរុញនិងលើកទឹកចិត្តសិស្សឱ្យរៀនភាសាអង់គ្លេស ក្នុងកម្រិត"ល្អ" (មធ្យមភាគ ៣.៦៥)។ សូចនាករដែលមានកម្រិតយល់ស្របកម្រិតល្អ (មធ្យមភាគ=៤.២៦) គឺ "សារប្រយោជន៍នៃការរៀននិងបង្រៀនសមត្ថភាពស្តាប់" និង (មធ្យមភាគ=៣.៥៥) "ការជំរុញនិងលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់"។ ដោយឡែកសូចនាករដែលមានកម្រិតទាបជាងគេ ក្នុងកម្រិត មធ្យម (មធ្យមភាគ=៣.៤៨) គឺ "វិធីសាស្ត្របង្រៀនបំណិនស្តាប់ភាសាអង់គ្លេស"។ ក្នុងន័យនេះគ្រូបង្រៀនបានប្រឹងប្រែងបំពេញភារកិច្ច និងតួនាទីក្នុងការផ្ទេរចំណេះដឹង ទោះបីការផ្គត់ផ្គង់សម្ភារឧបទេសដូចជា ម៉ាញេកាសែត កាសែតសម្លេង ថាសសម្លេង CD និង VCD បន្ទប់សោតទស្សន៍ភាសាដែលសំខាន់ក្នុងការបង្រៀនសមត្ថភាពស្តាប់ នៅមានកម្រិតនៅឡើយ ដែលជាការនាំឱ្យជះឥទ្ធិពលដល់ការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស។ ទោះបីជាយ៉ាងណាក្តី ក៏គ្រូបង្រៀននៅតែបន្តការបង្រៀនបានល្អដោយប្រើវិធីសាស្ត្របង្រៀនដែលសម

ស្របទៅនឹងសមត្ថភាពចំណេះដឹងសិស្ស និងប្រើសម្ភារឧបទេសទៅតាមលទ្ធភាពដែលអាចបង្កើតបានខ្លួនឯងបាននិងប្រើប្រាស់ឱ្យអស់ពីលទ្ធភាព។

## ៤.២.៣.ទិន្នន័យការឆ្លើយតបរបស់សិស្សប្រើប្រាស់វិធីសាស្ត្ររៀន

### ក.វិធីសាស្ត្ររៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស

តារាង ៤.១០ វិធីសាស្ត្ររៀនសមត្ថភាពស្តាប់ភាសាអង់គ្លេស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | ប្អូនប្រើការទស្សន៍ទាយអត្ថន័យពាក្យពិបាកពេលកំពុងស្តាប់ក្នុងស្ថានភាពជាក់លាក់ពិតប្រាកដ។ (Guessing Method)។ | ៣.២៤ | ០.៨៦ | មធ្យម |
| ២ | ប្អូនប្រើការទស្សន៍ទាយអត្ថន័យខ្លឹមសារអត្ថបទក្រោយពេលស្តាប់អត្ថបទភាសាអង់គ្លេស (Critical thinking)។ | ៣.១៦ | ០.៩១ | មធ្យម |
| ៣ | ប្អូនប្រើវិធីចងចាំនិងការទន្ទេញដើម្បីយកមកអនុវត្តពេលរៀនបំស្តាប់ភាសាអង់គ្លេសនៅក្នុងថ្នាក់។ | ៣.៣៤ | ១.០០ | មធ្យម |
| ៤ | ប្អូនជឿជាក់លើខ្លួនឯងក្នុងការស្តាប់គ្រូនិងមិត្តរួមថ្នាក់និយាយភាសាអង់គ្លេសក្នុងថ្នាក់រៀន។ | ៣.៥៣ | ០.៩០ | ល្អ |
| ៥ | ប្អូនទន្និញពាក្យថ្មីឱ្យចាំមាត់ក្រោយពីរៀនស្តាប់អត្ថបទ។ | ៣.៣១ | ៣.៣៧ | មធ្យម |
| ៦ | ប្អូនពិភាក្សាគ្នាជាដៃគូរ ឬជាក្រុម ជាភាសាអង់គ្លេស។ | ៣.៧៨ | ១.០០ | ល្អ |
| ៧ | ប្អូនចូលរួមសកម្មភាពស្តាប់ និងអានភាសាអង់គ្លេស។ | ៤.០៥ | ១.០២ | ល្អ |
| ៨ | គ្រូដាក់កិច្ចការនៅផ្ទះទាក់ទងនឹងការស្តាប់ជាភាសាអង់គ្លេស ដោយការសរសេរសេចក្តីសង្ខេប។ | ៣.៥៥ | ០.៩១ | ល្អ |

| | | | | |
|---|---|---|---|---|
| ៩ | គ្រូជំរុញប្អូនឱ្យប្អូនស្ដាប់អត្ថបទផ្សេងៗ ជាភាសាអង់គ្លេស ដូចជា ព័ត៌មាន ចម្រៀង រឿងភាគ ។ល។ | ៣.៧៨ | ១.០១ | ល្អ |
| ១០ | បំណិនស្ដាប់ជាជំនាញដែលដាក់ក្នុងការប្រឡងស្តង់ដារអន្តរជាតិ (TOEFL Exam) និង (IELTS)។ | ៣.៣៨ | ១.០២ | មធ្យម |
| **សរុប** | | **៣.៥១** | **០.៩១** | **ល្អ** |

តារាង៤.១០ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើវិធីសាស្ត្ររៀនលើសមត្ថភាពស្ដាប់ភាសាអង់គ្លេសរបស់សិស្សដែលជ្រើសរើសវិធីសាស្ត្រសមស្របនឹងសមត្ថភាពសិស្សដែលឆ្លុះបញ្ចាំងពីយុទ្ធវិធីនៃការរៀន និងឥរិយាបទក្នុងការរៀនបំណិនស្ដាប់នៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ គឺទទួលបានការយល់ស្របក្នុងកម្រិត " ល្អ " (មធ្យមភាគ= ៣.៥១)។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អណាស់" (មធ្យមភាគ= ៤.០៥) គឺ" ប្អូនចូលរួមសកម្មភាពស្ដាប់ និងអាន" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម " (មធ្យមភាគ= ៣.១៦ )គឺ" ប្អូនប្រើការទូសទាយអត្ថន័យខ្លឹមសារអត្ថបទក្រោយពេលស្ដាប់អត្ថបទភាសាអង់គ្លេស(Critical thinking)"។

សរុបទិន្នន័យលើការប្រើប្រាស់វិធីសាស្ត្ររៀនរបស់សិស្សលើបំណិនស្ដាប់បានកម្រិតល្អ ដែលអ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ការអនុវត្តវិធីសាស្ត្ររៀនរបស់សិស្សមានសកម្មភាពចូលរួមក្នុងថ្នាក់ និងបានយល់ដឹងពីយុទ្ធវិធីរៀនដោយក៏ដោយគ្រូបង្រៀនត្រូវពង្រឹងចំណេះដឹងបន្ថែមនិងវិធីសាស្ត្ររៀនលើបំណិនស្ដាប់ភាសាអង់គ្លេសឱ្យកាន់តែមានប្រសិទ្ធភាព.

**ខ.ការប្រើប្រាស់សម្ភារឧបទ្ទេសគាំទ្រការរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស**

តារាង៤.១១ សម្ភារឧបទេស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | ប្អូនចូលចិត្តនិងចាប់អារម្មណ៍លើសៀវភៅសិក្សាគោលEnglish For Cambodia (EFC)។ | ៣.៣៥ | ០.៩០ | មធ្យម |
| ២ | សៀវភៅពុម្ពភាសាអង់គ្លេសមានរូបភាពទាក់ទាញនិងគួរឱ្យចាប់អារម្មណ៍គួរឱ្យចង់រៀន។ | ៣.៦១ | ១.០៤ | ល្អ |
| ៣ | គ្រូបង្រៀនប្រើប្រាស់សម្ភារៈបង្រៀនញឹកញាប់និងទាក់ទាញធ្វើឱ្យប្អូនចូលចិត្តរៀន។ | ៣.៣២ | ១.០០ | មធ្យម |
| ៤ | គ្រូរៀបចំថ្នាក់រៀនសមស្របនឹងសកម្មភាពក្នុងថ្នាក់ពេលរៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៤២ | ១.០០ | ល្អ |
| ៥ | គ្រូតែងតែចាក់អត្ថបទស្តាប់ក្នុងថ្នាក់។ | ៣.២៩ | ១.២២ | មធ្យម |
| | **សរុប** | **៣.៣៩** | **១.០៣** | **មធ្យម** |

តារាង៤.១១ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើការប្រើប្រាស់សម្ភារឧបទ្ទេសដើម្បីគាំទ្រការរៀនរបស់សិស្សទៅលើសមត្ថភាពស្តាប់ភាសាអង់គ្លេស ដែលឆ្លុះបញ្ចាំងពីការរៀននិងប្រើសម្ភារឧបទេសជំនួយក្នុងការរៀនបំណិនស្តាប់នៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ គឺទទួលបានការយល់ស្របក្នុងកម្រិត "មធ្យម " (មធ្យមភាគ= ៣.៣៩ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៦១) គឺ " សៀវភៅពុម្ពភាសាអង់គ្លេសមានរូបភាពទាក់ទាញនិងគួរឱ្យចាប់អារម្មណ៍គួរឱ្យចង់រៀន" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម " (មធ្យមភាគ=៣.២៩ )គឺ" គ្រូតែងតែចាក់អត្ថបទស្តាប់ក្នុងថ្នាក់"។

តាមរយៈទិន្នន័យសរុបតារាង៤.១១ សំដៅទៅលើការការប្រើប្រាស់សម្ភារឧបទេសគាំទ្រការរៀនរបស់សិស្សលើសមត្ថភាពស្តាប់ភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញក្នុងកម្រិតមធ្យមបង្ហាញឱ្យឃើញថា សិស្សបានប្រើប្រាស់សៀវភៅពុម្ព EFC តែមួយតែប៉ុណ្ណោះ រីឯការប្រើប្រាស់ ម៉ាញេ

កាសែត កាសែតសម្លេងសម្រាប់ការស្ដាប់ភាសាអង់គ្លេស ដែលមានសារប្រយោជន៍ក្នុងការអនុវត្តន៍ និងការពង្រឹងសមត្ថភាពស្ដាប់មិនបានញឹកញាប់គ្រប់គ្រាន់នៅឡើយទេ។

### ៤.២.៤.ទិន្នន័យសរុបនៃការឆ្លើយតបរបស់សិស្ស

តារាង ៤.១២ ទិន្នន័យសរុបនៃការឆ្លើយតបរបស់សិស្ស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | វិធីសាស្ត្ររៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស | ៣.៥១ | ០.៩១ | ល្អ |
| ២ | ការប្រើប្រាស់សម្ភារឧបទ្ទេសគាំទ្រការរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស | ៣.៣៩ | ១.០៣ | មធ្យម |
| | **សរុប** | **៣.៤៥** | **០.៩៧** | **ល្អ** |

តារាង៤.១២ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើការប្រើប្រាស់វិធីរៀន តាមរយៈការឆ្លើយតបរបស់សិស្សលើសមត្ថភាពស្ដាប់ភាសាអង់គ្លេស ដែលឆ្លុះបញ្ចាំងវិធីសាស្ត្ររៀន និងការប្រើសម្ភារឧបទេសជំនួយក្នុងការរៀនបំណិនស្ដាប់របស់សិស្សនៅមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ ទទួលបានការយល់ស្របក្នុងកម្រិត " ល្អ" (មធ្យមភាគ=៣.៤៥ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ=៣.៥១) គឺ "វិធីសាស្ត្ររៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស" និង សូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម " (មធ្យមភាគ=៣.២៩ )គឺ "ការប្រើប្រាស់សម្ភារឧបទ្ទេសគាំទ្រការរៀនសមត្ថភាពស្ដាប់ភាសាអង់គ្លេស"

### ៤.២.៥.សរុបទិន្ន័យការប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀនបំណិនស្ដាប់ភាសាអង់គ្លេស

តារាង៤.១៣ ទិន្ន័យសរុបការប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀនបំណិនស្ដាប់ភាសាអង់គ្លេស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបការគ្រប់គ្រងនិងតាមដានរបស់ គណៈគ្រប់គ្រងលើវិធីសាស្រ្តរៀននិងបង្រៀន។ | ៣.២៧ | ០.៩៩ | មធ្យម |
| ២ | ទិន្នន័យសរុបវិធីសាស្រ្តបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៥១ | ០.៨២ | ល្អ |
| ៣ | ទិន្នន័យសរុបវិធីសាស្រ្តរៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៤៥ | ០.៩៧ | ល្អ |
| | **សរុប** | **៣.៤០** | **០.៩២** | **មធ្យម** |

តាមតារាង ៤.១៣ ទិន្នន័យសរុបពីឆ្លើយតបរបស់គ្រូបង្រៀននិងភាគគីពាក់ព័ន្ធលើការប្រើប្រាស់វិធីសាស្រ្តបង្រៀននិងរៀនក្នុងកម្រិត "មធ្យម" (មធ្យមភាគ=៣.៤០)បានបង្ហាញឱ្យឃើញថា ការគ្រប់គ្រងនិងបំណែងចែកកម្មវិធីសិក្សារបស់គណៈគ្រប់គ្រង លើការប្រើប្រាស់វិធីសាស្រ្តរៀននិងបង្រៀន ដើម្បីពង្រឹងចំណេះដឹង សមត្ថភាពគ្រូ និងសិស្សអាចមានភាពល្អប្រសើរមិនទាន់ប្រសិទ្ធភាពខ្ពស់នៅឡើយ ដោយសារការប្រើប្រាស់សម្ភារឧបទេសបង្រៀននៅមានកម្រិត មិនទាន់សមស្របទៅតាមគោលដៅមេរៀន និងការអនុវត្តន៍បំណិនស្តាប់ភាសាអង់គ្លេសមិនបានញឹកញាប់។

## ៤.៣.ការវិភាគទិន្នន័យលើកម្រងទី២ មធ្យមភាគ (គ្រូបង្រៀននិងសិស្ស)

### ៤.៣.១បញ្ហាប្រឈមលើការបង្រៀន

តារាង៤.១៤ ក.កត្តាគ្រូបង្រៀន

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | សិស្សមិនយល់ពីភាសាអង់គ្លេសទាល់តែសោះ។ | ២.៩៥ | ០.៨៣ | មធ្យម |
| ២ | សិស្សចេះតែពាក្យ និងឃ្លាសាមញ្ញក្នុងជីវភាពប្រើប្រាស់ប្រចាំថ្ងៃ។ | ៣.៣៦ | ០.៨២ | មធ្យម |

| | | | | |
|---|---|---|---|---|
| ៣ | សិស្សអាចយល់ពីការណែនាំរបស់គ្រូក្នុងពេលកំពុងបង្រៀនបំណិនស្តាប់។ | ៣.០៥ | ០.៩៤ | មធ្យម |
| ៤ | សិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការចាក់កាសែត។ | ២.៨០ | ០.៨៨ | មធ្យម |
| ៥ | សិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការអានផ្ទាល់ពីគ្រូ។ | ៣.០០ | ០.៧៦ | មធ្យម |
| ៦ | សិស្សមានចំណេះដឹងទូទៅទាក់ទងនឹងអត្ថបទស្តាប់មិនទូលំទូលាយ។ | ២.៦០ | ០.៧៩ | មធ្យម |
| ៧ | សិស្សមានការព្រួយបារម្ភពីការបញ្ចេញសំលេងរបស់អ្នកនិយាយដែលធ្វើឱ្យពួកគេធុញធប់ពីការយល់អត្ថបទ។ | ៣.១០ | ០.៨២ | មធ្យម |
| | **សរុប** | **២.៩៨** | **០.៨៣** | មធ្យម |

តារាង៤.១៤ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើបញ្ហាប្រឈមរបស់គ្រូនៃការរៀនរបស់សិស្ស ដែលឆ្លុះបញ្ចាំងការឆ្លើយតបរបស់គ្រូភាគច្រើនបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ទទួលបានការយល់ស្របក្នុងកម្រិត " មធ្យម" (មធ្យមភាគ= ២.៩៨ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៣៦) គឺ " សិស្សចេះតែពាក្យ និងឃ្លាសាមញ្ញក្នុងជីវភាពប្រើប្រាស់ប្រចាំថ្ងៃ" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម" (មធ្យមភាគ= ២.៦០ )គឺ" សិស្សមានចំណេះដឹងទូទៅទាក់ទងនឹងអត្ថបទស្តាប់មិនទូលំទូលាយ"។

សរុបសេចក្តីនៃការយល់ស្របរបស់គ្រូបង្រៀនដែលជួបបញ្ហាកន្លងមកក្នុងកម្រិត ដែលបង្ហាញឱ្យឃើញថា គ្រូបង្រៀនមានសិស្សក្នុងថ្នាក់ដែលមានចំណេះដឹងមិនសូវទូលំទូលាយ រីឯព្យាយាមនិងយកចិត្តទុកដាក់រៀនមានការចាប់អារម្មណ៍មិនសូវខ្លាំង ដែលនាំឱ្យគ្រូបង្រៀនមានការលំបាកខ្លះៗទៅលើការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស និងលទ្ធផលសិក្សារបស់សិស្សមិនទាន់បានល្អប្រសើរនៅឡើយទេ។

ហេតុដូច្នេះគ្រូបង្រៀនត្រូវរកវិធីសាស្ត្របង្រៀននិងរៀនឱ្យសមស្របនឹងចំណេះដឹងនិងចំណង់ចំណូលចិត្ត របស់សិស្ស ព្រមទាំងលើកទឹកចិត្តឱ្យចូលចិត្តរៀនស្តាប់ភាសាអង់គ្លេស មិនតែប៉ុណ្ណោះបន្ថែមការជំរុញ សិស្សឱ្យមានការចូលចិត្តរៀន និងយល់ពីសារប្រយោជន៍នៃការរៀនភាសាអង់គ្លេសឱ្យស៊ីជម្រៅជាងមុន។

តារាង៤.១៥ ខ.កត្តាសិស្ស

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ១ | ប្អូនមិនមានការភ័យខ្លាចនៅពេលកំពុងស្តាប់ក្នុងស្ថានភាពជាក់លាក់ពិតប្រាកដ។ | ៣.២៩ | ០.៩០ | មធ្យម |
| ២ | ប្អូនយល់ថាសិស្សដទៃទៀតស្តាប់យល់ជាងប្អូនខណៈពេលកំពុងស្តាប់ភាសាអង់គ្លេស។ | ៣.៣៣ | ១.០០ | មធ្យម |
| ៣ | ប្អូនជឿជាក់លើខ្លួនឯងក្នុងការស្តាប់ភាសាអង់គ្លេសនៅក្នុងថ្នាក់។ | ៣.៣៧ | ០.៩០ | មធ្យម |
| ៤ | ប្អូនមិនជឿជាក់លើខ្លួនឯងក្នុងការស្តាប់គ្រូនិងមិត្តរួមថ្នាក់និយាយភាសាអង់គ្លេស។ | ៣.៥៨ | ០.៨៩ | ល្អ |
| ៥ | នៅពេលអ្នកនិយាយប្រើពាក្យពិបាក ប្អូនព្រួយបារម្ភចំពោះការមិនយល់ពីពាក្យនោះ។ | ៣.៤៣ | ១.០០ | ល្អ |
| ៦ | ប្អូនមានអារម្មណ៍តានតឹងលើការរៀនបំណិនស្តាប់ជាជាងរៀនបំណិនអាន បំណិនសរសេរ បំណិននិយាយ។ | ៣.១៨ | ១.០០ | មធ្យម |
| ៧ | ប្អូនមានចំណេះដឹងទូលំទូលាយ ចំពោះការរៀនបំណិនស្តាប់។ | ៣.២០ | ០.៩០ | មធ្យម |
| ៨ | ប្អូនមានការជឿជាក់លើខ្លួនឯងពេលស្តាប់ការអត្ថបទដោយគ្រូផ្ទាល់ ខណៈពេលរៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៣៦ | ០.៨០ | មធ្យម |
| ៩ | ប្អូនមានការជឿជាក់លើខ្លួនឯងពេលស្តាប់អត្ថបពេលស្តាប់ការសែតភាសាអង់គ្លេស។ | ៣.៣៦ | ០.៧៦ | មធ្យម |

| | | | | |
|---|---|---|---|---|
| ១០ | ប្អូនជួបពាក្យពិបាកនៅពេលដែលប្អូនរៀនបំណិនស្តាប់ភាសាអង់គ្លេស។ | ៣.៨២ | ០.៨០ | ល្អ |
| ១១ | ខណៈពេលស្តាប់ប្អូនមានការលំបាកលើការបញ្ចេញសម្លេង និងការលើកដាក់សម្លេងរបស់អ្នកនិយាយ។ | ០.៥៦ | ០.៥៦ | ល្អ |
| ១២ | ការស្តាប់ការសែតមានការសន្ទនាលឿនស្តាប់មិនទាន់។ | ៣.៧៨ | ០.៦០ | ល្អ |
| ១៣ | នៅពេលស្តាប់ក្នុងថ្នាក់មានការរំខានពីខាងក្រៅ ។ | ៣.២៨ | ០.៨៤ | មធ្យម |
| ១៤ | ការស្តាប់កាសែតមានសម្លេងមិនសូវច្បាស់ និងមានការរអាក់រអួល។ | ៣.២០ | ០.៩៣ | មធ្យម |
| | **សរុប** | **៣.៤៣** | **០.៨៤** | **ល្អ** |

តារាង៤.១៥ ខាងលើបានបង្ហាញពីមធ្យមភាគទៅលើបញ្ហាប្រឈមនៃការរៀនរបស់សិស្សដែលឆ្លុះបញ្ចាំងការរៀនបំណិនស្តាប់នៅមធ្យមសិក្សាទុតិយភូមិ ទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៤៣ )។ ហើយសូចនាករដែលទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគ= ៣.៨២) គឺ " ប្អូនជួបពាក្យពិបាកនៅពេលដែលប្អូនរៀនបំណិនស្តាប់ភាសាអង់គ្លេស" និងសូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត " មធ្យម " (មធ្យមភាគ= ៣.១៨ )គឺ" ប្អូនមានអារម្មណ៍តានតឹងលើការរៀនបំណិនស្តាប់ជាជាងរៀនបំណិនអាន បំណិនសរសេរ និងបំណិននិយាយ"។ ក្នុងន័យនេះ សិស្សជួបការលំបាកលើការរៀនលើវិធីសាស្ត្រក្នុងកម្រិតល្អបង្ហាញឱ្យឃើញថាសមត្ថភាពភាសាបរទេសរបស់សិស្សផ្ទាល់ និងការប្រើបច្ចេកទេសរៀនបំណិនស្តាប់ក្នុងថ្នាក់រៀនថែមទាំងការយកចិត្តទុកដាក់របស់សិស្សផ្ទាល់នៅមានចន្លោះប្រហោងតិចតួច ដែលឥទ្ធិពលក្នុងការរៀនភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនោះ គ្រូបង្រៀនដើរតួនាទីសំខាន់ជាអ្នកផ្ទេរចំណេះដឹង ពុទ្ធិ និងបំណិនផ្សេងៗ ត្រូវជួយសម្របសម្រួលការរៀននិងបង្រៀន និងពង្រឹងបន្ថែមទៅលើការអភិវឌ្ឍន៍ភាសាអង់គ្លេសរបស់សិស្ស។

## ៤.៣.២.សរុបទិន្នន័យលើបញ្ហាប្រឈមលើការបង្រៀននិងរៀនសមត្ថភាពស្តាប់( គ្រូបង្រៀន និងសិស្ស)

តារាង៤.១៦ ទិន្នន័យសរុបកម្រងសំណួរលើបញ្ហាប្រឈមលើការបង្រៀនសមត្ថភាពស្តាប់

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|---|
| ក | ទិន្នន័យសរុបលើការឆ្លើយតបបញ្ហាប្រឈមរបស់គ្រូលើការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស | ២.៩៨ | ០.៨៣ | មធ្យម |
| ខ | ទិន្នន័យសរុបលើការឆ្លើយតបបញ្ហាប្រឈមរបស់សិស្សលើការរៀនបំណិនស្តាប់ភាសាអង់គ្លេស | ៣.៤៣ | ០.៨៤ | ល្អ |
| | **សរុប** | **៣.២០** | **០.៨៣** | **មធ្យម** |

តាមតារាង ៤.១៦ បានបង្ហាញពីមធ្យមភាគសរុបពីការឆ្លើយតបជារួមពី គ្រូបង្រៀន និង សិស្សយល់ស្របព្រមក្នុងកម្រិត "មធ្យម" (មធ្យមភាគ=៣.២០) ដែលបង្ហាញពីការអនុវត្តកម្មវិធីរៀននិងបង្រៀនភាសាអង់គ្លេសរបស់គ្រូ និងសិស្សនៅមានបញ្ហាប្រឈមមានតិចតួចទៅលើការប្រើប្រាស់វិធីសាស្ត្ររៀន និងបង្រៀន ការប្រើសម្ភារឧបទេសគាំទ្រការបបង្រៀននៅមានកម្រិត ដោយគ្រូបានប្រើ ម៉ាញេកាសែត កាសែតសម្លេង ថាសសម្លេង CD និងVCD មិនបានញឹកញាប់ មិនទាន់មានបន្ទប់សោតទស្សន៍ដើម្បីអនុវត្ត និងពង្រឹងចំណេះដឹងសមត្ថភាពស្តាប់ ដើម្បី ។

## ៤.៣.៣.ការពិភាក្សាលើការប្រើប្រាស់វិធីសាស្ត្ររៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់កម្រិតមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ

### ៤.៣.៣.១.ផ្នែកកម្មវិធីសិក្សា និងដំណើរការបង្រៀន

ការសិក្សាមុខវិជ្ជាភាសាអង់គ្លេសពិតជាជួយឱ្យសិស្សនូវចំណេះដឹងទូលំទូលាយ ហេតុដូចនេះនៅក្នុងដំណើរការបង្រៀននិងរៀន លោកគ្រូអ្នកគ្រូចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀនឱ្យសមស្របទៅនឹងសមត្ថភាពចំណេះដឹងរបស់សិស្ស និងលទ្ធផលរបស់សិស្សមានភាពប្រសើរឡើង។ ការអនុវត្តកម្មវិធីសិក្សាគ្រូបង្រៀនចាំបាច់ប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ត្រឹមត្រូវទៅតាមមេរៀននៃការរៀនភាសាអង់គ្លេស ដែលមានបំណិនបួនដូចជា បំណិនអាន បំណិនសរសេរ បំណិនស្តាប់ និងបំណិននិយាយ។ តាមបំណោងចែកកម្មវិធី

សិក្សាប្រចាំឆ្នាំ គ្រូប្រើប្រាស់វាជាឯកសារចង្អុលបង្ហាញ ដើម្បីឱ្យពួកគាត់បង្កើតផែនការបង្រៀនផ្ទាល់ខ្លួនក្នុងរយៈពេល១ឆ្នាំសិក្សា។ មិនតែប៉ុណ្ណោះ ការប្រើសម្ភារឧបទេស ជាមធ្យោបាយ និងលក្ខខណ្ឌសម្រាប់ប្រើប្រាស់ក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ តាមរយៈលោក Cheng & Andy បាននិយាយថា ការបង្រៀនបានជោគជ័យចាំបាច់ទាមទារឱ្យកម្រិតយល់ដឹងភាសាអង់គ្លេស គុណសម្បត្តិផ្ទាល់ខ្លួន សម្ភារបង្រៀន ព្រមទាំងជំនាញផ្នែកវិធីសាស្ត្របង្រៀន ដែលជាកត្តាសំខាន់ (Cheng & Andy, 2010)។

**៤.៣.៣.២.គ្រូបង្រៀន និងដំណើរការបង្រៀនក្នុងថ្នាក់**

- គ្រូបង្រៀនភាគយល់ស្របលើ" មានការនិយមប្រើប្រាស់វិធីសាស្ត្រអានផ្ទាល់ដែលគ្រូប្រើច្រើនដើម្បីបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ដោយគ្រូត្រូវអានអត្ថបទស្តាប់ឱ្យសិស្សស្តាប់ហើយឆ្លើយសំណួរតាមរយៈ ការទួសទាយ សំណួរពិតឬមិនពិត ការផ្គូរផ្គង ។ល។ បានជាគ្រូជ្រើសរើសវិធីសាស្ត្រនេះដោយសារមានកត្តា កង្វះខាតបន្ទប់សោតទស្សន៍ភាសាបរទេស សម្ភារឧបទេស សម្រាប់ការបង្រៀនបំណិនស្តាប់ត្រូវការ ដូចជា មាញ៉េកាសែត កាសែតសម្លេង និងថាសសម្លេង CD រឺVCD ឧបករណ៍បំប៉ងសម្លេង ។ល។ ដែលសាលាមួយចំនួនផ្គត់ផ្គង់មិនទាន់គ្រប់គ្រាន់នៅឡើយទៅតាមតំរូវការរបស់គ្រូបង្រៀននិងរៀននៅឡើយទេ។

- គ្រូភាគច្រើនបានយល់ស្របថាបានប្រើប្រាស់វិធីសាស្ត្រទាំងនេះញឹកញាប់ "ប្រើប្រាស់វិធីសាស្ត្រស្តាប់ដោយការយល់ (Comprehensive Listening Method) ក្នុងការបង្រៀនបំណិនស្តាប់លមានភាពងាយស្រួលដល់គ្រូជួយដល់សិស្សឱ្យឆាប់យល់ និងសិស្សមានសកម្មភាពចូលរួមក្នុងថ្នាក់លើការឆ្លើយសំណួរចម្លើយ សំណួរពិតឬមិនពិត សំណួរផ្គូរផ្គង បំពេញចន្លោះដើម្បីឱ្យសិស្សយល់ពីអត្ថបទរួចធ្វើការឆ្លើយតបត្រឡប់មកវិញ និងវិធីសាស្ត្របកប្រែជាភាសាដើមកំណើត (Translated Method)សម្រាប់ជួយសម្រួលដល់សិស្សដែលមានសមត្ថភាពភាសាអង់គ្លេសកម្រិតទាប និងមធ្យមងាយស្រួលយល់ ព្រមទាំងយល់ពីការណែនាំរបស់គ្រូ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សមួយចំនួនតូច ដែលមិនយល់ពីភាសាអង់គ្លេសផ្ទាល់។ ស្របតាមលោក( Natsir, 2014, p.58 )បានលើកឡើងពីការវិធីសាស្ត្របង្រៀន គឺជាសមាសធាតុ

មួយដ៏សំខាន់ដើម្បីអនុវត្តគោលដៅនៃការអប់រំ នៅក្នុងដំណើរការនៃការបង្រៀន និងរៀនជាពិសេសនោះ ថ្នាក់រៀនជាភាសាអង់គ្លេស។ ដើម្បីឱ្យការបង្រៀននិងការរៀនទទួលបានជោគជ័យវាទាមទារឱ្យគ្រូបង្រៀន មានគុណវុឌ្ឍិគ្រប់គ្រាន់ និងវិធីសាស្ត្របង្រៀនច្បាស់លាស់ ដែលមានលក្ខណៈបត់បែនទៅតាមស្ថានភាព ថ្នាក់រៀនសម្រាប់បង្រៀនសិស្ស។

- លោកគ្រូអ្នកគ្រូបានយល់ស្របថា"បានប្រើប្រាស់វិធីសាស្ត្រទាំងនេះញឹកញាប់ លើការជំរុញនិង លើកទឹកចិត្តដល់សិស្សអនុវត្តការស្តាប់ព័ត៌មាន ចម្រៀងកំសាន្ត ភាពយន្ត រឿងភាគ ជាភាសាអង់គ្លេស និង ព្រមទាំងលើកទឹកសិស្សដោយប្រើពាក្យសរសើរនិងផ្តល់រង្វាន់ មិនតែប៉ុណ្ណោះគ្រូផ្តល់កំនែ និងព័ត៌មាន ត្រឡប់ទៅសិស្សដែលជាការលើកទឹកចិត្តដល់សិស្សខិតខំប្រឹងប្រែង និងបានជួយជំរុញសិស្សឱ្យមានភាព ក្លាហាននិងហ៊ានបញ្ចេញមតិយោបល់"។ ទិន្នន័យដែលទទួលបាន វាសមស្របទៅនឹងការលើកឡើងរបស់ Petty(1998) យល់ឃើញថា ប្រសិនបើសិស្សមិនចង់រៀន ប្រសិនភាពនៃការសិក្សារបស់ពួកគេប្រាកដជា យឺត ឬក៏គ្មានទទួលបានផលអ្វីទាំងអស់។ ដូចច្នេះបើគ្រូបង្រៀនដឹងពីវិធីនៃការលើកទឹកចិត្តសិស្ស គ្រូអាច ជួយបង្កើនការសិក្សារបស់សិស្សឱ្យប្រសើរជាងមុន (Petty, 2004)។

- គ្រូបង្រៀនមានវិធីសាស្ត្រច្រើនក្នុងការបង្រៀនភាសាអង់គ្លេស ប៉ុន្តែជាក់ស្តែងគ្រូបង្រៀនពុំសូវ យកមកវិធីសាស្ត្រALM និងCLM ដែលជួយដល់សិស្សក្នុងការអនុវត្តផ្ទាល់បំណិនស្តាប់ វាអាស្រ័យទៅ តាមស្ថានភាពនាពេលបច្ចុប្បន្ននៅតាមសាលាបង្រៀនរបស់ពួកគាត់។

- គ្រូភាគច្រើនយល់ស្របថា "មានវិធីសាស្ត្រមួយចំនួនពុំសូវបានយកមកអនុវត្តលើការបង្រៀន បំណិនស្តាប់ភាសាអង់គ្លេសនោះទេ" តាមការលើឡើងរបស់គ្រូបានប្រើប្រាស់វិធិសាស្ត្រ Critical listening ម្តងម្កាលនៅក្នុងថ្នាក់រៀនលើបំណិនស្តាប់ភាសាអងគ្លេស ដោយកត្តាសិស្សមានសមត្ថភាពភាសាអង់គ្លេស ភាគច្រើនមានកម្រិតមធ្យម និងខ្លះទៀតមានកម្រិតក្រោមកម្រិតថ្នាក់និងសៀវភៅសិក្សាគោល EFC របស់ ក្រសួងអប់រំ យុវជន និងកីឡា(តាមការឆ្លើយសំណួររបស់គ្រូទៅលើសមត្ថភាពចំណេះដឹងភាសាអង់គ្លេស របស់សិស្ស) និង វិធីសាស្ត្រ (Audio Lingual method) លោកគ្រូ អ្នកគ្រូភាគច្រើនមិនប្រើប្រាស់ញឹកញាប់

នោះទេ មូលហេតុដោយសារការផ្តត់ផ្គង់សម្ភារឧបទេសរៀន និងបង្រៀនមានមិនគ្រប់គ្រាន់ ដូចនេះពួកគាត់ពុំសូវចាក់ឱ្យសិស្សស្តាប់នោះទេ។

- គ្រូភាគច្រើនយល់ស្របថា "មិនបានដាក់បំណិនស្តាប់ក្នុងវិញ្ញាសាប្រឡងប្រចាំខែ ឬប្រឡងឆមាសនោះទេ ដោយសារមិនមានសម្ភារឧបទេស ក៏ដូចជាការប្រឡងថ្នាក់ជាតិមិនបានដាក់បំណិនស្តាប់ក្នុងវិញ្ញាសាប្រឡងថ្នាក់ជាតិមុខវិជ្ជាភាសាអង់គ្លេស"

សរុបមក លោកគ្រូ អ្នកគ្រូ ប្រើប្រាស់វិធីសាស្ត្រមួយចំនួនមានដូចជា ការអានឱ្យសិស្សស្តាប់ ដែលជួយសម្រួលដល់ការបង្រៀនមានភាពងាយស្រួលក្នុងការផលិតសម្ភារឧបទេស ឱ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងក្នុងសាលារៀនដែលមានការផ្គត់ផ្គង់គ្រឿងបរិក្ខារ។ រីឯបន្ទប់បណ្ណាល័យខ្វះសៀវភៅអានភាសាអង់គ្លេសសម្រាប់គ្រូ និងសិស្សធ្វើស្វ័យសិក្សាស្រាវជ្រាវ និងមិនមានបន្ទប់សោតទស្សន៍ដែលមានសារៈសំខាន់សម្រាប់ហាត់ស្តាប់ភាសាអង់គ្លេស ឧបករណ៍សម្រាប់ស្តាប់មិនទាន់មានគ្រប់គ្រាន់ និងទាន់ពេលវេលាតាមតម្រូវការជាក់ស្តែង និងគ្រឿងបរិក្ខារ ក៏ដូចជាធនធានផ្គត់ផ្គង់សម្រាប់បំណិនស្តាប់នៅមានកម្រិតទៅតាមលទ្ធភាពសាលារៀននីមួយៗក្នុងរាជធានីភ្នំពេញ។

### ៤.៣.៣.៣.សម្ភារឧបទេស បន្ទប់ភាសា និងសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស

ក្នុងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់លើគ្រប់មុខវិទ្យាទាំងអស់ សម្ភារទ្រទ្រង់ការបង្រៀនពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយ ឱ្យគ្រូសម្រេចនូវវត្ថុបំណងមេរៀន។ គ្រូបង្រៀនភាសាអង់គ្លេស ចាំបាច់ប្រើប្រាស់សម្ភារឧបទេសដូចជាសៀវភៅសិក្សាគោល សៀវភៅណែនាំគ្រូ ម៉ាញ៉េចាក់កាសែត ឬស៊ីឌី ប័ណ្ណរូបភាពឬពាក្យ បន្ទប់អនុវត្តការស្តាប់ និងមើលវីឌីអូ និងតាមទ្រឹស្តីរបស់លោក Brakash S.chauhan សម្ភារៈបង្រៀននិងរៀនចែកចេញជាបីប្រភេទសំខាន់ៗ ដែលអាចយកមកប្រើប្រាស់សម្រាប់មេរៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់ភាសាអង់គ្លេស ខណៈពេលកំពុងបង្រៀនសិស្សនៅក្នុងថ្នាក់រៀន (chauhan, 2015)។

- គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សភាគច្រើនយល់ស្របគ្នាលើ "ការប្រើប្រាស់សៀវភៅសិក្សាគោល EFC ចាំបាច់ត្រូវប្រើប្រាស់សម្ភារៈទ្រទ្រង់ការបង្រៀនរបស់ខ្លួនផងដែរ ក្នុងចំណោមសម្ភារៈទ្រទ្រង់ដល់ការបង្រៀនភាសាអង់គ្លេស"។ ដោយឡែកគ្រូភាគច្រើនប្រើសៀវភៅសិក្សាគោល EFC(Book 4, 5, 6) សៀវភៅពុម្ពភាសាអង់គ្លេសរបស់ក្រសួងអប់រំយុវជន និងកីឡាតែ១ប៉ុណ្ណោះក្នុងការគាំទ្រក្នុងការបង្រៀនបំណិនស្តាប់ ដែលសៀវភៅនោះមិនទាន់បានធ្វើបច្ចុប្បន្នភាព នៅឡើយនិងការអនុញ្ញាតឱ្យប្រើប្រាស់សៀវភៅថ្មី។

- គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស ភាគច្រើនមានមតិយោបល់ស្របគ្នាលើ " បន្ទប់បណ្ណាល័យមិនទាន់មានការបំពាក់គ្រឿងបរិក្ខារ និងសៀវភៅ និងឯកសារអានភាសាអង់គ្លេស ដោយឡែកការប្រើប្រាស់សម្ភារឧបទេសលើមុខវិជ្ជាភាសាអង់គ្លេស ពុំទាន់មានដូចជាបន្ទប់សោតទស្សន៍ភាសាបរទេសសម្រាប់អនុវត្តស្តាប់ និងមើលវីដេអូភាសាអង់គ្លេសមិនទាន់មានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់គ្រូបង្រៀននិងសិស្ស" ស្របនឹងការសិក្សានេះ លោក Heng narin( 2018) បានរកឃើញដូចបានរៀបរាប់ ដូចគ្នានឹងលោក Mosha (2014) បានលើកឡើងថា កង្វះសម្ភារៈទ្រទ្រង់ការបង្រៀន គឺជាកត្តាជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការរៀននិងបង្រៀនផងដែរ។

## ៤.៣.៣.៤.សិស្ស និងដំណើរការបង្រៀនក្នុងថ្នាក់

ភាសាអង់គ្លេសមានសារៈសំខាន់ ដែលសិស្សមានចំណាប់អារម្មណ៍ពីសារប្រយោជន៍នៃការរៀនភាសាអង់គ្លេស បន្ថែមពីនេះមានសិស្សមួយចំនួនទៅបំប៉នបន្ថែមនៅខាងក្រៅម៉ោងរដ្ឋ។ សិស្សមានចំណាប់អារម្មណ៍លើការៀនបំណិនស្តាប់ពីព្រោះពួកគាត់ចង់ចេះស្តាប់និងចេះនិយាយ ព្រមទាំងសិស្សមួយចំនួនព្យាយាមរៀន និងហ្វឹកហាត់រៀនភាសាតាមវិធីសាស្រ្តផ្សេងៗគ្នា យោងតាមការឆ្លើយសំណួររបស់សិស្សក្នុងសំណួរបើកពីវិធីសាស្រ្តរៀនសមត្ថភាពស្តាប់ភាសាអងគ្លេស។

- សិស្សភាគច្រើនបានយល់ស្របលើមតិ "ការចូលរួមសកម្មភាពក្នុងការរៀនភាសាអង់គ្លេសសមត្ថភាពស្តាប់ និងនិយាយ( សិស្សមានការចូលរួមដោយលោកគ្រូ អ្នកគ្រូជាអ្នកកំណត់ទៅលើវិធីសាស្រ្ត

និងមេរៀនត្រូវរៀននិងប្អូនប្រើការពិភាក្សាគ្នាជាមួយដៃគូរ ឬជាក្រុម ព្រមទាំង ប្អូនប្រើភាពជឿជាក់លើខ្លួនឯងក្នុងការស្តាប់គ្រូ និងមិត្តរួមថ្នាក់និយាយភាសាអង់គ្លេសវាមានលក្ខណៈងាយស្តាប់បាន និងយល់ពីអ្វីដែលគេនិយាយ។ការការលើកទឹកចិត្ត និងការជំរុញរបស់គ្រូឱ្យសិស្សពង្រឹងការស្តាប់តាមរយៈព័ត៌មាន ចម្រៀង រឿងខ្លី រឿងភាគជាភាសាអង់គ្លេសដែលអាចឱ្យប្អូនអាចពង្រឹងការស្តាប់តាមរយៈការបញ្ចេញសម្លេងពីជនជាតិដើមការលើកដាក់សំលេង ដែលជួយឱ្យឆាប់យល់ពីការស្តាប់ការសន្ទនារបស់អ្នកនិយាយ មិនតែប៉ុណ្ណោះ ការធ្វើកិច្ចការងារផ្ទះដែលគ្រូដាក់ឱ្យដើម្បីពង្រឹងសមត្ថភាពស្តាប់ដោយការស្តាប់ហើយឱ្យសិស្សសរសេរសេចក្តីសង្ខេបមកវិញដើម្បីឆ្លើយតបការយល់របស់ប្អូនបានកម្រិតណា"។

- ដោយឡែកសិស្សភាគច្រើនមានយោបល់ស្របគ្នាលើ "ការរៀនភាសាអង់គ្លេសមិនសូវបានប្រើប្រាស់វិធីសាស្រ្តទស្សទាយអត្ថន័យខ្លឹមសារអត្ថបទក្រោយពីការស្តាប់មេរៀនជាភាសាអង់គ្លេស ផ្អែកលើចំណេះដឹងទូទៅរបស់ប្អូនពុំសូវមានសមត្ថភាពទូលំទូលាយ និងមូលដ្ឋានគ្រឹះភាសាអង់គ្លេសនៅមានកម្រិតទាបនៅឡើយ" និង "ពេលរៀនមិនសូវចាប់អារម្មណ៍លើបំណិនស្តាប់ដោយការទស្សទាយអត្ថន័យពាក្យពិបាកនៅពេលកំពុងស្តាប់" ដោយប្អូនគិតថាពិបាក និងមិនចេះបកប្រែជាភាសាដើមកំណើតរបស់ខ្លួន ដែលជាហេតុធ្វើឱ្យប្អូនមានការភ័យខ្លាច និងធុញធប់ក្នុងការរៀនបំណិនស្តាប់ភាសាអង់គ្លេសជាជាងបំណិនផ្សេងៗ។ ការលើកឡើងរបស់សិស្សមានលក្ខណៈប្រហាក់ប្រហែលនឹងការលើកឡើងរបស់លោក Oxford 2001 បានបញ្ជាក់ថាជំនឿរបស់សិស្សលើការរៀនភាសាអង់គ្លេស ចាត់ទុកជាមុខវិជ្ជាមួយមានពាក្យ វេយ្យាករណ៍ ឃ្លាវេយ្យាស័ព្ទចាំបាច់ត្រូវទន្ទេញចាំឬបែងចែកបំណិនឱ្យបានដាក់លាក់មានបំណិនបញ្ចូលញគ្នា និងបំណិនបន្ទាប់បន្សំ។

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ គ្រូបង្រៀនតាមសាលារដ្ឋមួយចំនួនបានបញ្ជាក់ពេលចុះប្រមូលទិន្នន័យថា៖ «បើសិនជាសិស្សដែលរៀនវាអត់បញ្ហាទេ ព្រោះសិស្សចេះស្រាវជ្រាវ តាមរយៈការរៀនតាមវេបសាយរៀនភាសាបរទេស ការស្តាប់ព័ត៌មានជាភាសាអង់គ្លេស ធ្វើតេស្តតាមវេបសាយបង្រៀនភាសាអង់គ្លេស ការធ្វើតេស្តប្រឡង TOEFL ឬ IELT ការប្រឡងស្តង់ដារអន្តរជាតិ

ដែលក្នុងនោះមានវិញ្ញាសាប្រឡងលើបំណិនស្តាប់ តែសម្រាប់សិស្សដែលខ្សោយគឺពិបាកហើយ ព្រោះអី សិស្សខ្សោយបើយើងជួបផ្ទាល់វិញវាល្អជាង យើងអាចពន្យល់បានច្រើន។ ដល់ពេលនេះការបង្រៀនភាសាអង់គ្លេស យើងពន្យល់សិស្សមួយចំនួនយល់ពីមេរៀនបានច្រើន ប៉ុន្តែសិស្សមួយចំនួនទៀតអត់យល់ខ្លឹមសារមេរៀនដែលបានបង្រៀន"។

សរុបមកតាមរយៈទិន្នន័យសរុបនៃការឆ្លើយតបរបស់គណៈនាយក គ្រូបង្រៀន និងសិស្សលើការប្រើប្រាស់វីធិសាស្ត្ររៀន និងបង្រៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់ នាពេលកន្លងមកមានការចូលរួម និងយកចិត្តទុកដាក់ពីគ្រូបង្រៀននិងភាគគីពាក់ព័ន្ធមានកម្រិតមធ្យម និងស្ថាភាពការរៀននិងបង្រៀនលើសមត្ថភាពស្តាប់ភាសអង់គ្លេសនៅមានកម្រិតមធ្យមនៅឡើយ។

### ៤.៤.១ ទិន្នន័យបែបគុណវិស័យដែលទទួលបាន ពីគណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស លើបញ្ហាប្រឈមនៃការរៀននិងបង្រៀន

ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសលើបំណិនមានបីជំហានដែលលោកគ្រូ អ្នកគ្រូត្រូវប្រើវិធីសាស្ត្របង្រៀនឱ្យស្របទៅតាមជំហានទាំងបី ដូចជា ការត្រៀមស្តាប់ (Pre-listening) ជាជំហានជួយដល់សិស្សត្រៀមលក្ខណៈស្តាប់ ដោយគ្រូជួយផ្តល់តម្រុយ ឬព័ត៌មានទូទៅដែលទាក់ទងនឹងអត្ថបទស្តាប់។ លោកគ្រូ អ្នកគ្រូភាគច្រើនលើកឡើងពីសិស្សមួយចំនួនមានចំណេះដឹងមិនទូលំទូលាយ និងសមត្ថភាពភាសាបរទេសមានកម្រិត មធ្យម។ ជំហានខណៈពេលស្តាប់ While-listening ដែលលោកគ្រូអ្នកគ្រូចាំបាច់ត្រូវប្រើប្រាស់សម្ភារឧបទេស ភាគច្រើនប្រើការសែតសំរាប់ចាក់ឱ្យសិស្សស្តាប់ និងគ្រូប្រើវិធីសាស្ត្របង្រៀននិងការជួយលើកទឹកចិត្តសិស្ស ដោយឱ្យតម្រុយ ផ្ទាំងរូបភាព ពាក្យ ពាក្យកាត ក្តារខៀន កាយវិការ...។ ជំហានក្រោយពេលស្តាប់ Post-Listening ក្រោយពីស្តាប់ទទួលបានអត្ថន័យអត្ថបទ សិស្សមានសកម្មភាព ឆ្លើយសំណួរ ផ្ទួរផ្ទង សង្ខេបនូវអ្វីដែលគេបានស្តាប់ ទៅតាមវិធីសាស្ត្រដែលគ្រូចង្អុលបង្ហាញ ដែលលោកគ្រូអាចវាយតម្លៃទៅលើលទ្ធផលនៃការៀនបំណិនស្តាប់តាមរយៈការឆ្លើយតបរបស់សិស្ស។មានសិស្សានុ សិស្សមួយចំនួន ដែលជួបបញ្ហាលំបាកក្នុងការរៀនភាសាអង់គ្លេសដូចជា ការរៀនមិនសូវចេះស្តាប់ និង ឆាប់ធុញជាដើម ដោយសារតែ ស្តាប់សម្លេងមិនសូវច្បាស់និងមានពាក្យពិបាក មិនចេះបកប្រែព្រោះមុននឹងចាប់

ផ្ដើមស្ដាប់លើកាសែតឬស្ដាប់ពីការអានរបស់គ្រូ នឹងមានការឆ្លើយសំណួរនិងលំហាត់ទាក់ទងនឹងអត្ថបទស្ដាប់។

### ក. ពិភាក្សាលើបញ្ហាប្រឈមគ្រូ ក្នុងការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស

តាមការស្រង់មតិរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សទៅលើការឆ្លើយសំណួរ៖

**ការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន៖ (ដំណើរការបង្រៀន និងវិធីសាស្ត្រ)**

- គណៈគ្រប់គ្រង៧៥% គ្រូបង្រៀន៧០% និងសិស្ស៥២% យល់ស្របថាមាន "ម៉ោងសិក្សាមុខវិជ្ជាភាសាអង់គ្លេសមាន២ម៉ោងក្នុង១សប្តាហ៍" ទាក់ទងទៅនឹងចំនួនម៉ោងសិក្សានៅពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយទេ ហើយដើម្បីឱ្យចប់ទាន់កម្មវិធីសិក្សាគ្រូបង្រៀនត្រូវបង្ខំចិត្តបង្រៀនសង្ខេបខ្លីច្បោលៗទៅលើខ្លឹមសារនិងបង្រៀនផ្តោតតែលើបំណិនអាននិងសរសេរ ពាក្យ និងវេយ្យាករណ៍តែប៉ុណ្ណោះ។ មួយវិញទៀតគ្រូពុំសូវបានអនុវត្តការស្តាប់នៅក្នុងថ្នាក់រៀនញឹកញាប់ទេ ដែលជាហេតុធ្វើឱ្យសិស្សមិនសូវជឿជាក់ និងចាប់អារម្មណ៍លើការរៀនបំណិនស្តាប់របស់គ្រូ ហើយសិស្សមិនយល់ច្បាស់ខ្លឹមសារមេរៀន និងការប្រើប្រាស់វិធីរៀន និងចំណុចដែលត្រូវពង្រឹងលើការស្តាប់ឱ្យមានភាពល្អប្រសើរ ។ ជាក់ស្តែងនៅកម្ពុជា ភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលជាផ្លូវការ នៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិចាប់ពីកម្រិតថ្នាក់ទី៤រហូតដល់ថ្នាក់ទី១២បាយម៉ោងសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវបានបែងចែកថ្នាក់ទី១០រហូតដល់ទី១២មានម៉ោងសិក្សា ១សប្តាហ៍ សិក្សា៤ ម៉ោង (៤ម៉ោង * ៣៥សប្តាហ៍=១៤០ ម៉ោង / ១ឆ្នាំសិក្សា)និងចំនួនជំពូកក្នុង១កម្រិតថ្នាក់ ទី១០រហូតដល់ទី១២ មាន១១ជំពូក ដោយក្នុង១ជំពូកមាន៣មេរៀន។ រីឯចំនួនម៉ោងក្នុង១មេរៀនមាន៤ ម៉ោង (សម្រាប់ថ្នាក់ទី ១០, ១១ និងទី១២) ដែលក្រសួងរំពឹងទុកនូវលទ្ធផល៖ (១)ការស្តាប់ (២)ការនិយាយ (៣)ការអាន (៤)ការសរសេរ (បូកថែមវេយ្យាករណ៍ និង ពាក្យស័ព្ទ) (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)។

- គណៈគ្រប់គ្រង៦១% គ្រូបង្រៀន ៤០%មានមតិថា "មានការបែងចែកសេវាបង្រៀនប្រចាំថ្ងៃមាន១៦ម៉ោងក្នុង១សប្តាហ៍ នៃគ្រូបង្រៀនលើមុខវិជ្ជាភាសាអង់គ្លេស"

- គ្រូបង្រៀន៦៥% និងសិស្សមានយល់ស្រប ថាបានរៀនបំណិនស្តាប់ចំនួន១ម៉ោងក្នុង១សប្តាហ៍ និងផ្អែកទៅតាមមេរៀនសៀវភៅសិក្សាគោល English For Cambodia របស់ក្រសួង អប់រំ យុវជន និង កីឡា" ដែលជាហេតុធ្វើគ្រូបង្រៀនមានការស្ទាក់ស្ទើរក្នុងការបង្រៀនបំណិនស្តាប់ក្នុងថ្នាក់ បើផ្អែកទៅលើ បំណែងចែកកាលវិភាគ នៃម៉ោងសិក្សារបស់សិស្សក្នុងថ្នាក់១ នោះការរៀននិងបង្រៀននឹងមិនអាច សម្រេចគោលបំណង និងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

- គ្រូបង្រៀន៥០% និងសិស្ស៨៣% ភាគច្រើនមានមតិយល់ស្របលើ "កម្រិតភាសាអង់គ្លេសរបស់ សិស្សភាគច្រើននៅកម្រិតមធ្យម និងតាមរយៈការជ្រើសរើសចម្លើយក្នុងកម្រងសំណួររបស់សិស្សលើ កម្រិតភាសាបរទេស។"

**ដំណើរការបង្រៀន និងវិធីសាស្រ្តៈ**

ដើម្បីសម្រេចគោលបំណង និងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សា ទុតិយភូមិ ទទួលបានជោគជ័យគ្រូបង្រៀនត្រូវ រៀបចំសកម្មភាពបង្រៀន និងរៀនស្របតាមកម្មវិធីសិក្សា លទ្ធផលសិក្សា និងបរិស្ថានសិក្សា។ ក្នុងការរៀបចំកិច្ចតែងការបង្រៀនត្រូវគោរពប្រាំជំហានៈ រដ្ឋបាល ថ្នាក់ រំលឹកមេរៀនចាស់ បង្រៀនមេរៀនថ្មី ពង្រឹងចំណេះដឹង និងដាក់កិច្ចការ ឱ្យសិស្ស ឬណែនាំសិស្សឱ្យ ស្វ័យសិក្សាមេរៀន។ (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)

- គ្រូបង្រៀន៩០%មានមាតិថា"បានប្រើប្រាស់វិធីសាស្រ្តដដែលៗ ប្រើវិធីសាស្រ្តអានឱ្យសិស្សស្តាប់ ផ្ទាល់សម្រាប់ការបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសដោយមិនបានចាក់កាសែតឱ្យសិស្សបានអនុវត្ត ផ្ទាល់លើបំណិនស្តាប់ និងប្រើវិធីសាស្រ្តបង្រៀនសិស្សមជ្ឈមណ្ឌល ក៏ដូចជាបកប្រែជាភាសាខ្មែរឱ្យសិស្ស ដើម្បីជួយឱ្យសិស្សងាយយល់" មិនតែប៉ុណ្ណោះ គ្រូបង្រៀន៧០%លើកឡើងថា "សមត្ថភាពសិស្សមិនស្មើ គ្នា ពិបាកក្នុងការបង្រៀនក្នុងពេលតែមួយនៅក្នុងថ្នាក់ ដែលត្រូវចំណាយពេលច្រើនដើម្បីពន្យល់សិស្ស និងត្រូវចំណាយពេលវេលាដើម្បីពន្យល់ទៅលើសិស្ស"។

**ចំពោះរដ្ឋបាលថ្នាក់៖**

ដោយផ្តោតលើសម្ភារឧបទេស សាលាមិនសូវមានសម្ភារៈគ្រប់គ្រាន់ដែលជួយដល់ដំណើរការបង្រៀន និងរៀនឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់ក៏ដូចជាអគារធនធាន ដែលធ្វើឱ្យគ្រូបង្រៀនដោយប្រើប្រាស់វិធីស្តាប់ ដែលត្រូវការបង្កើតឧបករណ៍ស្តាប់មិនមានគ្រូបង្រៀនជ្រើសរើសវិធីសាស្ត្រអានរបស់គ្រូប៉ុណ្ណោះ ដែលជាហេតុខាងដើមធ្វើឱ្យការបង្រៀននិងរៀនមិនទទួលបានលទ្ធផលល្អប្រសើរដូចក្នុងកម្មវិធីសិក្សាលម្អិតបានរំពឹងទុក។ មួយវិញទៀតសាលាមិនទាន់មានឯកសារស្រាវជ្រាវគ្រប់គ្រាន់ដែលបម្រើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេស ជាពិសេសការរៀននិងបង្រៀនសមត្ថភាព ស្តាប់នៅឡើយទេ។ មានការលើកឡើងថា សម្ភារឧបទេសជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់ សម្រាប់ប្រើប្រាស់ក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ សម្ភារឧបទេសរួមមាន៖ រូបភាពផ្ទាំងធំ បណ្ណរូបភាព បណ្ណពាក្យ សៀវភៅសិក្សាគោល សៀវភៅណែនាំជាដើម គឺជាធនធានដែលគ្រូ និងសិស្សយល់មកប្រើប្រាស់ក្នុងការបង្រៀន និងរៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ច្បាស់លាស់ ងាយចាប់បាន មានការទាក់ទាញអារម្មណ៍សិស្សហើយអាចសម្រាចវត្ថុបំណងមេរៀនបានល្អប្រសើរ (ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨)។ ចំពោះការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក៏នៅមានភាពធូររលុងនៅឡើយ ដោយការអនុញ្ញាតិឱ្យសិស្សឡើងថ្នាក់ទាំងដែលសិស្សមិនមានមធ្យមភាគជាប់ ដែលជាហេតុធ្វើឱ្យសិស្សមិនសូវយកចិត្តទុកដាក់លើពិន្ទុ ប្រឡងធ្វើឱ្យពួកគេមិនខិតខំសិក្សារៀនសូត្រ អវត្តមានច្រើនក្នុងម៉ោងសិក្សា ។

- គណៈគ្រប់គ្រង៦៩% គ្រូបង្រៀន៥០%និងសិស្ស៧០% យល់ស្របលើការលើ"ការប្រើប្រាស់សម្ភារឧបទេសមានភាពតិចតួច និងមានគ្រូខ្លះមិនបានប្រើសម្ភារឧបទេសជំនួយលើការរៀននិងបង្រៀនបំណិនស្តាប់។ដោយកត្តាបរិស្ថានបន្ទប់រៀន អគារធនធាន បន្ទប់Labភាសាបរទេស សម្រាប់ជំនួយដល់ការរៀននិងបង្រៀនភាសាអង់គ្លេស មិនទាន់បានតាមតម្រូវការនៅឡើយ។ មានការសិក្សាស្រាវជ្រាវរបស់ (លោក សែម ម៉ាក់ ឆ្នាំ២០១៦-២០១៨) រកឃើញលទ្ធផលប្រហាក់ប្រហែលគ្នានឹងការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនភាសាអង់គ្លេស។ ដោយឡែកគ្រូបង្រៀនភាសាអង់គ្លេស២៥%បានប្រើសម្ភារ

ឧបទេស ទ្រទ្រង់ការរៀនបំណិនស្តាប់ ដូចជា ម៉ាញេចាក់កាសែត មាំស៊ីនចាក់ស៊ីឌី ឧបករណ៍បំប៉ងសម្លេងសម្រាប់ជំនួយដល់ការពង្រឹងការស្តាប់ "ជួយដល់ដំណើរការបង្រៀននិងរៀនឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់ទៅតាមលទ្ធភាពសាលារៀន។

- គ្រូបង្រៀន៤៥%និងសិស្ស៦០% មានការយល់ស្របលើ "ការចាប់អារម្មណ៍លើសៀវភៅសិក្សាគោលEnglish For Cambodia មានភាពទាក់ទាញតិចតួច"។

- គណៈគ្រប់គ្រង ៧៦% និង គ្រូបង្រៀន ៦០%មានយោបល់ស្របគ្នាលើ"ចំណេះដឹងមូលដ្ឋានគ្រឹះនិងចំណេះដឹងទូទៅរបស់សិស្សមិនទូលំទូលាយ និងសមត្ថភាពភាសាបរទេសនៅមានកម្រិតទាបជាងកម្រិតសៀវភៅសិក្សានិងមានលក្ខណៈចំរុះបញ្ចូលគ្នា ក្នុងថ្នាក់តែមួយ" សមត្ថភាពសិស្សជាបញ្ហាប្រឈមដែលធ្វើឱ្យលោកគ្រូពិបាកក្នុងការបញ្ចៀបអត្ថន័យខ្លឹមសារមេរៀន និងការណែនាំរបស់គ្រូឱ្យសមស្របនឹងបរិបទសង្គមរបស់សិស្សក៏ដូចជាការយល់ពីវប្បធម៌បរទេស ។ បន្ថែមពីនេះគ្រូជួបបញ្ហាភាគច្រើនដែលសិស្សចេះតែពាក្យអង់គ្លេសងាយៗ និងសាមញ្ញសម្រាប់ជីវភាពប្រចាំ វាពិបាកនិងយល់បានច្រើនពីការស្តាប់អត្ថបទមានពាក្យ បច្ចេកទេសដូចជា សេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ ប្រវត្តសាស្ត្រ។ល។ ក្នុងករណីនេះមានដូចក្នុងការលើកឡើងរបស់លោក Anderson និង Lynch " ចន្លោះប្រហោងនៃចំណេះដឹងរបស់យើងអំពីវប្បធម៌បរទេសភាសាទីពីរ របស់សមាគមន៍ និងឯកសារយោងនានាអាចប្រើប្រាស់បានសម្រាប់ជនជាតិដើម និងអាចយកមកកំណត់បង្ហាញឧបសគ្គនៃការយល់ដឹងក្នុងការទំនាក់ទំនងរវាងអ្នកនិយាយនិងអ្នកស្តាប់"។

- សិស្សភាគច្រើនយល់ស្របលើ"មិនសូវចាប់អារម្មណ៍ខ្លាំងលើបំណិនស្តាប់ភាសាអង់គ្លេសប៉ុន្មានទេ"។

## ខ.ដំណើរការរៀនរបស់សិស្ស

ការយល់ឃើញរបស់សិស្សចំនួន៣០% តាមរយៈការឆ្លើយសំណួរយល់ស្របថា "ចំណាប់អារម្មណ៍លើបំណិនស្តាប់មានភាគតិចតួច ពីព្រោះសិស្សយល់ថារៀនបំណិនស្តាប់សិស្សអាចចេះស្តាប់ភាសាអង់គ្លេសបានល្អ និងងាយយល់ពីអ្វីដែលគេនិយាយ និងចេះនិយាយភាសាអង់គ្លេស"។

សិស្សភាគច្រើនមានយល់ស្របលើ"សមត្ថភាពចំណេះដឹងភាសាអង់គ្លេសនៅមានកម្រិតនធ្យម និងព្រួយបារម្ភណ៍លើការរៀនបំណិនស្តាប់ដោយកត្តា៖

សិស្ស៥២% ស្តាប់មិនសូវបានការបញ្ចេញសម្លេងនិងលើកដាក់សម្លេងការសន្ទនាក្នុងកាសែត

សិស្ស៣០% ជួបពាក្យពិបាកខណៈពេលស្តាប់

សិស្ស ២៥% ជួបការលំបាកទៅលើការនិយាយមានល្បឿនលឿន

សិស្ស ១៩% ស្តាប់មិនសូវបាន និងសម្លេងមិនច្បាស់ពីការសែត

បញ្ហាចម្បងខាងលើធ្វើឱ្យសិស្សមានភាពភ័យខ្លាច និងគ្មានភាពជឿជាក់លើខ្លួនឯងលើការស្តាប់។ ដូចការលើកឡើងរបស់(Brown & Yule 1983b) បានបង្ហាញថាកត្តា៤ ដែលជះឥទ្ធិពលលើការស្តាប់ កង្វះការស្តាប់ផ្ទាល់ផ្អែកទៅលើអ្នកនិយាយ(មានចំនួនប៉ុន្មាន និយាយលឿនប៉ុណ្ណា ប្រើតុងនិយាយអ្វី)អត្ថន័យខ្លឹមសារ (វេយ្យាករណ៍, ពាក្យស័ព្ទ, ព័ត៌មាន, ប្រវត្តចំណេះដឹង) និងការគាំទ្រ (បើទោះជាមានរូបភាព, បាឆាត ឬសម្លេងជំនួយការគាំទ្រអត្ថបទ។

**ការគាំទ្រនិងការបង្កបរិយាកាសសិក្សាមុខភាសាអង់គ្លេស៖**

- ក្រៅពីនេះកត្តាគ្រួសារបរិស្ថានបន្ទប់រៀនបរិស្ថានសាលារៀនសហគមន៍ និងដំណើរការអគារធនធាន ក៏មានឥទ្ធិពលទៅលើបញ្ហាប្រឈមក្នុងការសិក្សារបស់សិស្សដែរ។ ចំពោះបញ្ហាគ្រួសារសិស្សភាគច្រើនមាន ឪពុកម្តាយមានមមាញឹកប្រកបរបរដើម្បីជីវភាព មិនសូវមានពេលវេលាគ្រប់គ្រាន់និងតាមដានមិនសូវមានការលើក ទឹកចិត្តកូនមិននិងជំរុញកូន ប្រើកូនធ្វើការងារផ្សេងៗដែលប៉ះពាល់ដល់ដំណើរការសិក្សារបស់កូន និងខ្វះលទ្ធភាពក្នុងការផ្គត់ផ្គង់កូនៗដើម្បីបានសិក្សាបន្ថែមក្រៅម៉ោងរដ្ឋ។ ចំពោះបញ្ហាបន្ទប់រៀនវិញបន្ទប់រៀនសាលាមួយចំនួនមិនទាន់កង្ហារ ផ្គត់ផ្គង់អគ្គសនី(ព្រីភ្លើង)ដែលជួយដល់តម្រូវការគ្រូនិងសិស្ស លធ្វើឱ្យសិស្សមានអារម្មណ៍មិនសប្បាយចិត្តក្នុងការសិក្សា។ ស្របនឹងការលើកឡើងរបស់(ក្រសួងអប់រំ យុវជននិងកីឡា, ២០១៨) ដើម្បីសម្រេចគោលបំណង និងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅមធ្យមសិក្សាទុតិយភូមិ ទទួលបានជោគជ័យគ្រូត្រូវរៀបចំសកម្មភាពបង្រៀន និងរៀនស្របតាមកម្មវិធីសិក្សា លទ្ធផលសិក្សា និងបរិស្ថានសិក្សា។

**គ.ដំណោះស្រាយលើដំណើរការបង្រៀនៈ**

- បំប៉នគ្រូឯកទេសភាសាងលើជំនាញឯកទេសភាសាអង់គ្លេសលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់សម្ភារឧបទេសឱ្យបានញឹកញាប់គឺការផ្តល់ឱកាសឱ្យលោកគ្រូ អ្នកគ្រូទទួលបានចំណេះដឹងថ្មី ក៏ដូចជាការរំលឹកចំណេះដឹងចាស់ដើម្បីឱ្យពួកគាត់កាន់តែមានភាពច្បាស់លាស់ កាន់តែមានទំនុកចិត្តក្នុងការផ្ទេរចំណេះដឹងទៅឱ្យសិស្ស ហើយសិស្សនឹងឆាប់ចាប់បាននូវការពន្យល់និងបកស្រាយរបស់គ្រូ។

- ពិនិត្យដានការបង្រៀនរបស់លោកគ្រូឯកទេសភាសាអង់គ្លេស និងលើកទឹកចិត្តឱ្យគ្រូធ្វើកិច្ចតែងការបង្រៀន ជាប្រចាំ គឺធ្វើឱ្យគ្រូយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វ័យសិក្សាស្រាវជ្រាវ និងបានត្រៀមរួចជាស្រេចនៅខ្លឹមសារ និងជំហានក្នុងដំណើរការបង្រៀន ដែលជាចលករធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរឡើង។

- សាលាបន្ថែមម៉ោងសិក្សាភាសាអង់គ្លេស ដើម្បីឱ្យគ្រូមានពេលគ្រប់គ្រាន់ក្នុងការបកស្រាយពន្យល់ខ្លឹមសារមេរៀនឱ្យបានលម្អិត និងបន្ថែមទៅលើការបង្រៀនពាក្យ វេយ្យាករណ៍ ឃ្លាវាក្យស័ព្ទ និងមានពេលវេលាគ្រប់គ្រាន់ឱ្យសិស្សអនុវត្តបំណិនស្តាប់ ដោយបញ្ជាក់ខ្លឹមសារឱ្យសិស្សមានភាពជឿជាក់ និងកាន់តែងាយយល់ក្នុងការស្តាប់ និយាយ អាន និងសសេរថែមទៀត។

- ផ្តល់សៀវភៅសិក្សាគោល English For Cambodia ឱ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងហើយធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាគោលឱ្យភាពត្រឹមត្រូវ និងលំដាប់លំដោយត្រឹមត្រូវទៅតាមលំដាប់ពីមួយកម្រិតថ្នាក់ទៅមួយកម្រិតថ្នាក់ ឱ្យមានរូបភាពទាក់ទាញ ការបកស្រាយងាយយល់ និងខ្លឹមសារទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃច្រើន ដែលធ្វើឱ្យទាក់ទាញចំណាប់អារម្មណ៍ពីគ្រូនិងសិស្ស ហើយបង្កឱ្យមានលក្ខណៈងាយស្រួលដល់ដំណើរបង្រៀននិងរៀនក្នុងថ្នាក់ភាសាអង់គ្លេសផងដែរ និងស្របតាមលោក (Richard, 2001) បានលើកឡើងពីការប្រើប្រាស់ សម្ភារៈដូចជា សៀវភៅពុម្ពណការលេងល្បែងការដើរតួ និងសកម្មភាពផ្សេងៗគាំទ្រការបង្រៀន និងមានឥទ្ធិពលលើសកម្មភាពបង្រៀនភាសាបរទេស។

- លើកទឹកចិត្តដល់គណៈគ្រប់គ្រង និងគ្រូរៀបចំបន្ទប់សោតទស្សន៍សម្រាប់អនុវត្តស្តាប់មានការផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធើណែត ដែលជួយគាំទ្រដល់គុណភាពនៃការបង្រៀននិងរៀនភាសាអង់គ្លេស។

- យកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់សម្ភារៈឧបទេសទៅតាមលទ្ធភាព ផលិតសម្ភារៈស្តាប់ដែលងាយៗតាមដែលអាចធ្វើទៅបានដោយមើលតាមវីដេអូក្នុងយូធូបជាដើម។

- ទិញឯកសារស្រាវជ្រាវភាសាអង់គ្លេសថ្មីៗទាន់សម័យកាលបន្ថែមក៏ដូចជាឯកសារស្តាប់អង់គ្លេស ឬវីដេអូឯកសារអង់គ្លេស ដើម្បីឆ្លើយតបទៅនឹងការសិក្សាស្រាវជ្រាវបន្ថែមក្រៅពីសៀវភៅសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

- គ្រូទទួលបន្ទុកថ្នាក់ត្រូវសហការជាមួយគណៈគ្រប់គ្រងដើម្បីពិនិត្យនូវលទ្ធផលសិក្សារបស់សិស្សតាមរយៈការមើលលើមធ្យមភាគនៃការធ្វើតេស្តបញ្ចប់មេរៀនតេស្តប្រចាំឆមាស ឬតេស្តប្រចាំឆ្នាំសិក្សារបស់សិស្ស ដោយរឹតបណ្តឹងនៅការវាយតម្លៃឱ្យសិស្សឡើងថ្នាក់បានលុះត្រាណាសិស្សមានមធ្យមភាគជាប់ប៉ុណ្ណោះ។

**ដំណោះស្រាយលើបញ្ហាប្រឈមក្នុងការរៀនភាសាអង់គ្លេស**

- ពង្រឹងការពិនិត្យតាមដានពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សពីថ្នាក់ក្រោមទៅភាសាអង់គ្លេស ដោយលើកចិត្តគ្រូឱ្យមានមនៈសិកាខ្ពស់ក្នុងការផ្ទេរចំណេះដឹងដល់សិស្ស។

- លើកទឹកចិត្តសិស្សឱ្យស្វ័យសិក្សាស្រាវជ្រាវបន្ថែម ដោយឆ្លុះបញ្ចាំងឱ្យពួកគេឃើញពីអត្ថយោជន៍នៃការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាពិសេសបំណិនស្តាប់ ដែលជួយឱ្យការទំនាក់ទំនងមានភាពងាយស្រួលនឹងមានភាពចាំបាច់លើតម្រូវការទីផ្សារការងារនៅថ្ងៃអនាគត។

**ការគាំទ្រនិងការបង្កបរិយាកាសសិក្សាមុខវិជ្ជាភាសាអង់គ្លេស៖**

- លើកទឹកចិត្តគ្រូដែលបង្រៀនបំប៉នបន្ថែមក្រៅម៉ោងរដ្ឋពុំយកកម្រៃពីសិស្សពុំមានលទ្ធភាព។

- អ្នកពាក់ព័ន្ធគួរលើកទឹកចិត្តដល់គណៈគ្រប់គ្រងដើម្បីរៀបចំកែលម្អបន្ទប់រៀនដែលប្រកប ដោយផាសុកភាព និងបំពាក់បរិក្ខារដែលឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូក្នុងយុគសម័យឌីជីថល។

- លើកទឹកចិត្តគណៈគ្រប់គ្រងឱ្យរៀបចំបន្ទប់Lab សម្រាប់ភាសាបរទេស និងទិញបន្ថែមនូវសម្ភារឧបទេសបន្ថែមទៅតាមលទ្ធភាពនិងឱ្យគ្រូឯកទេសព្យាយាមបង្កើតសម្ភារៈឧបទេសងាយៗ ដែលអាចធ្វើ

ទៅបានដោយការមើលវីដេអូក្នុងយូធូបជាដើម ដើម្បីគាំទ្រដល់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេស ។

- គណៈគ្រប់គ្រងគួររៀបចំខ្លួនដើម្បីឆ្លើយតបទៅនឹងទំនុកចិត្តរបស់ លោកគ្រូ អ្នកគ្រូ សិស្ស សហគមន៍ មាតា បិតា អាណាព្យាបាលសិស្ស ហើយធ្វើការគៀងគររកជំនួយពីសហគមន៍ សប្បុរសជន និងធ្វើបុណ្យផ្កាដើម្បីបានកម្រៃយកមកអភិវឌ្ឍន៍បរិស្ថានសាលា ក៏ដូចជាការឆ្លើយតបទៅលើតម្រូវការសម្ភារឧបទេសរបស់លោកគ្រូ អ្នកគ្រូ។

ក្នុងការផ្ទេរចំណេះដឹងពីគ្រូទៅសិស្សគឺតែងតែមានជួបផលវិជ្ជមាន និងអវិជ្ជមានពីសិស្ស នៅគ្រប់ស្ថានភាពថ្នាក់រៀនក្នុងដំណើរការអប់រំ។មុខវិជ្ជាភាសាអង់គ្លេស ក្នុងដំណើរការថ្នាក់រៀនមានបរិយាកាសល្អឬមានបញ្ហាប្រឈមមួយចំនួនក្តី វាជាកត្តាសត្យានុម័តក្នុងដំណើរការថ្នាក់រៀនប្រចាំថ្ងៃ ព្រោះមនុស្សតែងតែមានសកម្មភាព ហើយសកម្មភាពនោះអាចជាវិជ្ជមានឬអវិជ្ជមាន។ដោយឡែកសិស្សត្រូវតែខិតខំសិក្សាដើម្បីឱ្យលទ្ធផលសិក្សាកាន់តែប្រសើរឡើង ការបង្រៀនមានប្រសិទ្ធភាព និងត្រូវកែលម្អចំនុចខ្វះខាតដើម្បីធ្វើការពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់ខ្លួន ក៏ដូចជាអភិវឌ្ឍខ្លួនឯងដើម្បីសាកសមជាទំពាំងស្នងឬស្សី និងធនធានសម្រាប់សង្គមជាតិ។ការសិក្សាភាសាអង់គ្លេសរបស់សិស្សនៅមានកម្រិតទៅតាមតំបន់ដោយឡែកសិស្សមួយចំនួនមានសមត្ថភាពភាសាអង់គ្លេសកម្រិតមធ្យមនិងការខ្វះខាតវិធីសាស្រ្តរៀន គឺទាមទារការកែតម្រូវពីគ្រូដែលមានបទពិសោធន៍និងវិធីសាស្រ្តបង្រៀន នៅក្នុងសាលារៀនដែលជាថ្នាលបណ្តុះបណ្តាលនូវចំណេះដឹងជំនាញ និងបំណិន គាំទ្រដល់កម្មវិធីសិក្សាការអប់រំពលរដ្ឋពេញលេញនៃកំណែទម្រង់របស់ក្រសួងអប់រំយុវជននិងកីឡា ព្រមទាំងយុទ្ធសាស្រ្តចតុកោណរបស់រាជ រដ្ឋាភិបាល។

# ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

### ៥.១.សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិកន្លងមក អ្នកសិក្សាស្រាវជ្រាវបានរកឃើញថានៅវិទ្យាល័យចំនួន៧ដែលមានទីតាំងនៅកណ្តាលក្រុង ទីប្រជុំជន និងនៅជាយក្រុងនៃរាជធានីភ្នំពេញ។ មានគ្រូបង្រៀនភាសាអង់គ្លេសបានបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនក្នុងកម្រិតមធ្យម(មធ្យមភាគ=៣.៤) បង្ហាញថាគ្រូនៅតាមសាលាមួយចំនួនប្រើវិធីសាស្ត្រអានឱ្យសិស្សស្តាប់ក្នុងការបង្រៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេស និងមិនសូវបានចូលរួមប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងនោះទេ។ គ្រូបង្រៀនប្រើប្រាស់សម្ភារឧបទេសបង្រៀនលើសមត្ថភាពស្តាប់មិនសូវញឹកញាប់ ឡើយ ការលើកទឹកចិត្តពីគណៈគ្រប់គ្រងលើសំណើសុំសម្ភារៈបង្រៀនលើបំណិនស្តាប់ដោយពឹងផ្អែកលើលទ្ធភាពជាក់ស្តែងរបស់សាលានីមួយៗ។ ទន្ទឹមនឹងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនក្នុងកម្រិតមធ្យម ក៏នៅមានបញ្ហាប្រឈមតិចតួច ដែលអ្នកស្រាវជ្រាវរកឃើញលទ្ធផលបញ្ហាប្រឈមនៃការរៀន និងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសក្នុងកម្រិតមធ្យម (មធ្យមភាគ=៣.២០) ដែលបង្ហាញឱ្យឃើញថាការប្រើប្រាស់សម្ភារឧបទេសនៅមានកម្រិត ដោយបណ្ណាល័យខ្វះសៀវភៅ និងឯកសារអានភាសាអង់គ្លេស បន្ទប់សោតទស្សន៍ភាសាបរទេស និងការផ្គត់ផ្គង់សម្ភារឧបទេស ម៉ាញ៉េចាក់កាសែត កាសែតសម្លេង ថាសសម្លេងCDឬVCD មិនទាន់គ្រប់គ្រាន់និងទាន់ពេលវេលា និងកត្តាគ្រូបង្រៀនខ្លួនឯងមិនបានប្រើសម្ភារឧបទេសជួយក្នុងការបង្រៀនសមត្ថភាពស្តាប់ ដែលចាំបាច់បំផុតលើការអនុវត្តស្តាប់ផ្ទាល់ពីម៉ាញ៉េកាសែត ស៊ីឌី ពីការបញ្ចេញសម្លេងផ្ទាល់ ដែលធ្វើឱ្យការប្រើប្រាស់វិធីសាស្ត្របង្រៀននៅមិនទាន់មានប្រសិទ្ធភាពល្អប្រសើរ ជាកត្តាជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការសិក្សារបស់សិស្ស។ ម្យ៉ាងទៀតផ្អែកលើទិន្នន័យឆ្លើយតបលើសំណួរបើករបស់គណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធ បានបង្ហាញពីកត្តា

សិស្សខ្លួនឯងដែលមានចំណេះដឹងទូទៅមិនទូលំទូលាយ និងសមត្ថភាពភាសាអង់គ្លេសរបស់សិស្សមិនស្មើគ្នាក្នុងថ្នាក់តែមួយ។ ចំណែកឯទិន្នន័យឆ្លើយតបរបស់សិស្ស មាន៨៣% មានសមត្ថភាពភាសាអង់គ្លេសកម្រិតមធ្យម និងការប្រើប្រាស់វិធីសាស្រ្តរៀននៅមានលក្ខណៈសើរៗ មិនសូវស៊ីជម្រៅលើបំណិនស្តាប់ ព្រមទាំងមានសិស្ស៥២% មានការលំបាកទៅលើពាក្យស្តាប់មិនសូវបានការបញ្ចេញសម្លេង និងលើកដាក់សម្លេងរបស់ការសន្ទនាក្នុងកាសែត។ បន្ថែមពីនេះមានសិស្ស ៣០ %ជួបពាក្យពិបាកខណៈពេលស្តាប់ សិស្ស២៥ % ជួបការលំបាកទៅលើការនិយាយមានល្បឿនលឿន និងសិស្ស២៥% ជួបការលំបាកទៅលើការស្តាប់មិនសូវបាន និងសម្លេងមិនច្បាស់ពីកាសែត។ ទាំងនេះបង្ហាញពីការប្រើវិធីសាស្រ្តរៀនរបស់សិស្សមិនសូវមានបទពិសោធន៍និងមានកម្រិតនៅឡើយ ដែលជាកត្តាជះឥទ្ធិពលមិនល្អដល់ការសិក្សារៀនសូត្រ និងក្រេបយកចំណេះដឹងភាសាអង់គ្លេស ជាពិសេសលើសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅរាជធានីភ្នំពេញ។

## ៥.២.សំណូមពរ

ដើម្បីចូលរួមលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសលើសមត្ថភាពស្តាប់ ក៏ដូចជាការចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាទាំងមូល អ្នកសិក្សាស្រាវជ្រាវដូចជា៖

### ៥.២.១.ក្រសួងអប់រំ យុវជន និងកីឡា

- សូមរៀបចំផែនការផ្គត់ផ្គង់សម្ភារៈICT និង សម្ភារឧបទេសដោយផ្តោតលើការរៀននិងបង្រៀនភាសាអង់គ្លេស ដាក់ផែនការយុទ្ធសាស្រ្តវិស័យអប់រំ។

- សូមធ្វើវិក្រឹតការគ្រូបង្រៀនភាសាអង់គ្លេស១ឆ្នាំ២ដង។

### ៥.២.២.មន្ទីរអប់រំ យុវជន និងកីឡា

- សូមរៀបចំឱ្យមានប្រជុំផ្លាស់ប្តូរបទពិសោធន៍គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ខេត្ត រាជធានី១ឆមាសម្តង។

- សូមជួយផ្គត់ផ្គង់ សៀវភៅសិក្សាគោលនិង ឯកសារស្រាវជ្រាវភាសាអង់គ្លេសថ្មីៗនិងឯកសារស្តាប់អង់គ្លេសឱ្យទាន់ពេល។

### ៥.២.៣.គណៈគ្រប់គ្រងសាលា

- សូមគណៈគ្រប់គ្រង មានផែនការផ្តល់សម្ភារឧបទេស ដល់គ្រូបង្រៀនភាសាអង់គ្លេសជាប្រចាំ។

- សូមគណៈគ្រប់គ្រង លើកទឹកចិត្តនិងមានការប្រកួតប្រជែងសមត្ថភាពភាសាអង់គ្លេសចំពោះសិស្ស។

### ៥.៤.៣.គ្រូបង្រៀន

- សូមគ្រូធ្វើការស្រាវជ្រាវខ្លឹមសារមេរៀន និងសម្ភារឧបទេសស្របតាមខ្លឹមសារមេរៀននាពេលសម័យបច្ចុប្បន្ន។

- សូមលើកទឹកចិត្តសិស្សឱ្យស្វ័យសិក្សាស្រាវជ្រាវបន្ថែម ដោយឆ្លុះបញ្ចាំងឱ្យពួកគេឃើញពីអត្ថយោជន៍នៃការរៀនភាសាអង់គ្លេស។

### ៥.៤.៤.ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើបញ្ហាប្រឈមនៃការរៀន និងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិ បានតែចំនួន៧វិទ្យាល័យក្នុងចំណោម៤០ គ្រាន់តែជាមួយផ្នែកតូចប៉ុណ្ណោះនៅក្នុងរាជធានីភ្នំពេញ ដោយសារស្ថិតក្នុងស្ថានភាពការរក្សាគម្លាតសុវត្ថិភាពកូវីត១៩ និងការការពារការចម្លងមេរោគកូវីត១៩ អ្នកស្រាវជ្រាវទទួលព័ត៌មានមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ។ ដូចនេះសម្រាប់ការសិក្សាស្រាវជ្រាវបន្ត គួរតែសិក្សាស្រាវជ្រាវបន្តគួរតែទូទាំងប្រទេសកម្ពុជា និងយកសាលាឱ្យបានកាន់តែច្រើន ដើម្បីឱ្យទទួលបានមានលក្ខណៈត្រឹមត្រូវនិងច្បាស់លាស់។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) កម្មវិធីសិក្សាងម្អិតភាសាអង់គ្លេស មធ្យមសិក្សាទុតិយភូមិ២-៤។

ក្រសួងអប់រំ យុវជន និងកីឡា(2016-2020) ផែនការយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៧) របាយការណ៍បូកសរុបរង្វាយតម្លៃការងារ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ និងទិសដៅឆ្នាំ២០១៨-2019។ ក្រសួងអប់រំ យុវជន និងកីឡា។

Abidin, W. X. (2013). English Listening Comprehension Problems os Students from China Learning English in Malaysia. *Linguistics and Translation*, 14009-14020.

Akbari, Z. (2015). *Current challenges in teaching/learning English for EFL learners:The case of junior high school and high school* , 394-401. Retrieved from https://www.sciencedirect.com/science/article/pii/S1877042815045358

Cambodia, M. (2019). *Lifelong Learing* (Vol. 1). (M. Cambodia, Ed.) Phnom Penh, Phnom Penh, Cambodia: Moeys.

Chauhan, B. S. (2015). *Language and its four basic skills with the description of various types, levels and breakdown od students'listening skills*, 6-12.

Cheung, Y. K. (2010-08-28). The Importance of Teaching Listening in the EFL Classroom. 24p.

Contributors, W. (2020, July 2). *Test of English as a Foreign Language.* Retrieved July 2, 2020, from Wikipedia, The Free Encyclopedia: https://en.wikipedia.org/w/index.php?title=Test_of_English_as_a_Foreign_Language&oldid=965629803

Deci, R. M. (2000). *Intrinsic and Extrinsic Motivations: Classic Definitions and New Directions.* doi:doi:10.1006/ceps.1999.1020, available online at http://www.idealibrary.com

Doverspike, W. F. (2006). *How to improve your listening Skills.* doi:770-913-0506

Ekrem Solak, V. (2016). *Teaching Listening Skills.*

Gardner, R. C. (Jan 2006). *The socio-educational model of Second Language Acquisition* (Vol. 6). A research paradigm. doi:https://doi.org/10.1075/eurosla.6.14gar

Kirkpatrick, A.,and Liddicoat, A. (2017). . Language education policy and practice in East and Southeast Asia. Language Teaching, 50(2),.

Kul, C. Y. (08-2010). The Importance of Teaching Listening in the EFL Classroom. *The Importance of Teaching Listening in the EFL Classroom*, 7-20.

Moeys. (2018). orientation conseling.

Muhammad Natsir, D. S. (2014). Grammar Translation Method (GTM) Versus CommunicativeLanguage Teaching (CLT). *Grammar Translation Method (GTM) Versus CommunicativeLanguage Teaching (CLT)*. doi:doi:10.7575/aiac.ijels.v.2n.1p.58

Petty, G. (2004). *Teaching Today* (third Ediotion ed.). United Kingdom: Nelson Thomes LTD. Retrieved from https://books.google.com.kh/books?hl=en&lr=&id=QfSPDVcauFUC&oi=fnd&pg=PP11&dq=teaching+today,+english+1998+stanley+Thornes&ots=BsyKdRATah&sig=Prq-UyTAQY25ZlJm49nNN7GjIl4&redir_esc=y#v=onepage&q&f=false

Renukadevi, D. (2014). *The Role of Listening in Language Acquisition* (Vols. Volume 4,). Research India Publications. Retrieved from http://www.ripublication.com

Richard M. Ryan and Edward L. Deci. (2000). *Intrinsic and Extrinsic Motivations: Classic Definitions and New Directions.* doi:doi:10.1006/ceps.1999.1020, available online at http://www.idealibrary.com

Richard, J. R. (2001). *Approaches and methods in language teaching.* New York: Cambridge University Press.

RosemarySutton, K. S. (2009). *Taylor Foundation.* (E.-I.-C. K. Seifert, Ed.) Retrieved from https://resources.saylor.org/wwwresources/archived/site/wp-content/uploads/2012/06/Educational-Psychology.pdf

Sanjaya, M. N. (2014). Grammar Translation Method (GTM) Versus CommunicativeLanguage Teaching (CLT). *Grammar Translation Method (GTM) Versus CommunicativeLanguage Teaching (CLT)*. doi:doi:10.7575/aiac.ijels.v.2n.1p.58

Seifert, R. K. (2009). *Taylor Foundation.* (E.-I.-C. K. Seifert, Ed.) Retrieved from https://resources.saylor.org/wwwresources/archived/site/wp-content/uploads/2012/06/Educational-Psychology.pdf

Service, U. T. (2020). The Importance of Learning English in Cambodia. doi:https://www.learningenglish-cambodia.com/

Shikare, S. .. (2017). Suggestopedia- a method od teaching English. *Developing best teacher for English*, 178-180.

Solak, E. (April 2016). *Teaching Listening Skills.*

Sothy, I. (2019). Situation of using English Teaching Methods in Lower Secondary School . 12-15.

Spatt, M,Pulvemess,A., & Willams, M. (2005). The KTK teaching Knowledge test course. *he KTK teaching Knowledge test course*.

Stern, H. H. (1983-03-24). *Fundamental Concepts of Language Teaching.pdf.* Oxford University Press. Retrieved 12 Nov 2020, from https://pdf.wecabrio.com/fundamental-concepts-of-language-teaching-stern.pdf

Tweed, A. D., & Som, M.,NarinHeng. (2018). Teaching and Learning English For grade 9 in Kandal Province. *Teaching and Learning English For grade 9 in Kandal Province*, 3.

Uk, E. (November 2018). *Assessment on English for Cambodian Textbook Uses.* (November 2018: https://www.ukessays.com/essays/education/assessment-on-english-for-cambodian-textbook-uses-education-essay.php?vref=1.

VanHa & Stephen, L. 1. (August 4,2020). *The Listening Skill.* Academia. Retrieved August 4, 2020, from wwwhttps://www.academia.edu/36081426/Chapter_II_The_listening_Skill

Zahra, A. (2015). *Current challenges in teaching/learning English for EFL learners:The case of junior high school and high school*, 394-401. Retrieved from https://www.sciencedirect.com/science/article/pii/S1877042815045358

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"

## កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គណៈគ្រប់គ្រង

### កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គណៈគ្រប់គ្រងសាលារៀន( លោកនាយក-នាយករង-នាយិកា-នាយិការង )

នាងខ្ញុំឈ្មោះ **យ៉ា ច័ន្ទសុធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី **"បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ"** ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពីកត្តាជះឥទ្ធិពលលើការសម្រេចចិត្តរបស់លោកគ្រូអ្នកគ្រូ ក្នុងការបង្រៀនសមត្ថភាពស្តាប់ រកឱ្យឃើញពីបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ន ។ ទិន្នន័យដែលប្រមូលបានពីលោក/លោកស្រីដែលជាគណៈគ្រប់គ្រងសាលារៀន មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅនឹងប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូម លោកនាយក-នាយករង លោកស្រីនាយិកា-នាយិការង មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែងដើម្បីឱ្យនាងខ្ញុំអាចយកព័ត៌មានធ្វើជាទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញយកអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមរបស់លោកនាយក-នាយករង លោកស្រីនាយិកា-នាយិការង។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

ការណែនាំ៖ សូមលោកនាយក-នាយករង លោកស្រីនាយិកា-នាយិការង គូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. តួនាទី៖.............................................. ២. បម្រើការងារនៅ៖......................................

៣. ភេទ៖ □ ប្រុស □ ស្រី

៤.អាយុ៖ □ ២៥ - ៣០ ឆ្នាំ □ ៣១ - ៣៥ ឆ្នាំ □ ៣៦ - ៤០ ឆ្នាំ□ លើសពី៤០ឆ្នាំ

៥. កម្រិតវប្បធម៌៖ □ ចប់ថ្នាក់ទី១២ □ បរិញ្ញាបត្រ □ បរិញ្ញាបត្រជាន់ខ្ពស់ □ ផ្សេងៗ៖...

៦. មុខជំនាញឯកទេស៖...................................

៧. បទពិសោធន៍ការងារ៖ □ ១ដល់៥ឆ្នាំ □ ៦ដល១០ឆ្នាំ

□ ១១ដល់១៥ឆ្នាំ □ លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ ការគ្រប់គ្រងនិងដឹកនាំរបស់គណៈគ្រប់គ្រងសាលារៀនលើការរៀននិងបង្រៀន**

**ការណែនាំ៖** សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា(✓)ទៅតាមកម្រិតនៃការយល់ស្របរបស់លោកនាយក-នាយករង លោកស្រីនាយិកា-នាយិការង៖

**១.ខ្សោយណាស់ ២.ខ្សោយ ៣.មធ្យម ៤.ល្អ ៥.ល្អណាស់**

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ៨ | បានចូលរួមថ្នាក់និទស្សន៍របស់លោកគ្រូ-អ្នកគ្រូភាសាអង់គ្លេសបង្រៀនបំណិនស្តាប់ | | | | | |
| ៩ | ធ្វើការតាមដាន និងវាយតម្លៃលើលោកគ្រូ-អ្នកគ្រូ បានបង្រៀនបំណិនស្តាប់តាមរយៈប្រធាន/អនុប្រធានក្រុមភាសាអង់គ្លេស | | | | | |
| ១០ | បានផ្តល់និងផ្គត់ផ្គង់សម្ភារៈឧបទេសតាមសំណើរបស់លោកគ្រូ-អ្នកគ្រូបង្រៀនភាសាអង់គ្លេសដើម្បីជួយគាំទ្រការរៀនបំណិនស្តាប់ | | | | | |
| ១១ | ផ្តល់បន្ទប់ទំនេរសម្រាប់ធ្វើជាបន្ទប់ស្តាប់ និងរៀនភាសាអង់គ្លេស( English Lab ) | | | | | |
| ១២ | បានផ្គត់ផ្គង់ប្រព័ន្ធអ៊ីនធឺណេតដល់លោកគ្រូ-អ្នកគ្រូនិងសិស្សប្រើសម្រាប់បំណិនស្តាប់ក្នុងថ្នាក់ | | | | | |
| ១៣ | លើកទឹកចិត្ត លោកគ្រូ-អ្នកគ្រូនិងសិស្សឱ្យចូលចិត្តអនុវត្តការស្តាប់ភាសាអង់គ្លេសតាមរយៈ ស្តាប់ព័ត៌មាន ចម្រៀង រឿងភាគ រឿងខ្លី ជាភាសាអង់គ្លេសក្នុងថ្នាក់ | | | | | |
| ១៤ | លើកទឹកចិត្តលោកគ្រូ-អ្នកគ្រូ បង្កើតសម្ភារៈឧបទេសដែលមានស្រាប់( Smart phone, Speaker )សម្រាប់ដោនលោតអត្ថបទស្តាប់ពីwebsite របស់ក្រសួងអប់រំយុវជននិងកីឡា ជួយការបង្រៀនបំណិនស្តាប់ | | | | | |

សំណួរ

១៥. តើលោកនាយក/នាយិកាបានបែងចែកសិស្សថ្នាក់ទី១០ ១១ និងថ្នាក់ទី១២រៀនភាសាអង់គ្លេសមានចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍?

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

១៦. តើលោកនាយក/នាយិកាបានបែងចែកលោកគ្រូ-អ្នកគ្រូ កម្រិតឧត្តមបង្រៀនភាសាអង់គ្លេសមានចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៧. តើលោកនាយក/នាយិកាជួបការលំបាកក្នុងការគ្រប់គ្រង និងដឹកនាំលោកគ្រូអ្នកដែលបង្រៀនភាសាអង់គ្លេសកម្រិតឧត្តមសិក្សាលើដំណើរការបង្រៀនរបស់ពួកគាត់អ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៨. តើលោកនាយក/នាយិកាជួបការលំបាកក្នុងការគ្រប់គ្រង និងដឹកនាំសិស្សរៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ? អ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

**មតិយោបល់**

សូមលោកនាយក/នាយិកា មានមតិយោបល់ឬសំណូមពរអ្វីបន្ថែមដើម្បីឱ្យការរៀន និងបង្រៀនលើសមត្ថភាពស្តាប់ភាសាអង់គ្លេសកាន់តែប្រសើរ និងមានប្រសិទ្ធភាពជាងមុន?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

# ឧបសម្ព័ន្ធ "ខ"

# កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់លោកគ្រូ-អ្នកគ្រូ

## កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់លោកគ្រូអ្នកគ្រូ

នាងខ្ញុំឈ្មោះ **យ៉ា ច័ន្ទសុធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី **"បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកម្រិតមធ្យមសិក្សាទុតិយភូមិ។ ករណីសិក្សា៖ រាជធានីភ្នំពេញ** ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពីកត្តាជះឥទ្ធិពលលើការសម្រេចចិត្តរបស់លោកគ្រូអ្នកគ្រូ ក្នុងការបង្រៀនសមត្ថភាពស្តាប់ រកឱ្យឃើញពីបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ន ស្វែងយល់វិធីសាស្ត្របង្រៀនសមស្របនិងការរៀនបំណិនស្តាប់ភាសាអង់គ្លេស និងការជំរុញលើកទឹកចិត្តសិស្ស ។ ទិន្នន័យដែលប្រមូលបានពីលោកគ្រូ អ្នកគ្រូ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅនិងប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូ អ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែងដើម្បីឱ្យនាងខ្ញុំអាចយកព័ត៌មានធ្វើជាទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្រ្ត ដើម្បីទាញយកអំណះអំណាងយកមកសិក្សាបកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមរបស់លោកគ្រូ អ្នកគ្រូ។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា (v)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. តួនាទី៖............................................... ២. បម្រើការងារនៅ៖...............................................

៣. ភេទ៖ □ ប្រុស □ ស្រី

៤.អាយុ៖ □ ២០ - ២៥ ឆ្នាំ □ ២៦ - ៣០ ឆ្នាំ □ ៣១ - ៣៥ ឆ្នាំ

□ ៣៥ - ៤០ ឆ្នាំ □ លើសពី៤០ឆ្នាំ

៥. កម្រិតវប្បធម៌៖ □ ចប់ថ្នាក់ទី១២ □ បរិញ្ញាបត្រ □ បរិញ្ញាបត្រជាន់ខ្ពស់ □ ផ្សេងៗ៖...

៦. មុខជំនាញឯកទេស៖.................................... ៧.បង្រៀនមុខវិជ្ជា៖....................................

1

៨. បទពិសោធន៍ការងារៈ □ ១ដល់៥ឆ្នាំ □ ៦ដល១០ឆ្នាំ

□ ១១ដល់១៥ឆ្នាំ □ លើសពី១៥ឆ្នាំ

**ផ្នែកទី២ៈ វិធីសាស្ត្របង្រៀនបំណិនស្តាប់ភាសាអង់គ្លេស**

៩.តើលោកគ្រូ-អ្នកគ្រូ គិតថាសិស្សភាសាអង់គ្លេសមានចំណេះដឹងកម្រិតបែបណា?ហេតុអ្វី?

.......................................................................................................................................

......................................................................................................................................។

១០.តើលោកគ្រូ-អ្នកគ្រូ គិតថាការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស(Listening Skills) សិស្សចាប់អារម្មណ៍ឬទេ? ហេតុអ្វី?

.......................................................................................................................................

.......................................................................................................................................

......................................................................................................................................។

១១.តើលោកគ្រូ-អ្នកគ្រូ ប្រើវិធីសាស្ត្របង្រៀនអ្វីខ្លះលើការបង្រៀនបំណិនស្តាប់?

.......................................................................................................................................

.......................................................................................................................................

......................................................................................................................................។

១២. តើលោកគ្រូ-អ្នកគ្រូបង្រៀនចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍?

......................................................................................................................................។

១៣. តើលោកគ្រូ-អ្នកគ្រូបានបង្រៀនបំណិនស្តាប់ចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍?បើប្រៀបធៀបនឹងការបង្រៀនបំណិនអាន បំណិនសរសេរ បំណិននិយាយ តើលោកគ្រូ អ្នកគ្រូបង្រៀនបានប៉ុន្មានភាគរយក្នុងមួយសប្តាហ៍?

.......................................................................................................................................

......................................................................................................................................។

2

១៤ តើលោកគ្រូ-អ្នកគ្រូជួបការលំបាកអ្វីខ្លះក្នុងការបង្រៀនបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស (Listening Skills)?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................។

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ប្រើពាក្យ និងឃ្លាសាមញ្ញក្នុងជីវភាពប្រើប្រាស់ប្រចាំថ្ងៃដើម្បីសិស្សងាយយល់ (Direct method) | | | | | |
| ២ | គ្រូពន្យល់ណែនាំសិស្សកំពុងបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស ដោយបកប្រែជាភាសាខ្មែរ (Translation method) | | | | | |
| ៣ | គ្រូឱ្យសិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការចាក់កាសែត( Critical Listening method) | | | | | |
| ៤ | គ្រូអានអត្ថបទផ្ទាល់សម្រាប់សិស្សស្តាប់សម្រាប់បំណិនស្តាប់(The Audio Lingual method) | | | | | |
| ៥ | គ្រូឱ្យសិស្សពិភាក្សាគ្នាជាដៃគូរ ឬក្រុម ជាភាសាអង់គ្លេស(students Centre) | | | | | |
| ៦ | គ្រូឱ្យសិស្សស្តាប់ដោយការយល់ហើយឆ្លើយសំនួរ សំណួរពិត ឬមិនពិត ផ្គូរផ្គង សំណួរជ្រើរើស (Comprehensive listening Method) | | | | | |
| ៧ | គ្រូចាក់ អត្ថបទស្តាប់ដោយ ការសែត CD ក្នុងបន្ទប់រៀន | | | | | |

**ផ្នែកទី២៖ បញ្ហាប្រឈមក្នុងការបង្រៀនបំណិនស្តាប់**

**ការណែនាំ៖** សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា(v)ទៅតាមកម្រិតនៃការយល់ស្របរបស់លោកគ្រូ-អ្នកគ្រូ៖

១.ខ្សោយណាស់ ២ខ្សោយ ៣.មធ្យម ៤.ល្អ ៥.ល្អណាស់

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ក.ការបង្រៀនបំណិនស្តាប់ភាសាអង់គ្លេស | | | | | | |
| ១ | សិស្សមិនយល់ពីភាសាអង់គ្លេសទាល់តែសោះ | | | | | |
| ២ | សិស្សចេះតែពាក្យ និងឃ្លាសាមញ្ញក្នុងជីវភាពប្រើប្រាស់ប្រចាំថ្ងៃ | | | | | |
| ៣ | សិស្សអាចយល់ពីការណែនាំរបស់គ្រូក្នុងពេលកំពុងបង្រៀនបំណិនស្តាប់ | | | | | |
| ៤ | សិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការចាក់កាសែត | | | | | |
| ៥ | សិស្សសិស្សព្យាយាមនិងយកចិត្តទុកដាក់យល់ពីខ្លឹមសារមេរៀនអត្ថបទស្តាប់ដោយការអានផ្ទាល់ពីគ្រូ | | | | | |
| ៦ | សិស្សមានចំណេះដឹងទូទៅទាក់ទងនឹងអត្ថបទស្តាប់មិនទូលំទូលាយ | | | | | |
| ៧ | សិស្សមានការបារម្ភពីការបញ្ចេញសំលេងរបស់អ្នកនិយាយដែលធ្វើឱ្យពួកគេធុញធប់ពីការយល់អត្ថបទ | | | | | |
| ខ.ការប្រើប្រាស់សម្ភារៈឧបទេសជំនួយក្នុងការបង្រៀន | | | | | | |
| ១ | លោកគ្រូ-អ្នកគ្រូ បានប្រើប្រាស់សម្ភារៈឧបទេសរាល់ពេលបង្រៀនបំណិនស្តាប់ភាសាអង់គ្លេសក្នុងថ្នាក់ | | | | | |
| ២ | លោកគ្រូ-អ្នកគ្រូប្រើសៀវភៅសិក្សាគោល English For Cambodia (EFC) តែមួយប៉ុណ្ណោះ | | | | | |
| ៣ | លោកគ្រូ-អ្នកគ្រូមានចំណាប់អរម្មណ៍ខ្លាំងលើភៅសិក្សាគោល English For Cambodia (EFC) | | | | | |

4

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | លោកគ្រូ-អ្នកគ្រូបានចាក់កាសែតឱ្យសិស្សស្តាប់អត្ថបទភាសាអង់គ្លេសក្នុងថ្នាក់រៀនញឹកញាប់ | | | | | |
| ៥ | លោកគ្រូ-អ្នកគ្រូបានបង្កើតសម្ភារៈឧបទេសជំនួយក្នុងការបង្រៀន ដូចជា ពាក្យកាត់ ផ្ទាំងរូបភាពតូច-ធំ casette player radio DVD Video clip ជាភាសាអង់គ្លេស | | | | | |
| **គ.ការជំរុញនិងលើកទឹកចិត្តសិស្សក្នុងការរៀនបំណិនស្តាប់** | | | | | | |
| ១ | លោកគ្រូ-អ្នកគ្រូ ផ្តល់យុទ្ធវិធីក្នុងការបង្កើនចំណេះដឹងការស្តាប់បានល្អប្រសើរជាងមុន | | | | | |
| ២ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សឱ្យចូលចិត្តអនុវត្តការស្តាប់ភាសាអង់គ្លេសតាមរយៈ ស្តាប់ព័ត៌មាន ចំរៀង រឿងភាគ រឿងខ្លី ជាភាសាអង់គ្លេស | | | | | |
| ៣ | លោកគ្រូ-អ្នកគ្រូ បានផ្តល់កំណែ/ព័ត៌មានត្រឡប់ទៅសិស្សវិញក្រោយពីការប្រគល់កិច្ចការនៅផ្ទះ | | | | | |
| ៤ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សដោយការសរសើរ (បណ្ណសរសើរ ពាក្យសរសើរ) | | | | | |
| ៥ | លោកគ្រូ-អ្នកគ្រូលើកទឹកចិត្តសិស្សដោយការសរសើរការផ្តល់រង្វាន់ | | | | | |
| **ឃ.សារៈប្រយោជន៍នៃការរៀនភាសាអង់គ្លេសលើសមត្ថភាពស្តាប់** | | | | | | |
| ១ | អ្នកស្តាប់បានល្អនោះអ្នកនឹងក្លាយជាអ្នកមានការពិនប្រសព្វនិយាយ | | | | | |
| ២ | ការស្តាប់បានល្អ អ្នកមានភាពងាយស្រួលក្នុងការទំនាក់ទំនង | | | | | |
| ៣ | អ្នកចេះភាសាអង់គ្លេសព្រមទាំងស្តាប់បានមានឱកាសការងារល្អ | | | | | |

**មតិយោបល់**

.......................................................................................................................................................

.......................................................................................................................................................។

**សូមអរគុណ!**

5

# ឧបសម្ព័ន្ធ "គ"

*កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់សិស្ស*

## កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់សិស្ស

នាងខ្ញុំឈ្មោះ **យ៉ា ច័ន្ទសុធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី **"បញ្ហាប្រឈមនៃការរៀននិងបង្រៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារៀនកម្រិតមធ្យមសិក្សាទុតិយភូមិរាជធានីភ្នំពេញ"** ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពីបញ្ហាប្រឈមនានាលើការរៀនសមត្ថភាពស្តាប់ភាសាអង់គ្លេសដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធីសាស្រ្តរៀនបំណិនស្តាប់ ។ ទិន្នន័យដែលប្រមូលបានពីសិស្សានុសិស្សដែលរៀននៅវិទ្យាល័យដែលជាគ្រឹះស្ថានរដ្ឋ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅនិងប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមសិស្សានុសិស្សមេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែងដើម្បីឱ្យនាងខ្ញុំអាចយកព័ត៌មានធ្វើជាទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្រ្ត ដើម្បីទាញយកអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមរបស់សិស្សានុសិស្សទាំងអស់គ្នា។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

ការណែនាំ៖ សូមប្អូន គូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. រៀនថ្នាក់ទី៖ ▫ ថ្នាក់ទី១០ ▫ ថ្នាក់ទី១១ ▫ ថ្នាក់ទី១២

២. រៀននៅវិទ្យាល័យ៖ ...........................................

៣. ភេទ៖ ▫ ១. ប្រុស ▫ ១.ស្រី

៤. កម្រិតភាសាបរទេស៖ ▫ ១. ខ្សោយ ▫ ២. មធ្យម ▫ ៣. ល្អ

**ផ្នែកទី២៖ សូមប្អូនជ្រើសរើសពីការប្រើវិធីសាស្រ្តរៀន និង សម្ភារៈរៀនបំណិនស្តាប់ភាសាអង់គ្លេស**

កំណត់ចង្អុលបង្ហាញ៖សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា(✓)ទៅ

តាមកម្រិតនៃការយល់ស្របរបស់ប្អូនៗ៖

១.មិនយល់ស្របទាល់តែសោះ

២.មិនយល់ស្រប

៣. កម្រិងយល់ស្របត្រឹមមធ្យម ឬ៥០%

៤.យល់ស្រប
៥.យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ក.ការប្រើវិធីសាស្ត្ររៀនស្តាប់ភាសាអង់គ្លេស | | | | | | |
| ១ | ប្អូនប្រើការទួសទាយនៅអត្ថន័យពាក្យពិបាកពេលកំពុងស្តាប់ក្នុងស្ថានភាពជាក់លាក់ពិតប្រាកដ។ | | | | | |
| ២ | ប្អូនប្រើការទួសទាយអត្ថន័យខ្លឹមសារអត្ថបទក្រោយពេលស្តាប់អត្ថបទភាសាអង់គ្លេស | | | | | |
| ៣ | ប្អូនប្រើវិធីចងចាំនិងការទន្ទេញដើម្បីយកមកអនុវត្តពេលរៀនបំស្តាប់ភាសាអង់គ្លេសនៅក្នុងថ្នាក់ | | | | | |
| ៤ | ប្អូនជឿជាក់លើខ្លួនឯងក្នុងការស្តាប់គ្រូនិងមិត្តរួមថ្នាក់និយាយភាសាអង់គ្លេសក្នុងថ្នាក់រៀន | | | | | |
| ៥ | ប្អូនទន្ទេញពាក្យថ្មីឱ្យចាំមាត់ក្រោយពីបានស្តាប់អត្ថបទ | | | | | |
| ៦ | គ្រូឱ្យប្អូនពិភាក្សាគ្នាជាដៃគូរ ឬជាក្រុម ជាភាសាអង់គ្លេស | | | | | |
| ៧ | គ្រូជំរុញប្អូនឱ្យប្អូនចូលរួមសកម្មភាពស្តាប់ និងអាន | | | | | |
| ៨ | គ្រូដាក់កិច្ចការនៅផ្ទះទាក់ទងនឹងការស្តាប់ជាភាសាអង់គ្លេស ដោយការសរសេរ | | | | | |
| ៩ | គ្រូជំរុញប្អូនឱ្យប្អូនស្តាប់អត្ថបទផ្សេងៗ ជាភាសាអង់គ្លេស ដូចជា ព័ត៌មាន ចម្រៀង រឿងភាគ ។ល។ | | | | | |
| ១០ | បំណិនស្តាប់ជាជំនាញដែលជាក់ក្នុងការប្រឡងស្តង់ដារអន្តរជាតិ (TOEFL Exam) និង (IELTS) | | | | | |
| ខ.ការប្រើប្រាស់សម្ភារៈរៀនបំណិនស្តាប់ភាសាអង់គ្លេស | | | | | | |
| ១ | ប្អូនចូលចិត្តនិងចាប់អារម្មណ៍លើសៀវភៅសិក្សាគោលEnglish For Cambodia ( EFC ) | | | | | |
| ២ | សៀវភៅពុម្ពភាសាអង់គ្លេសមានរូបភាពទាក់ទាញនិងគួរឱ្យចាប់អារម្មណ៍គួរចង់រៀន | | | | | |
| ៣ | លោកគ្រូអ្នកគ្រូប្រើប្រាស់សម្ភារៈបង្រៀនញឹកញាប់និងទាក់ទាញធ្វើឱ្យប្អូនចូលចិត្តរៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | គ្រូរៀបចំថ្នាក់រៀនសមស្របនឹងសកម្មភាពក្នុងថ្នាក់ពេលរៀនបំណិនស្តាប់ភាសាអង់គ្លេស | | | | | |
| ៥ | គ្រូតែងតែចាក់អត្ថបទស្តាប់ក្នុងថ្នាក់ | | | | | |

**ផ្នែកទី៣៖ បញ្ហាប្រឈមក្នុងការរៀនបំណិនស្តាប់ភាសាអង់គ្លេស**

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ប្អូនមិនមានការភ័យខ្លាចនៅពេលកំពុងស្តាប់ក្នុងស្ថានភាពជាក់លាក់ពិតប្រាកដ។ | | | | | |
| ២ | ប្អូនយល់ថាសិស្សដទៃទៀតស្តាប់យល់ជាងប្អូនខណៈពេលកំពុងស្តាប់ភាសាអង់គ្លេស | | | | | |
| ៣ | ប្អូនជឿជាក់លើខ្លួនឯងក្នុងការស្តាប់ភាសាអង់គ្លេសនៅក្នុងថ្នាក់ | | | | | |
| ៤ | ប្អូនមិនជឿជាក់លើខ្លួនឯងក្នុងការស្តាប់គ្រូនិងមិត្តរួមថ្នាក់និយាយភាសាអង់គ្លេស | | | | | |
| ៥ | នៅពេលអ្នកនិយាយប្រើពាក្យពិបាក ប្អូនបារម្មណ៍ចំពោះការមិនយល់ពីពាក្យនោះ | | | | | |
| ៦ | ប្អូនមានអារម្មណ៍តានតឹងលើការរៀនបំណិនស្តាប់ ជាជាងរៀនបំណិនអាន បំណិនសរសេរ បំណិននិយាយ | | | | | |
| ៧ | ប្អូនមានចំណេះដឹងទូលំទូលាយ ចំពោះការរៀនបំណិនស្តាប់ | | | | | |
| ៨ | ប្អូនមានការជឿជាក់លើខ្លួនឯងពេលស្តាប់ការអត្ថបទដោយគ្រូផ្ទាល់ ខណៈពេលរៀនបំណិនស្តាប់ភាសាអង់គ្លេស | | | | | |
| ៩ | ប្អូនមានការជឿជាក់លើខ្លួនឯងពេលស្តាប់អត្ថបពេលស្តាប់ការសែតភាសាអង់គ្លេស | | | | | |
| ១០ | ប្អូនជួបពាក្យពិបាកនៅពេលដែលប្អូនរៀនបំណិនស្តាប់ភាសាអង់គ្លេស | | | | | |
| ១១ | ខណៈពេលស្តាប់ប្អូនមានការលំបាកលើការបញ្ចេញសម្លេង និងការលើកដាក់សម្លេងរបស់អ្នកនិយាយ | | | | | |
| ១២ | ការស្តាប់ការសែតមានការសន្ទនាលឿនស្តាប់មិនទាន់ | | | | | |
| ១៣ | នៅពេលស្តាប់ក្នុងថ្នាក់មានការរំខានពីខាងក្រៅ | | | | | |

| ១៤ | ការស្តាប់កាសែតមានសម្លេងមិនសូវច្បាស់ និងមានការរអាក់រអួល | | | | | |
|---|---|---|---|---|---|---|

១. តើប្អូនរៀនភាសាអង់គ្លេសមានចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍?

..........................................................................................................................................

.......................................................................................................................................។

២. តើលោកគ្រូ-អ្នកគ្រូបានបង្រៀនសមត្ថភាពស្តាប់ចំនួនប៉ុន្មានម៉ោងក្នុង១សប្តាហ៍? បើប្រៀបធៀបនឹងបំណិនអាន សរសេរ និយាយ មានចំនួនប៉ុន្មានភាគរយ?

..........................................................................................................................................

.......................................................................................................................................។

៣. តើប្អូនជួបការលំបាកអ្វីខ្លះពេលកំពុងរៀនបំណិនស្តាប់ភាសាអង់គ្លេសដោយការចាក់ការសែត?

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................។

៤. តើការរៀនបំណិនស្តាប់ភាសាអង់គ្លេសមានសារៈប្រយោជន៍អ្វីខ្លះលើការទំនាក់ទំនង?

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................។

**មតិយោបល់**

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................។

**សូមអរគុណ!**

# ឧបសម្ព័ន្ធ "ឃ"

## លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

លេខ: ០៤៥ វជអ.

**លិខិតបង្គាប់ការ**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត យ៉ា ច័ន្ទសុជា ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត នី វង្សា

២-គ្រូដឹកនាំរង

លោក លឹម វ៉ាន់

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០

**ជ. នាយកវិទ្យាស្ថានជាតិអប់រំ**

**នាយករង**

បណ្ឌិត.នុច_វីរ៉ា

**កន្លែងទទួល៖**

- ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ៖ www.nie.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ** :១០៦ **ខជអ.** ៨ក

មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ
មកដល់ ថ្ងៃទី... ខែ... ឆ្នាំ20..
ម៉ោង... ចុះលេខ...
បញ្ជូនមកកាន់...

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **យ៉ា ច័ន្ទសុធា** នៅតាមវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ។
**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា លោកស្រី **យ៉ា ច័ន្ទសុធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី **«ការប្រឈមនៃការរៀននិងបង្រៀនលើសម្ថភាពស្តាប់ភាសាអង់គ្លេសនៅសាលារដ្ឋកំរិតមធ្យមសិក្សាទុតិយរាជធានីភ្នំពេញ»** ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ លោក **យ៉ា ច័ន្ទសុធា** នឹងចែកកម្រងសំណួរបំពេញតាមរយៈ Google Form និងសម្ភាសន៍តាមប្រព័ន្ធ ONLINE ដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ដែលកំពុងបំពេញការងារនៅវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។**

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

លេខ ១៤០ ចល.អយក.ភ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

និងបញ្ជូនមក៖

-ការិយាល័យពាក់ព័ន្ធនៃមន្ទីរអយក.ភ

-ការិយាល័យអយក.នៃរដ្ឋបាលខណ្ឌ(ពាក់ព័ន្ធ)

" ដើម្បីព័ត៌មាន-មុខការ "

-គ្រឹះស្ថានមធ្យមសិក្សា ពាក់ព័ន្ធ (ដូចមានក្នុងបញ្ជីជូនភ្ជាប់)

" ដើម្បីសម្របសម្រួល "

-សាមីខ្លួន

" ដើម្បីអនុវត្ត "

-ឯកសារ - កាលប្បវត្តិ

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ពស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២០

**ជ.ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ**

**អនុប្រធាន**

ហេង សារិន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :..............វជអ.**

## លិខិតអញ្ជើញ

សូមគោរពអញ្ជើញ ៖ **និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

*ព័ត៌មានបន្ថែម ៖*

- ✓ *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវធំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- ✓ *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ៖ www.nie.edu.kh